# អង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា (ខេប)

*“ការអភិវឌ្ឍមនុស្សប្រកបដោយសេចក្ដីថ្លៃថ្នូរ”*












**ការិយាល័យ:** សាលាគរុកោសល្យ និងវិក្រិតការខេត្ត ផ្លូវជាតិលេខ ៧ចាស់ ក្រុងកំពង់ចាម ខេត្តកំពង់ចាម

**ប្រអប់សំបុត្រ:** P.O Box ១៦២១ ភ្នំពេញ កម្ពុជា

042-941-481 / 042-941-918

kape@kapekh.org www.kapekh.org

www.facebook.com/kapeaction

www.youtube.com/TheKapeCambodia

www.linkedin.com/in/kapecambodia

https://twitter.com/KAPECambodia


# របាយការណ៍ប្រចាំឆ្នាំ ២០២០

**ចេញផ្សាយនៅថ្ងៃទី ៣១ ខែមករា ឆ្នាំ២០២១**

*(អង្គការ ខេប បានចុះបញ្ជីនៅក្រសួងមហាផ្ទៃក្នុងឆ្នាំ១៩៩៩ និងចុះបញ្ជីជាថ្មីនៅចុងឆ្នាំ២០១៩)*

**សម្គាល់:** សូមមើលអំពីផលជះរបស់គម្រោងនីមួយៗនៅលើគេហទំព័រអង្គការ ខេប។ លោកអ្នកអាចអានករណីសិក្សាបន្ថែមតាមរយៈតំណភ្ជាប់: *kapekh.org/en/what-we-do/4/?pro_id=20*

# សាររប្រធានក្រុមប្រឹក្សាភិបាល



ក្នុងនាមក្រុមប្រឹក្សាភិបាលអង្គការ ខេប ខ្ញុំមានសេចក្ដីសោមនស្សរីករាយយ៉ាងខ្លាំង និងឯកភាពទៅលើរបាយការណ៍ប្រចាំឆ្នាំ២០២០ ដែលចាប់ផ្ដើមពីខែមករា ដល់ចុងបញ្ចប់ខែធ្នូ ឆ្នាំ២០២០ នេះ។ របាយការណ៍នេះបានបង្ហាញទាំងដំណើរការកម្មវិធីជោគជ័យនៅក្នុងបរិយាកាសប្រតិបត្តិការ សមិទ្ធផលថ្មីៗ និងការពង្រីកប្រភពផ្ដល់ហិរញ្ញប្បទាន។ របាយការណ៍ឆ្នាំនេះកើតឡើងចំពេលព្រឹត្តិការណ៍ពិភពលោកកំពុងជួបការរីករាលដាលពីជំងឺកូវីដ ១៩ ដែលបានបង្កបង្កើតឱ្យមានបរិយាកាសប្រតិបត្តិការដ៏លំបាកសម្រាប់អង្គការ ខេប។ ទោះបីជាមានបញ្ហាប្រឈមជាច្រើនបង្កឡើងដោយជំងឺកូវីដ ១៩ នេះក៏ដោយ ក៏អង្គការ ខេប នៅតែអាចសម្របសម្រួលប្រតិបត្តិកម្មវិធីបាន និងរក្សាបាននូវសន្ទុះសកម្មភាពអភិវឌ្ឍន៍មួយចំនួន។ ក្រុមប្រឹក្សាភិបាលសូមចូលរួមអបអរសាទរដល់បុគ្គលិកអង្គការ ខេប ទាំងអស់ដែលបានខិតខំពុះពារជួយកុមារកម្ពុជា ដែលមានវិបត្តិឱ្យទទួលបានសេវាអប់រំមានគុណភាពខ្ពស់ រក្សាបាននូវស្តង់ដារអភិបាលកិច្ចល្អ មានតម្លាភាព និងមានប្រសិទ្ធភាពក្នុងការប្រើប្រាស់ហិរញ្ញប្បទាន៕

**ប្រធានក្រុមប្រឹក្សាភិបាល**

**ហ៊ាន ភុយ**

ខេបគឺជាអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក ដែលធ្វើការចម្បងនៅក្នុងវិស័យអប់រំក្នុងប្រព័ន្ធនៅក្នុងប្រទេសកម្ពុជា។ ខេបបានប្រតិបត្តិការគម្រោងនៅគ្រប់កម្រិតជាមួយអ្នកទទួលផលនៅក្នុងសាលាមត្តេយ្យសិក្សា បឋមសិក្សា អនុវិទ្យាល័យ វិទ្យាល័យ កម្មវិធីអាហារូបករណ៍និស្សិតកម្រិតឧត្តមសិក្សា និងកម្មវិធីថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ។ ចំនួនកុមារទទួលផលផ្ទាល់មានជាង ១២០.០០០នាក់ និងគ្រូបង្រៀនជាច្រើនរយនាក់ ដែលបង្រៀននៅជាង ១៦៥សាលាក្នុង១៣ខេត្ត-រាជធានី។

## ចក្ខុវិស័យ

ចក្ខុវិស័យរបស់ ខេប គឺផ្ដល់លទ្ធភាពដល់កុមារ និងយុវជននូវជម្រើសដ៏ល្អបំផុតនៅក្នុងជីវិតផ្អែកលើសក្ដានុពលរបស់ពួកគេតាមរយៈការទទួលបានការអប់រំល្អ។

## បេសកកម្ម

បេសកកម្មរបស់ខេប គឺធ្វើការជាមួយរដ្ឋាភិបាល សហគមន៍ និងអ្នកពាក់ព័ន្ធផ្សេងទៀត ដើម្បីផ្ដល់អំណាចដល់កុមារ និងយុវជនរងគ្រោះ ក្នុងការសម្រេចបាននូវសិទ្ធិទទួលបានការអប់រំប្រកបដោយគុណភាពតាមរយៈវិធីច្នៃប្រឌិតថ្មី។

## គុណតម្លៃ

- ការផ្ដល់សិទ្ធិអំណាច
- ការសាមគ្គី
- សេចក្ដីមេត្តា
- ការគោរព
- កិច្ចសហប្រតិបត្តិការ
- ការកែប្រែថ្មី/ច្នៃប្រឌិតថ្មី
- តម្លាភាព
- ជឿជាក់



បុគ្គលិកអង្គការ ខេប

# សារនាយកប្រតិបត្តិ



អង្គការ ខេប មានសេចក្ដីសោមនស្សរីករាយ សូមចែករំលែករបាយការណ៍ប្រតិបត្តិប្រចាំឆ្នាំសារពើពន្ធ ២០២០ ជាមួយអ្នកពាក់ព័ន្ធទាំងអស់។ របាយការណ៍ក្នុងឆ្នាំនេះ ធ្វើឡើងចំពេលស្ថានភាពពិភពលោកកំពុងជួបប្រទះនឹងការរីករាលដាលពីជំងឺកូវីដ ១៩ និងការធ្លាក់ចុះសកម្មភាពសេដ្ឋកិច្ចដែលបានជះឥទ្ធិពលយ៉ាងខ្លាំងដល់សង្គមកម្ពុជា។ ដំណើរការកម្មវិធីអង្គការ ខេប បានរងផលប៉ះពាល់យ៉ាងខ្លាំងពីស្ថានភាពនេះ ដោយសារតែសាលារៀនបិទទ្វារ។ ឥទ្ធិពលនេះធ្វើឱ្យប៉ះពាល់ខ្លាំងដល់កម្មវិធីនិងគម្រោងរបស់យើង ក៏ដូចជាកម្មវិធីអភិវឌ្ឍន៍ជាច្រើនទៀត។ ទោះជាមានឧបសគ្គរារាំងទាំងនេះក្ដី កម្មវិធី និងគម្រោងរបស់អង្គការ ខេប នៅតែអាចឈានទៅមុខដោយមានការបោះពុម្ពសៀវភៅ និងឯកសារក្របខណ្ឌថ្មីៗ ក៏ដូចជាការផ្លាស់ប្ដូរទៅជាកម្មវិធីអប់រំតាមអនឡាញសម្រាប់សិស្សសិក្សាជាច្រើន ជាពិសេសកម្មវិធីសាលារៀនជំនាន់ថ្មី។

ចំពោះរបាយការណ៍ប្រចាំឆ្នាំនេះ ខេបបានអនុម័តទម្រង់ថ្មីមួយដែលបង្ហាញពីការងារចូលរួមផ្នែកបច្ចេកទេសជាច្រើន រួមមានៈ ព័ត៌មានវិទ្យា ទំនាក់ទំនង និងបច្ចេកវិទ្យាសម្រាប់ការអប់រំ កម្មវិធីអប់រំបរិយាប័ន្ន និងកម្មវិធីជាច្រើនដទៃទៀត។ សេចក្ដីបង្ហាញក្នុងរបាយការណ៍នេះមានគោលបំណងជួយខេប និងអ្នកពាក់ព័ន្ធឱ្យយល់កាន់តែច្បាស់អំពីតួនាទីជាយុទ្ធសាស្ត្រ ដែលខេបដើរតួនាទីនៅក្នុងប្រព័ន្ធអប់រំ និងគាំទ្រគម្រោងផ្សេងៗផ្សារភ្ជាប់ និងពង្រឹងគ្នាទៅវិញទៅមក។ សេចក្ដីបង្ហាញកម្មវិធីតាមវិធីនេះ ក៏ជាមធ្យោបាយដ៏មានប្រយោជន៍ក្នុងការចាប់ផ្ដើមទសវត្សរ៍ថ្មី និងសង្ខេបផែនការយុទ្ធសាស្ត្រក្នុងផ្នែកពហុបច្ចេកទេស។ ក្នុងន័យនេះ ខេបនឹងធ្វើផែនការយុទ្ធសាស្ត្រឡើងវិញសម្រាប់រយៈពេល ៥ឆ្នាំ (២០២០-២០២៤)។

ទាក់ទងនឹងកម្មវិធីវិញ ខេបរក្សាបាននូវគម្រោងធំៗចំនួន ២០ ក្នុងឆ្នាំ២០២០នេះ ជាការងារទទួលខុសត្រូវធំបំផុតដែលខេបមានជាប្រវត្តិសាស្ត្រ។ ខេបបានបន្តអភិវឌ្ឍន៍កម្មវិធីថ្មីៗដោយជោគជ័យឈានទៅឯកភាពគម្រោងថ្មីចំនួន ៦ ទៀតដែលចាប់ផ្ដើមនៅឆ្នាំ២០២០។ នៅក្នុងខែសីហាឆ្នាំនេះ មូលនិធិ គីន ឆាន់ បានព្រមព្រៀងផ្ដល់ជំនួយប្រចាំឆ្នាំដល់ខេបជាង ១លានដុល្លារ ដើម្បីលើកកម្ពស់កម្មវិធីអប់រំបរិយាប័ន្ននៅតំបន់ដាច់ស្រយាល ដែលធ្វើឱ្យក្លាយជាអង្គការដៃគូដ៏ធំបំផុតរបស់ខេបបន្ទាប់ពីក្រសួងអប់រំយុវជននិងកីឡា។ គម្រោងថ្មីៗ បានជួយធ្វើឱ្យខេបមានតួនាទីនិងយុទ្ធសាស្ត្រដ៏ល្អផងដែរ នៅពេលដែលដៃគូរបស់ខ្លួនកំពុងដោះស្រាយការឆ្លើយតបការអប់រំក្នុងប្រព័ន្ធអំឡុងពេលបរិបទជំងឺកូវីដ ១៩។ ឧទាហរណ៍ គម្រោងថ្មីដែលគាំទ្រហិរញ្ញប្បទានពីភាពជាដៃគូសកលដើម្បីការអប់រំ-អង្គការយូនីសេហ្វ (GPE3-UNICEF) តម្រូវឱ្យខេបធ្វើការងារផ្នែកបច្ចេកទេសជួយដល់ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីដាក់ចេញនូវកម្មវិធីថ្មីគាំទ្រដល់ការសិក្សាបន្ត និងជំរុញប្រព័ន្ធអប់រំតាមអនឡាញឈានទៅមុខលឿន។ តួនាទីសំខាន់របស់ខេបក្នុងគម្រោងនេះបានពង្រឹងការសម្របសម្រួលការងារក្នុងប្រព័ន្ធអប់រំ និងបង្កើនសមត្ថភាពលើកកម្ពស់ព័ត៌មានវិទ្យា ទំនាក់ទំនង និងបច្ចេកវិទ្យាសម្រាប់ការអប់រំនៅក្នុងគម្រោងដទៃៗទៀត។

ខេបបានបន្តទំនាក់ទំនងយ៉ាងរឹងមាំជាមួយក្រសួងអប់រំ យុវជន និងកីឡា និងបន្តតួនាទីថ្មីក្នុងការប្រតិបត្តិកម្មវិធីសាលារៀនជំនាន់ថ្មីក្នុងរយៈពេល៦ឆ្នាំជាប់ៗគ្នា។ ព្រឹត្តិការណ៍សំខាន់មួយទៀតក្នុងកម្មវិធីសាលារៀនជំនាន់ថ្មី គឺការបញ្ចប់ការសិក្សារបស់គរុនិស្សិតពីមជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មីស្ថិតក្នុងវិទ្យាស្ថានជាតិអប់រំ។ ក្រសួងអប់រំ យុវជន និងកីឡាបានស្នើសុំឱ្យខេបបង្កើត និងគ្រប់គ្រងមជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី ដែលបានជួយដល់ខេបយ៉ាងខ្លាំងក្នុងការដើរតួនាទីសំខាន់ក្នុងការអភិវឌ្ឍយុទ្ធសាស្ត្រប្រឹក្សាគរុកោសល្យថ្មីៗ។ គ្រូប្រឹក្សាគរុកោសល្យទាំងនេះទទួលបានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសប្រឹក្សាគរុកោសល្យ ហើយនឹងបន្តអនុវត្តការងារនៅតាមសាលារៀនជំនាន់ថ្មីទាំងអស់ក្រោមក្របខ័ណ្ឌប្រឹក្សាគរុកោសល្យថ្មី។

ក្រៅពីអង្គការយូនីសេហ្វ ខេបក៏បានស្វាគមន៍ម្ចាស់ជំនួយថ្មីៗជាច្រើនទៀតក្នុងឆ្នាំនេះ រួមមានៈ ធនាគារអភិវឌ្ឍន៍អាស៊ី និងអង្គការផេកត៍ ខណៈដែលខេបកំពុងបន្តមានទំនាក់ទំនងរឹងមាំជាមួយដៃគូគ្រឹះស្ថានឯកជន ដូចជា មូលនិធិអាស៊ី មូលនិធិគ្រួសារត្រកូលប្រេ្វងស៍ មូលនិធិហ្វីនីកស៍ មូលនិធិ គីន ឆាន់ មូលនិធិអ្នកទ្រី អង្គការឆាលហ្វាន អង្គការវីវើល-GVC អង្គការវីរីអូប៊ី និងអង្គការសង្គ្រោះកុមារ (SC)។

ជាថ្មីម្ដងទៀត អង្គការ ខេប សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះដៃគូ និងអ្នកពាក់ព័ន្ធទាំងអស់ដែលបានគាំទ្រជាច្រើនឆ្នាំកន្លងមកនេះ ហើយយើងទន្ទឹងរង់ចាំបន្តធ្វើការរួមគ្នា ដើម្បីកែលម្អប្រព័ន្ធអប់រំសម្រាប់កុមារ និងយុវជនកម្ពុជានៅក្នុងឆ្នាំខាងមុខនេះ៕

នាយកប្រតិបត្តិ

សៅ វណ្ណា

## រៀបចំដោយ

| | |
|---|---|
| លោក អឿ សារីន | មន្ត្រីទំនាក់ទំនងជាន់ខ្ពស់ |

## សរសេរជាភាសាអង់គ្លេស

| | |
|---|---|
| លោកឃីត ប៉្រែដិនប៉ែក | ទីប្រឹក្សាបច្ចេកទេសអន្តរជាតិជាន់ខ្ពស់ |

## ត្រួតពិនិត្យខ្លឹមសារ និងកែសម្រួលភាសាខ្មែរ

| | |
|---|---|
| លោក ហ៊ិន ស៊ីមហួន | នាយករងប្រតិបត្តិ/អ្នកសម្របសម្រួលគម្រោងសាលារៀនជំនាន់ថ្មី ( NGS) |
| លោក ឈួន សារ៉ាន | ប្រធានរដ្ឋបាល និងធនធានមនុស្ស |
| លោក ពេជ្រ សុភឿន | ប្រធានគម្រោង BFC |
| លោក ឆន ឆៃយុទ្ធ | ប្រ.សម្របសម្រួលផ្នែក ICT |
| លោក ចាយ ម៉េងឃី | មន្ត្រីកម្មវិធីអំណាន |
| លោកស្រី សែត សុលក្ខណា | អ្នកសម្របសម្រួលអំណាន |
| លោក ផាន់ ប៊ុនណាត | អ្នកសម្របសម្រួលកម្មវិធី |
| លោក ផេង សារ៉ា | មន្ត្រីបណ្តុះបណ្តាលអំណាន |
| លោក ថៃ ធារិទ្ធ | មន្ត្រីកម្មវិធីជាន់ខ្ពស់ |

# មាតិកា


សារប្រធានក្រុមប្រឹក្សាភិបាល....2
សារនាយកប្រតិបត្តិ....3
សេចក្តីសង្ខេប....5
ការឆ្ពុះបញ្ចាំងទៅថ្ងៃអនាគត....7
ព័ត៌មានសំខាន់ៗ និងព្រឹត្តិការណ៍អន្តរជាតិ....8
ការបោះពុម្ពផ្សាយសៀវភៅថ្មីរបស់អង្គការ ខេប....11
ក្រុមហ៊ុន ធីធីអូ អ៊ិមផត អិចផត ឯ.ក....12

អង្គការ ខេប អនុវត្តកម្មវិធីអប់រំច្រើនផ្នែកតាមបច្ចេកទេស....13

- ការអភិវឌ្ឍសាលារៀនធម្មនុញ្ញ....14
- ព័ត៌មានវិទ្យា ទំនាក់ទំនង និងបច្ចេកវិទ្យាសម្រាប់ការអប់រំ (ICT)....15
- ការអភិវឌ្ឍគ្រូបង្រៀន....16
- កម្មវិធីអប់រំបញ្ចូលគ្នា....17
- កម្មវិធីអំណានថ្នាក់ដំបូង....18
- កម្មវិធីមត្តេយ្យសិក្សា....19
- របាយការណ៍ហេដ្ឋារចនាសម្ព័ន្ធ....20
- ការអភិវឌ្ឍបណ្ណាល័យ....21
- ការអប់រំបំណិនជីវិត និងប្រឹក្សាអាជីព....22
- កម្មវិធីឆ្លើយតបនឹងការអប់រំក្នុងបរិបទជំងឺកូវីដ....23

ប្រវត្តិគម្រោង....24
សេចក្តីសង្ខេបហិរញ្ញវត្ថុក្នុងឆ្នាំ២០២០....28
ក្រុមអ្នកគ្រប់គ្រងនៅក្នុងឆ្នាំ២០២០....29
រចនាសម្ព័ន្ធអង្គការ ខេប នៅក្នុងឆ្នាំ២០២០....30

# សេចក្ដីសង្ខេប

ទោះបីជាការរីករាលដាលជំងឺកូវីដ ១៩ បានជះឥទ្ធិពលយ៉ាងខ្លាំងទៅលើល្បឿនអភិវឌ្ឍន៍ការអប់រំក្នុងប្រព័ន្ធអប់រំនៅកម្ពុជាក៏ដោយ ក៏ខេបនៅតែអាចដំណើរកម្មវិធីទៅមុខបាន។ ក្នុងន័យនេះ ខេបបានបង្កើនផ្ដោតការយកចិត្តទុកដាក់លើការអប់រំពីចម្ងាយ និងតាមឌីជីថល ដោយសារតែសាលារៀនបិទទ្វារ ដើម្បីពន្លឿនកម្មវិធីជាច្រើនដោយលើកកម្ពស់ព័ត៌មានវិទ្យា ទំនាក់ទំនង និងបច្ចេកវិទ្យាសម្រាប់ការអប់រំ ព្រមទាំងបង្កើតទំនាក់ទំនងជិតស្និទ្ធជាមួយមជ្ឈមណ្ឌលអប់រំពីចម្ងាយ និងឌីជីថល (CDDE) ដែលត្រូវបានបង្កើតឡើងដោយក្រសួងអប់រំ យុវជន និងកីឡា នៅក្នុងបរិវេណវិទ្យាល័យ ព្រះស៊ីសុវត្ថិក្នុងរាជធានីភ្នំពេញ។ វាមិនត្រឹមតែជាមជ្ឈមណ្ឌលបេះដូងនៃកម្មវិធីសាលារៀនជំនាន់ថ្មីរបស់ខេបនៅវិទ្យាល័យ ព្រះស៊ីសុវត្ថិនោះទេ ប៉ុន្តែជាការជ្រើសរើសរបស់អង្គការយូនីសេហ្វ ដើម្បីជួយសម្របសម្រួលកម្មវិធីឆ្លើយតប និងស្ដារឡើងវិញនូវវិស័យអប់រំក្នុងបរិបទជំងឺកូវីដ ១៩ របស់ក្រសួងអប់រំ យុវជន និងកីឡាបានផ្ដល់នូវមធ្យោបាយដ៏ល្អឥតខ្ចោះមួយដើម្បីសហការយ៉ាងជិតស្និទ្ធជាមួយក្រុម ICT របស់ក្រសួងអប់រំនៅមជ្ឈមណ្ឌល CDDE បាន។ ដូច្នេះ ខេបពិតជាកាន់តួនាទីល្អក្នុងការបន្ត និងប្រើប្រាស់កម្មវិធីសិក្សាពីចម្ងាយនូវកម្មវិធីឌីជីថល ដែលជាអាទិភាពក្នុងពេលការរីករាលដាលជំងឺកូវីដ ១៩ ដើម្បីពន្លឿនការវិនិយោគព័ត៌មានវិទ្យា ទំនាក់ទំនង និងបច្ចេកវិទ្យា ជាពិសេសនៅតាមសាលារៀនជំនាន់ថ្មី។ ទោះបីយ៉ាងណាក៏ដោយ ក៏ការរីករាលដាលជំងឺនេះបានកំហិតមិនអនុញ្ញាតឱ្យបុគ្គលិកខេបដែលមានសមត្ថភាពធ្វើដំណើរទៅបរទេស ឬចូលរួមសន្និសីទ និងសិក្ខាសាលាផ្សេងៗទៀតបានទេ លើកលែងតែការប្រើប្រាស់មធ្យោបាយតាមប្រព័ន្ធអេឡិចត្រូនិកតែប៉ុណ្ណោះ។




| គម្រោងចំនួន ២០ ក្នុងឆ្នាំ២០២០ | | |
|---|---|---|
| **BfC** | ១. សៀវភៅសម្រាប់កម្ពុជា | បន្ត |
| **CERRP** | ២. កម្មវិធីឆ្លើយតប និងស្ដារឡើងវិញនូវវិស័យអប់រំក្នុងបរិបទជំងឺកូវីដ១៩ | ថ្មី |
| **CTSP** | ៣. អាហារូបករណ៍និស្សិតកម្រិតឧត្ដមសិក្សា | បញ្ចប់ |
| **GEI** | ៤. អប់រំកុមារី | បន្ត |
| **GPE3-PE** | ៥. វាយតម្លៃគម្រោង-**GPE3** (**EGRA**) | ថ្មី |
| **HCC** | ៦. កុមារកម្ពុជារីករាយ | បន្ត |
| **KYLA** | ៧. សកម្មភាពយុវជនវ័យក្មេងនៅកម្ពុជា | បន្ត |
| **LSLAG** | ៨. អប់រំជីវិតសម្រាប់កុមារី** | បន្ត |
| **NGPRC** | ៩. មជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី | បន្ត |
| **NGS/SR** | ១០. កម្មវិធីសាលារៀនជំនាន់ថ្មី-ស្វាយរៀង | បន្ត |
| **NGSI** (មធ្យម) | ១១. កម្មវិធីសាលារៀនជំនាន់ថ្មី (មធ្យម)(អយក) | បន្ត |
| **NGSI** (បឋម) | ១២. កម្មវិធីសាលារៀនជំនាន់ថ្មី (បឋម)(អយក) | បន្ត |
| **PC** | ១៣. ពន្លកចំណេះ (សិក្សាស្រាវជ្រាវ) | ថ្មី |
| **QLE** | ១៤. បរិស្ថានសិក្សាប្រកបដោយគុណភាព | បញ្ចប់ |
| **REACH III** | ១៥. បង្កើនភាពងាយស្រួលចូលសាលារៀនតាមរយៈការគាំទ្រពីសហគមន៍ | បន្ត |
| **SEEK** | ១៦. លើកកម្ពស់ការអប់រំ និងការងារនៅកម្ពុជា | ថ្មី |
| **TIGER** | ១៧. លើកកម្ពស់ការឆ្លើយតបនឹងសមភាពយេនឌ័រក្នុងការបង្រៀន និងរៀន | បញ្ចប់ |
| **TRAC III** | ១៨. វិធីសាស្ត្រសរុបដើម្បីពង្រឹងអំណានសម្រាប់កុមារ (ត្រាក់៣/TRACIII) | បន្ត |
| **USE-SDP 2** | ១៩. គម្រោងអភិវឌ្ឍន៍វិស័យអប់រំ - មធ្យមសិក្សា ២ | ថ្មី |
| **YEP** | ២០. គម្រោងសហគ្រិនវ័យក្មេង | ថ្មី |

អំឡុងឆ្នាំ២០២០ ខេបមានលទ្ធភាពរក្សាកម្មវិធីធំៗបានជាប្រវត្តិសាស្ត្រ ដែលមានចំនួន ២០គម្រោង (សូមមើលតារាង)។ ទោះបីជាគម្រោងចំនួន៣ បានបញ្ចប់វដ្ដក៏ដោយ តែសកម្មភាពអភិវឌ្ឍន៍កម្មវិធីបានជួយឱ្យខេបចាប់ផ្ដើមគម្រោងថ្មីចំនួន៦ ក្នុងឆ្នាំនេះ ព្រមទាំងតួនាទីសម្របសម្រួលបច្ចេកទេសសម្រាប់កម្មវិធីឆ្លើយតប និងស្ដារឡើងវិញនូវវិស័យអប់រំនៅកម្ពុជាក្នុងបរិបទជំងឺកូវីដ ១៩ របស់រដ្ឋាភិបាល។ គម្រោងប្រតិបត្តិដោយខេបមាននៅក្នុងទីតាំងចំនួន ១៣ខេត្ត-រាជធានី និងផ្ដល់ផលដល់កុមារនិងយុវជនជាង ១២០.០០០នាក់។ អ្វីដែលសំខាន់នោះ គឺខេបទទួលបានជំនួយពីមូលនិធិ គីន ឆាន់ ក្នុងឆ្នាំ២០២០នេះ មានជាង ១លានដុល្លារ ដែលនឹងជំរុញកិច្ចខិតខំប្រឹងប្រែងរបស់ខេប ដើម្បីលើកកម្ពស់កម្មវិធីអប់រំបរិយាប័ន្ននៅតំបន់ដាច់ស្រយាល។


*គ្រូប្រឹក្សាគរុកោសល្យដែលបញ្ចប់ការសិក្សាបានចូលរួមសិក្ខាសាលាតម្រង់ទិស ដើម្បីចាប់ផ្ដើមការងារថ្មីជាគ្រូប្រឹក្សាគរុកោសល្យមូលដ្ឋាន។*

ព្រឹត្តិការណ៍សំខាន់មួយទៀត ដែលកើតឡើងក្នុងអំឡុងឆ្នាំនេះ គឺការបិទវគ្គសិក្សាជំនាន់ទី១ ឯកទេសប្រឹក្សាគរុកោសល្យពីមជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី (NGPRC)។ គរុនិស្សិតក្នុងនោះចំនួន ២៥នាក់ បានទទួលសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់អប់រំពីរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡានៅក្នុងពិធីដ៏ឱឡារិកមួយនៅវិទ្យាស្ថានជាតិអប់រំក្នុងខែកញ្ញា ឆ្នាំ២០២០។ ក្នុងឆ្នាំ២០១៩ ក្រសួងបានធ្វើកិច្ចព្រមព្រៀងជាមួយខេប ដើម្បីបង្កើតមជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មីស្ថិតក្នុងវិទ្យាស្ថានជាតិអប់រំ ដែលនាំឱ្យមានពិធីសម្ពោធកម្មវិធី

# សេចក្តីសង្ខេប

បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ជំនាន់ទី១ ដែលគ្រប់គ្រងដោយមជ្ឈមណ្ឌល NGPRC។ មជ្ឈមណ្ឌល NGPRC បានលើកកម្ពស់តួនាទីដល់វិទ្យាស្ថានជាតិអប់រំយ៉ាងខ្លាំង ដើម្បីជួយរៀបចំសន្និសីទអន្តរជាតិលើកទី១ ស្តីពី "**ការអប់រំប្រឹក្សាគរុកោសល្យ**" ក្នុងខែធ្នូ ឆ្នាំ២០២០ គឺជាព្រឹត្តិការណ៍ប្រចាំឆ្នាំ ដែលរៀបចំឡើងដោយមជ្ឈមណ្ឌល និងក៏ជាសន្និសីទតែមួយគត់ធ្វើឡើងសម្រាប់ការប្រឹក្សាគរុកោសល្យដល់គ្រូនៅក្នុងតំបន់អាស៊ាន។ សមិទ្ធផលនេះជួយឱ្យខេបឈានមុខគេក្នុងការខិតខំប្រឹងប្រែងលើកកម្ពស់ប្រឹក្សាគរុកោសល្យគ្រូ។




ខេបបានបោះពុម្ពផ្សាយសៀវភៅបច្ចេកទេស និងឯកសារក្របខ័ណ្ឌមួយចំនួនធំ ដែលផ្តល់ជាឧទាហរណ៍នូវគំនិតច្នៃប្រឌិតថ្មីនៅក្នុងប្រព័ន្ធអប់រំ រួមមាន៖ ផែនទីបង្ហាញផ្លូវនូវរបៀបធ្វើបរិបទនិន្នាការក្នុងសតវត្សរ៍ទី២១ ស្ថាបត្យកម្មសាលារៀននេះជាបរិបទកម្ពុជាថ្មី សៀវភៅអភិវឌ្ឍន៍បណ្ណាល័យសតវត្សរ៍ទី២១ ឯកសារក្របខ័ណ្ឌគរុកោសល្យថ្មីសម្រាប់ជួយក្រសួងអប់រំ យុវជន និងកីឡាប្តូរវិធីសាស្ត្រធ្វើទំនើបកម្មក្នុងថ្នាក់រៀនជាក្របខ័ណ្ឌថ្មីសម្រាប់ពង្រីកកម្មវិធីសាលារៀនជំនាន់ថ្មីទៅក្នុងវិស័យមត្តេយ្យសិក្សា និងឯកសារជាច្រើនទៀតស្តីពីប្រឹក្សាគរុកោសល្យគ្រូ។

ខេបបានបន្តនឹងមានមោទនភាពចំពោះទំនាក់ទំនងជិតស្និទ្ធជាមួយក្រសួងអប់រំយុវជននិងកីឡា។ ខេបពិតជាអង្គការ តែមួយគត់ដែលទទួលបានហិរញ្ញប្បទានពីក្រសួងអប់រំយុវជននិងកីឡា។ ក្រសួងបានអនុម័តយល់ព្រមផ្តល់ហិរញ្ញប្បទានផ្ទាល់រយៈពេល ៦ឆ្នាំ មកដល់ឆ្នាំ២០២១ ដើម្បីបន្តការប្រតិបត្តិកំណែទម្រង់កម្មវិធីសាលារៀនជំនាន់ថ្មី។ បច្ចុប្បន្ននេះ ក្រសួងអប់រំ យុវជន និងកីឡា គឺជាម្ចាស់ជំនួយដ៏ធំបំផុតរបស់ខេប ដែលបានផ្តល់ហិរញ្ញប្បទានចំនួន ១,៨ លានដុល្លារក្នុងឆ្នាំសារពើពន្ធបច្ចុប្បន្ន ដើម្បីគាំទ្រដល់កំណែទម្រង់កម្មវិធីសាលារៀនជំនាន់ថ្មី។

ខេបបានបន្តប្រមូលផ្តុំកម្មវិធីអប់រំថ្មីៗជាច្រើនដែលអាចធ្វើបរិបទដល់ប្រព័ន្ធសាលារៀននៅប្រទេសកម្ពុជា។ ឈ្មោះកម្មវិធីសុសវែរថ្មីដែលខេបបង្កើត ឬធ្វើបរិបទ រួមមាន៖ កម្មវិធី**អានខ្មែរ**(អំណានថ្នាក់ទី១) **សៀវភៅឆ្លាត**(អំណានតាមអេឡិចត្រូនិចសម្រាប់កម្រិតថ្នាក់ទី២ និងទី៣) **សរសេរខ្មែរ** ( សំណេរថ្នាក់ដំបូងភាសាខ្មែរ) ***Literatu*** (វាយតម្លៃតាមអេឡិចត្រូនិច) **ត្រីវិស័យ** (ប្រឹក្សាអាជីពតាមអេឡិចត្រូនិច) **អំណាន-X** (ការសិក្សាភាសាអង់គ្លេស)


*រចនាបថបន្ទប់កុំព្យូទ័រថ្មីនៅក្នុងសាលារៀនដែលគាំទ្រដោយអង្គការ ខេប ដើម្បីប្រើប្រាស់ជាទីកន្លែង និងផ្តល់ភាពងាយស្រួលដល់គ្រូបង្រៀន និងសិស្សសិក្សាឱ្យបានជាអតិបរិមា។*

**រឿងអប់រំ**(ការអប់រំយេនឌ័រ) **អំណានភាសាខ្មែរ**(ការវិភាគអត្ថបទ) **អុបស៊ើរីក**(ប្រឹក្សាគរុកោសល្យគ្រូ) និងកម្មវិធីថ្មីៗ **Platform** ធនាគារសំណួរ។ កម្មវិធីសុសវែរទាំងនេះមានគោលដៅទាំងនៅកម្រិតបឋមសិក្សា និងមធ្យមសិក្សា ហើយបច្ចុប្បន្នកំពុងបញ្ចូលទៅក្នុងពហុគម្រោង។ ការខិតខំទាំងនេះធ្វើឱ្យខេបក្លាយជាអ្នកឈានមុខគេក្នុងការអភិវឌ្ឍ និងប្រតិបត្តិកម្មវិធីអប់រំ ដែលរៀបចំឡើងសម្រាប់ប្រព័ន្ធសាលារៀននៅកម្ពុជា។ ការប្រើប្រាស់សុសវែរក្នុងការអប់រំគឺស្របតាមផែនការយុទ្ធសាស្ត្រខេប ដើម្បីបង្កើតប្រសិទ្ធភាពប្រតិបត្តិការអប់រំដោយប្រើប្រាស់បច្ចេកវិទ្យាជាច្រើន។

ស្ថានភាពហិរញ្ញវត្ថុសរុបរបស់ខេបនៅតែបន្តមានការកើនឡើងក្នុងអំឡុងឆ្នាំនេះ ប្រាក់ចំណូលប្រចាំឆ្នាំកើនពី ៣,៧៦ លានដុល្លារក្នុងឆ្នាំសារពើពន្ធ២០១៩ ដល់ **៣,៨៨ លានដុល្លារ**នៅឆ្នាំ២០២០ ឬកើនឡើងចំនួន **៣**%។ នៅចុងឆ្នាំនេះ ខេបមានម្ចាស់ជំនួយ និងដៃគូចំនួន១៧ រួមទាំងម្ចាស់ជំនួយថ្មី ឬអតីតម្ចាស់ជំនួយ ដូចជា៖ សហគមន៍អឺរ៉ុប Lotus Outreach និង Gap, Inc.។ ទោះបីជាយ៉ាងណាក៏ដោយ យើងកត់សម្គាល់ឃើញថា បច្ចុប្បន្នចំណូលខេប **៤៧**%បានមកពីក្រសួងអប់រំ យុវជន និងកីឡា ដែលធ្វើឱ្យរាជរដ្ឋាភិបាលកម្ពុជាជាម្ចាស់ជំនួយដ៏ធំបំផុតរបស់ខេប។ **២១,៣១**%ទៀតមកពីមូលនិធិឯកជន ចំណូលមួយផ្នែកទៀតបានមកពីទ្វេភាគី ឬពហុភាគី។ នាឆ្នាំកន្លងមក ចំនួន **៦២**% នៃទំហំធនធានរបស់ខេបត្រូវបានចំណាយទៅលើការគាំទ្រអ្នកទទួលផល រួមមាន៖ សេវាកម្មអប់រំ សម្ភារសិក្សា និងគ្រឿងបរិក្ខារ ថវិកាសាលារៀន និងការសិក្សាស្រាវជ្រាវក្នុងឆ្នាំ២០២០៕



គរុនិស្សិតបញ្ចប់ការសិក្សាបានចូលរួមកម្មវិធីប្រឹក្សាគរុកោសល្យក្នុងបន្ទប់សិក្ខាសាលាទំនើបនៅមជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី។ មជ្ឈមណ្ឌល NGPRC ស្ថិតនៅក្នុងវិទ្យាស្ថានជាតិអប់រំ រាជធានីភ្នំពេញ និងផ្ដល់ការសិក្សាលើកម្មវិធីបរិញ្ញាបត្រជាន់ខ្ពស់អប់រំដំបូងគេ ដែលផ្ដល់ដោយវិទ្យាស្ថាន។ មជ្ឈមណ្ឌលត្រូវបានគ្រប់គ្រងដោយអង្គការ ខេប តាមសំណើរបស់ក្រសួង និងផ្ដល់នូវកម្មវិធីសិក្សាពិសេសជាថ្នាក់រៀនតូចៗបែបសិក្ខាសាលា និងបំពាក់ដោយបរិក្ខារអប់រំទំនើបៗ។



ក្មេងស្រីងាយរងគ្រោះនៅអនុវិទ្យាល័យមួយក្នុងខេត្តត្បូងឃ្មុំទទួលបានកង់ ដែលជាផ្នែកមួយនៃកញ្ចប់អាហារូបករណ៍ផ្ដល់ដោយខេប។ កញ្ចប់អាហារូបករណ៍នេះគាំទ្រដោយហិរញ្ញប្បទានពីអង្គការ Lotus Outreach និងស្វែងរកដំណោះស្រាយបញ្ហាចំណាយលើការសិក្សាពីចម្ងាយ និងឱកាសសម្រាប់ក្មេងស្រីឱ្យបន្តការសិក្សាបន្ទាប់ពីពួកគាត់បញ្ចប់បឋមសិក្សា។

## ការឆ្លុះបញ្ចាំង និងឆ្ពោះទៅមុខ...!

ដោយសារវដ្ដគម្រោងមួយចំនួនគ្រោងនឹងបញ្ចប់នៅចុងឆ្នាំ២០២០ ខេបបានបន្តវិនិយោគយ៉ាងច្រើនក្នុងការអភិវឌ្ឍកម្មវិធីដែលឆ្លើយតបផែនការយុទ្ធសាស្ត្ររយៈពេល៥ឆ្នាំ។ ដូចបង្ហាញរួចមកហើយ ខេបបានផ្ដោតយកចិត្តទុកដាក់ច្រើនលើកម្មវិធីឆ្លើយតបនឹងការអប់រំក្នុងបរិបទជំងឺកូវីដ ១៩ រួមមាន៖ អក្ខរកម្មថ្នាក់ដំបូង បច្ចេកវិទ្យាសម្រាប់ការអប់រំ សំខាន់ជាងគេបំផុតនោះគឺការអភិវឌ្ឍសាលារៀនធម្មនុញ្ញ។ ជាសរុប គម្រោងចំនួន១៦ បានដាក់ជូនម្ចាស់ជំនួយត្រួតពិនិត្យ និងឯកភាព។ ក្នុងគម្រោងទាំងអស់ទទួលបានជោគជ័យ លើកលែងតែចំនួនបីគម្រោងកំពុងរង់ចាំ (សូមមើលកម្មវិធី **ROTA**[9], **ZOOM** និងមូលនិធិ **Spencer**) ដែលបង្កើតអត្រាជោគជ័យ ៨១%។ គម្រោងអនុម័តចំនួនប្រាំបីជាគម្រោងពង្រីកបន្តខណៈមួយផ្នែកទៀតជាគម្រោងថ្មី (ឧ. គម្រោងអភិវឌ្ឍន៍វិស័យអប់រំមធ្យមសិក្សា២ គម្រោងសហគ្រិនវ័យក្មេង) ឬការបង្កើនហិរញ្ញប្បទានសម្រាប់គម្រោងដែលមានស្រាប់ (**LSLAG**)។ ជាលទ្ធផលនៃការខិតខំប្រឹងប្រែងអភិវឌ្ឍន៍កម្មវិធីក្នុងឆ្នាំនេះ ខេបរំពឹងថានឹងមានគម្រោងចំនួន១៩ ឬច្រើនជាងនេះនៅក្នុងឆ្នាំសារពើពន្ធក្រោយនេះ។

## សេចក្ដីសង្ខេបការអភិវឌ្ឍកម្មវិធីថ្មីៗក្នុងឆ្នាំ២០២០

| គម្រោង | ដៃគូ | ម្ចាស់ជំនួយ | លក្ខខណ្ឌ | រយៈពេល |
|---|---|---|---|---|
| ១). គម្រោង សៀវភៅសម្រាប់កម្ពុជា (ពង្រីកបន្ត) | ក្រសួងអប់រំ យុវជន និងកីឡា | អង្គការមូលនិធិអាស៊ី | ជោគជ័យ | ១ឆ្នាំ |
| ២). កម្មវិធីឆ្លើយតប និងស្ដារឡើងវិញនូវវិស័យអប់រំនៅកម្ពុជាក្នុងបរិបទជំងឺកូវីដ ១៩ គាំទ្រដោយភាពជាដៃគូសកលដើម្បីការអប់រំ។ | អង្គការវើរ៉ូប៊ី | អង្គការយូនីសេហ្វ-GPE3 | ជោគជ័យ | ១ឆ្នាំ |
| ៣). គម្រោង អប់រំកុមារ | អង្គការ Aide et Action | មូលនិធិ Qatar | ជោគជ័យ | ៣ឆ្នាំ |
| ៤). គម្រោង សិក្សាសកល | អង្គការ CARE | អង្គការ ROTA | កំពុងរង់ចាំ | ៣ឆ្នាំ |
| ៥). គម្រោង វាយតម្លៃ-GPE3 (អ៊ីក្រា-EGRA) | អង្គការយូណេស្កូ-ក្រសួងអប់រំ យុវជន និងកីឡា | អង្គការភាពជាដៃគូសកលដើម្បីការអប់រំ ៣ (GPE3) | ជោគជ័យ | ៣ឆ្នាំ |
| ៦). គម្រោង កុមារកម្ពុជារីករាយ (ពង្រីកបន្ត) | អង្គការគ្រួសារយើង | មូលនិធិ គីន ឆាន់ ស្ទីហ្វទុង | ជោគជ័យ | ១ឆ្នាំ |
| ៧). គម្រោង អប់រំបំណិនជីវិតសម្រាប់កុមារី (ពង្រីកហិរញ្ញប្បទាន) | -- | ក្រុមហ៊ុន Gap, Inc. | ជោគជ័យ | ១ឆ្នាំ |
| ៨). មជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី (ពង្រីកលើកទី៣) | អង្គការឆាលហ្វាន<br>មូលនិធិគ្រួសារត្រកូលហ្វ្រេងស៍ | ក្រសួងអប់រំ យុវជន និងកីឡា | ជោគជ័យ | ១ឆ្នាំ |
| ៩). គម្រោង សាលារៀនជំនាន់ថ្មី/កម្រិតសាលាបឋមសិក្សា (ពង្រីកលើកទី៤) | មូលនិធិគ្រួសារត្រកូលហ្វ្រេងស៍ | ក្រសួងអប់រំ យុវជន និងកីឡា | ជោគជ័យ | ១ឆ្នាំ |
| ១០).គម្រោង សាលារៀនជំនាន់ថ្មី/កម្រិតសាលាបឋមសិក្សា (ពង្រីកលើកទី៥) | មូលនិធិគ្រួសារត្រកូលហ្វ្រេងស៍ | ក្រសួងអប់រំ យុវជន និងកីឡា | ជោគជ័យ | ១ឆ្នាំ |
| ១១). គម្រោង សិក្សាស្រាវជ្រាវតាមអនឡាញ | -- | មូលនិធិ Spencer | កំពុងរង់ចាំ | ៣ឆ្នាំ |
| ១២).គម្រោង សិក្សាពីចម្ងាយសម្រាប់មុខវិជ្ជាស្នែមនៅកម្ពុជា | អង្គការមូលនិធិអាស៊ី | អង្គការ ZOOM | កំពុងរង់ចាំ | ១ឆ្នាំ |
| ១៣).គម្រោង បង្កើនភាពងាយស្រួលចូលសាលារៀនតាមរយៈការគាំទ្រពីសហគមន៍ IV (ពង្រីកបន្ត) | អង្គការ Ciai | អង្គការវីវើល-GVC | ជោគជ័យ | ២ឆ្នាំ |
| ១៤). គម្រោងអភិវឌ្ឍន៍វិស័យអប់រំ-មធ្យមសិក្សា | អង្គការ VSO | ធនាគារអភិវឌ្ឍន៍អាស៊ី -<br>ក្រសួងអប់រំ យុវជន និងកីឡា | ជោគជ័យ | ៣ឆ្នាំ |
| ១៥). គម្រោង សហគ្រិនវ័យក្មេង | -- | អង្គការ PACT-USAID | ជោគជ័យ | ១ឆ្នាំ |
| ១៦).គម្រោង CAPFISH | អង្គការ Aide et Action<br>អង្គការ Oxfam-GB | សហគមន៍អឺរ៉ុប | ជោគជ័យ | ៣ឆ្នាំ |

[9] *កម្មវិធី Reach Out To Asia*

# ព័ត៌មាន និងព្រឹត្តិការណ៍អន្តរជាតិសំខាន់ៗ

*“ការអភិវឌ្ឍតាមរយៈបណ្តាញ និងនៅថ្នាក់មូលដ្ឋាន”*

## ខេបធ្វើការជាមួយវិទ្យាស្ថានជាតិអប់រំ ដែលបានរៀបចំសន្និសីទអន្តរជាតិលើកទី១ ស្តីពី "ការអប់រំប្រឹក្សាគរុកោសល្យ"




នេះជាសមិទ្ធផលមួយក្នុងចំណោមសមិទ្ធផលធំៗដែលសម្រេចបាននៅក្នុងឆ្នាំ២០២០គឺសន្និសីទអន្តរជាតិលើកទី១ស្តីពី “**ការអប់រំប្រឹក្សាគរុកោសល្យ**” ដែលរៀបចំដោយមជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី(NGPRC)។ នៅក្នុងឆ្នាំ២០១៩ ក្រសួងអប់រំ យុវជន និងកីឡាបានស្នើសុំខេបបង្កើត និងគ្រប់គ្រងមជ្ឈមណ្ឌល NGPRC ដើម្បីលើកកម្ពស់ការបណ្តុះបណ្តាលគ្រូ និងការស្រាវជ្រាវក្នុងវិស័យឧត្តមសិក្សានៅវិទ្យាស្ថានជាតិអប់រំ។ ទោះបីជាសន្និសីទគ្រោងធ្វើដំបូងនៅខែសីហា ឆ្នាំ២០២០ក៏ដោយ ប៉ុន្តែវាត្រូវបានពន្យារពេលដល់ថ្ងៃទី២១-២៣ ខែធ្នូ ឆ្នាំ២០២០ ដោយសារជំងឺកូវីដ ១៩ ហើយប្រើបែបបទរៀនតាមអនឡាញ។ ជាក់ស្តែងប្រហែលជាសន្និសីទ អនឡាញពេញលេញលើកទី១នៅកម្ពុជា។ ទោះយ៉ាងណាក្តីសន្និសីទនេះមានអ្នកចូលរួមពីអន្តរជាតិយ៉ាងច្រើន និងមានវាគ្មិនចំនួន ៦៦នាក់ដែលបានចូលរួមក្នុងដំណើរការស្រាវជ្រាវចុងក្រោយស្តីពី “**ប្រឹក្សាគរុកោសល្យគ្រូ**”។ សន្និសីទនេះមានវាគ្មិនសំខាន់ពីថ្នាក់ជាតិគឺឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំយុវជននិងកីឡា។ សន្និសីទនេះបង្ហាញជាលើកដំបូងអំពីវិទ្យាស្ថានជាតិអប់រំបានរៀបចំសន្និសីទអន្តរជាតិមួយជាប្រវត្តិសាស្ត្រ។ សមិទ្ធផលនេះសង្ឃឹមថាជារបត់មួយចំពោះលក្ខណៈ និងកេរ្តិ៍ឈ្មោះវិទ្យាស្ថានជាតិអប់រំសម្រាប់លើកមុខមាត់វិទ្យាស្ថានបណ្តុះបណ្តាលគ្រូជាន់ខ្ពស់នៅកម្ពុជា។ ខេបរំពឹងថាសន្និសីទនេះនឹងក្លាយជាកាលវិភាគជាប់លាប់របស់វិទ្យាស្ថានជាតិអប់រំ ហើយនឹងជួយពង្រឹងកេរ្តិ៍ឈ្មោះទាំងមជ្ឈមណ្ឌល និងវិទ្យាស្ថានក្នុងនាមជាអ្នកនាំមុខគេក្នុងការច្នៃប្រឌិតការអប់រំ៕

### គោលបំណងសន្និសីទអន្តរជាតិនៅកម្ពុជាស្តីពី "ការអប់រំប្រឹក្សាគរុកោសល្យ" ដើម្បី៖

1. *ផ្តល់វេទិកាសម្រាប់ស្រាវជ្រាវពីសហគមន៍អន្តរជាតិ។*
2. *បង្ហាញមាគ៌ាថ្មីចំពោះឧត្តមភាពក្នុងការអប់រំតាមរយៈសកម្មភាព និងការច្នៃប្រឌិត។*
3. *ចែករំលែកការអនុវត្តការបង្រៀនល្អៗ និងប្រើលទ្ធផលស្រាវជ្រាវដើម្បីដោះស្រាយបញ្ហាសាលារៀន។*
4. *ចែករំលែកបទពិសោធន៍ប្រឹក្សាគរុកោសល្យគ្រូ និងជំនាញ*
5. *បង្កើតភាពជាដៃគូ និងការសហការគ្នារវាងអ្នកស្រាវជ្រាវនៅទូទាំងពិភពលោក។*
6. *ផ្សព្វផ្សាយលទ្ធផលនិក្ខេបបទ / សកម្មភាពផ្សព្វផ្សាយការអប់រំនៅថ្នាក់ឧត្តមសិក្សា និង*
7. *រៀបគំនូទស្សនៈថ្មីៗក្នុងការដោះស្រាយបញ្ហាអប់រំ និងការរៀបចំសន្និសីទ។*

## ខេបត្រូវបានក្រសួងអប់រំ យុវជន និងកីឡា ជ្រើសរើសឱ្យផ្តល់ការគាំទ្រផ្នែកបច្ចេកទេស នៅក្នុងកម្មវិធីសំខាន់ៗរបស់រដ្ឋាភិបាល

ភាពលេចធ្លោរបស់ខេបនៅក្នុងវិស័យអប់រំបានបន្តកើនឡើងអំឡុងឆ្នាំនេះ ដោយសារក្រសួងអប់រំ យុវជន និងកីឡាជ្រើសរើសខេបឱ្យផ្តល់ការគាំទ្រផ្នែកបច្ចេកទេសនៅក្នុងពហុកម្មវិធីសំខាន់ៗកម្រិតខ្ពស់ថ្នាក់ជាតិ។ នៅពាក់កណ្តាលឆ្នាំនេះ ខេបបានផ្តល់ជំនួយបច្ចេកទេសដល់កម្មវិធីអភិវឌ្ឍន៍វិស័យអប់រំ-មធ្យមសិក្សា ២ (USE-SDP2) ដែលផ្តល់ការគាំទ្រដល់អនុវិទ្យាល័យចំនួន ១៣៧ ទូទាំងប្រទេស ដែលជាផ្នែកមួយនៃប្រាក់កម្ចីពីធនាគារអភិវឌ្ឍន៍អាស៊ីចំពោះរាជរដ្ឋាភិបាលកម្ពុជា។ នៅចុងឆ្នាំ២០២០ ខេបត្រូវបានក្រសួងអប់រំ យុវជន និងកីឡា និងអង្គការយូនីសេហ្វជ្រើសរើសឱ្យជួយសម្របសម្រួលការងារគាំទ្របច្ចេកទេសដល់កម្មវិធីឆ្លើយតប និងស្តារឡើងវិញនូវវិស័យអប់រំនៅកម្ពុជាក្នុងបរិបទជំងឺកូវីដ ១៩ ដែលគាំទ្រហិរញ្ញប្បទានពីអង្គការភាពជាដៃគូសកលសម្រាប់ការអប់រំ(GPE)។ កម្មវិធីគាំទ្របច្ចេកវិទ្យាទាំងពីរនេះបានធ្វើឱ្យខេបមានការជឿជាក់ និងក្លាយជាតួនាទីស្នូលមួយសម្រាប់ប្រើប្រាស់គំនិតច្នៃប្រឌិត និងបុគ្គលិកដែលមានបទពិសោធន៍ខ្ពស់៕



*ឯកឧត្តម ណាត ប៊ុនរឿន រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា បានដឹកនាំកិច្ចប្រជុំស្វាគមន៍អង្គការ ខេប ដើម្បីជួយប្រតិបត្តិគម្រោងអភិវឌ្ឍន៍វិស័យអប់រំ - មធ្យមសិក្សា 2 (USE-SDP 2)។*

# និស្សិតខេបជំនាន់ទី៣ ទទួលសញ្ញាបត្របរិញ្ញាបត្រ ពីសាកលវិទ្យាល័យវេស្ទើន



ក្មេងស្រី ៣០នាក់ ដែលជានិស្សិតអាហារូបករណ៍ជំនាន់ទី៣ ហើយនឹងបញ្ចប់ការសិក្សានៅសាកលវិទ្យាល័យវេស្ទើនក្នុងឆ្នាំ ២០២០នេះ បានចូលរួមធ្វើបទបង្ហាញចែករំលែកបទពិសោធន៍ជាមួយតំណាងមកពីអង្គការ Lotus Outreach នៅសាលប្រជុំសាលារៀនជំនាន់ថ្មី វិទ្យាល័យ ហ៊ុន សែន កំពង់ចាម។ ពួកគាត់មានសេចក្ដីរីករាយផ្លាស់ប្ដូរបទពិសោធន៍សិក្សា និងសមិទ្ធផលដែលពួកគាត់ទទួលបានក្នុងអំឡុងឆ្នាំ២០១៦-២០២០។

បច្ចុប្បន្ននេះ គម្រោងអាហារូបករណ៍និស្សិតកម្រិតឧត្ដមសិក្សា (CTSP) បានជួយក្មេងស្រីជំនាន់ទី៣ ចំនួន ៣០នាក់ បានបញ្ចប់ថ្នាក់បរិញ្ញាបត្រក្នុងពហុឯកទេស ដែលជាផ្នែកខិតខំប្រឹងប្រែងរបស់ខេបក្នុងការផ្ដល់សិទ្ធិអំណាចដល់ស្ដ្រី។ ក្រោមការគាំទ្រហិរញ្ញប្បទានពីអង្គការមូលនិធិអាស៊ី និងមូលនិធិ Merali។ បេក្ខជនទាំង ៣០នាក់ បានទទួលសញ្ញាបត្រពីសាកលវិទ្យាល័យវេស្ទើននៅចុងឆ្នាំ២០២០។ បើគ្មានការអន្ដរាគមន៍ពីខេបទេ បេក្ខជនទាំងអស់ដែលចេញពីគ្រួសារងាយរងគ្រោះបំផុតទាំងអស់នេះមិនអាចមានលទ្ធភាពបន្តការសិក្សានៅសាកលវិទ្យាល័យបានឡើយ។ និស្សិតអាហារូបករណ៍ដែលបញ្ចប់ការសិក្សាទទួលបានសញ្ញាបត្រជំនាន់ទី៣ រួមជាមួយជំនាន់ទី១ជាក្មេងស្រីចំនួន ៦៦នាក់ និងជំនាន់ទី២ចំនួន ៥០នាក់។ ក្មេងស្រីទាំងអស់នេះមិនត្រឹមតែទទួលបានការឧបត្ថម្ភអាហារូបករណ៍ប៉ុណ្ណោះទេ ប៉ុន្តែពួកគាត់ក៏ទទួលបានការឧបត្ថម្ភឱ្យស្នាក់នៅក្នុងអន្តេវាសិកដ្ឋានរួមគ្នាផងដែរ ដែលអាចជួយគ្នាទៅវិញទៅមក និងរៀនសូត្របន្ថែមអំពីជំនាញក្នុងការកសាងក្រុម និងភាពជាអ្នកដឹកនាំ។ តាមរយៈការសម្របសម្រួលដ៏ខ្លាំងក្លារបស់ខេបជាមួយសហគមន៍អាជីវកម្ម ខេបក៏បានជួយឱ្យបេក្ខជនទាំងអស់នេះទទួលបានការងារល្អធ្វើនៅតាមធនាគារ ស្ថាប័នមីក្រូហិរញ្ញវត្ថុ ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត និងតាមបណ្ដាស្ថាប័នរបស់រដ្ឋាភិបាលក្នុងស្រុកផងដែរ៕

---

## បេក្ខជនជាគរុនិស្សិតបរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសប្រឹក្សាគរុកោសល្យ ជំនាន់ទី១ ទទួលសញ្ញាបត្រ

ខេបបានជួយក្រសួងអប់រំ យុវជន និងកីឡា បង្កើតមជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មីនៅក្នុងឆ្នាំ២០១៩។ មជ្ឈមណ្ឌលនេះបានបើកដំណើរការនៅខែកញ្ញា ឆ្នាំ២០១៩ និងទទួលចុះឈ្មោះបេក្ខជនថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំចំនួន ២៥នាក់ ដែលត្រូវបានជ្រើសរើសយ៉ាងសម្រិតសម្រាំងក្នុងចំណោមបេក្ខជន ១៥០នាក់។ បេក្ខជនទាំងនេះបានចូលសិក្សាកម្មវិធីបណ្ដុះបណ្ដាលនៅមជ្ឈមណ្ឌល ដែលប្រើប្រាស់ការច្នៃប្រឌិតថ្មីក្នុងការសិក្សា រួមមាន៖ សិក្សាតាមអនឡាញ និងរៀនបែបសិក្ខាសាលាថ្នាក់តូចៗក្នុងអគារបំពាក់ដោយគ្រឿងបរិក្ខារទំនើបៗ។ បេក្ខជនទាំងនេះទទួលបានការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំឯកទេសប្រឹក្សាគរុកោសល្យគ្រូដំបូងគេនៅប្រទេសកម្ពុជា។ នៅក្នុងពិធីសម្ពោធមជ្ឈមណ្ឌលក្រោមអធិបតីភាព ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំយុវជននិងកីឡា។ កម្មវិធីថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសប្រឹក្សាគរុកោសល្យ មិនមែនត្រឹមតែជាកម្មវិធីប្លែកនៅកម្ពុជានោះទេ តែវាក៏ជាកម្មវិធីនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ផងដែរ។ បេក្ខជនទាំង ២៥នាក់ បានទទួលសញ្ញាបត្រនៅខែកញ្ញា ឆ្នាំ២០២០ នៅវិទ្យាស្ថានជាតិអប់រំ។ ពួកគាត់គឺជាគរុនិស្សិតជំនាន់ទី១ ដែលមិនធ្លាប់ទទួលសញ្ញាប័ត្របរិញ្ញាបត្រអប់រំជាន់ខ្ពស់ពីវិទ្យាស្ថានជាតិអប់រំ ដែលបង្កើនបានគុណភាពអប់រំជាសំខាន់។ ក្រោមការគាំទ្រហិរញ្ញប្បទានបន្តពីក្រសួងអប់រំ យុវជន និងកីឡា ខេបបានគាំទ្រមជ្ឈមណ្ឌលរៀបចំកន្លែងដល់បុគ្គលិកអប់រំថ្មី ឯកទេសប្រឹក្សាគរុកោសល្យនៅតាមសាលារៀនជំនាន់ថ្មី ចំពេលសាលារៀនជំនាន់ថ្មីកំពុងពង្រីកកំណែទម្រង់ខ្លួន។ ខេបជឿជាក់ថា ការគាំទ្ររបស់ក្រសួងដល់មជ្ឈមណ្ឌលនឹងជួយជំរុញនូវការអប់រំប្រកបដោយការច្នៃប្រឌិតថ្មីក្នុងប្រព័ន្ធអប់រំនៅក្នុងប្រទេសកម្ពុជា៕



សមាជិកគណៈកម្មការគរុនិស្សិតមជ្ឈមណ្ឌល NGPRC បានថតរូបជាមួយរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងរដ្ឋលេខាធិការក្នុងពិធីចែកសញ្ញាបត្រដល់បេក្ខជនទាំងអស់ ដែលបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសប្រឹក្សាគរុកោសល្យ។

# សាលារៀនជំនាន់ថ្មីកាន់តែមានប្រវត្តិល្បីល្បាញឡើង




កម្មវិធីសាលារៀនជំនាន់ថ្មីនៅតែជាកម្មវិធីមួយដ៏ល្អបំផុតក្នុងចំណោមកម្មវិធីល្អៗដទៃទៀតរបស់ខេប។ ជាទូទៅ ក្នុងរយៈពេលមួយឆ្នាំកន្លងមកនេះ ប្រវត្តិសាលារៀនជំនាន់ថ្មីបានបន្តរីកសុះសាយទាំងផ្នែកសារព័ត៌មាន និងការបោះពុម្ពផ្សាយក្នុងវិស័យសិក្សា។ កាលពីឆ្នាំមុន កម្មវិធីសាលារៀនជំនាន់ថ្មីត្រូវបានគេរាយការណ៍អំពីកំណែទម្រង់ដែលបានបង្ហាញនៅក្នុងការបោះពុម្ពផ្សាយ និងក្នុងសន្និសីទអន្តរជាតិជាច្រើន រួមមាន៖ ***សន្និសីទអន្តរជាតិនៃសង្គមអប់រំ(CIES)*** នៅសាន់ហ្វ្រាន់ស៊ីស្កូ។ ក្នុងឆ្នាំនេះ កំណែទម្រង់សាលារៀនជំនាន់ថ្មីត្រូវបានធ្វើវិភាគនៅក្នុងការបោះពុម្ពផ្សាយថ្មីមួយដោយធនាគារពិភពលោកដែលហៅថា ***ប្រទេសកម្ពុជាក្នុងអំឡុងពេលជំងឺកូវីដ ១៩៖ ការផ្តោតពិសេសទៅលើគុណនេយ្យភាពគ្រូបង្រៀន និងលទ្ធផលសិក្សារបស់សិស្ស***។ ការបោះពុម្ពផ្សាយនេះបានលើកឡើងនូវគំរូចំនួន ៣ នៃការលើកកម្ពស់គុណនេយ្យភាពនៅតាមសាលារៀន រួមមាន៖ គំរូសាលារៀនជំនាន់ថ្មី គំរូមូលដ្ឋានគ្រឹះគ្រប់គ្រងសាលារៀន និងសាលារៀនឯកជន។ កំណែទម្រង់សាលារៀនជំនាន់ថ្មីក៏ត្រូវបានពិពណ៌នានៅក្នុងការបោះពុម្ពផ្សាយថ្មីមួយទៀតដោយមូលនិធិ អាដេណូអ័រ ដែលជាបណ្តាញដ៏សំខាន់មួយសម្រាប់ធ្វើឱ្យមានការប្រែប្រួលការអប់រំនៅកម្ពុជា ពាក់ព័ន្ធនឹងការអប់រំដោយប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យា។ សៀវភៅថ្មីមានចំណងជើងថា ***ប្រទេសកម្ពុជាឆ្នាំ២០៤០៖ វប្បធម៌និងសង្គម***[២] បានរៀបរាប់អំពីសក្តានុពលគំរូសាលាជំនាន់ថ្មីដែលធ្វើការផ្លាស់ប្តូរប្រព័ន្ធអប់រំពីគំរូសិក្សាបែបមូលដ្ឋានទៅជាការសិក្សាមួយដែលធ្វើឱ្យដំណើរសិក្សាមានកម្រិតខ្ពស់ជាងមុន។

កម្មវិធីសាលារៀនជំនាន់ថ្មីមានសមត្ថភាពទាក់ទាញចំណាប់អារម្មណ៍អ្នកសិក្សា ក៏ដូចជាដៃគូអភិវឌ្ឍន៍ជាច្រើនតាមរយៈសមិទ្ធផលកម្មវិធីរបស់ខ្លួន។ ការពង្រីកឯកសារផ្សព្វផ្សាយទូលំទូលាយរបស់កម្មវិធីសាលារៀនជំនាន់ថ្មី រួមទាំងផ្នែកបច្ចេកទេសទៀតផងនឹងផ្តល់នូវរចនាសម្ព័ន្ធ ដែលជាសក្ខីភាពមូលដ្ឋានសម្រាប់ចម្លងគំរូកម្មវិធីសាលារៀនជំនាន់ថ្មីទៅប្រើប្រាស់ក្នុងប្រទេសដទៃៗទៀតនាពេលអនាគត៕




# គេហទំព័រសម្រាប់សាលារៀនជំនាន់ថ្មី និងមជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មីមាននៅលើអនឡាញ

នៅចុងឆ្នាំនេះ ខេបបានបើកដំណើរការគេហទំព័រថ្មីសម្រាប់មជ្ឈមណ្ឌលស្រាវជ្រាវជំនាន់ថ្មី (NGPRC) និងប្រព័ន្ធសាលារៀនជំនាន់ថ្មីដែលគ្រប់គ្រងដោយមជ្ឈមណ្ឌលផ្ទាល់។ គេហទំព័ររបស់មជ្ឈមណ្ឌល **NGPRC** មានអាសយដ្ឋានដូចខាងក្រោម: **(https://www.ngprc.edu.kh/)** ដែលជួយពន្លឿនកម្មវិធីបណ្តុះបណ្តាលគ្រូរបស់មជ្ឈមណ្ឌលទៅជាទម្រង់និម្មិត (អនឡាញ) ហើយក្នុងនោះក៏មានបញ្ចូលទាំងការចុះឈ្មោះតាមអនឡាញផងដែរ។ គេហទំព័រនេះនឹងជួយឱ្យមជ្ឈមណ្ឌលបន្តប្រតិបត្តិកម្មវិធីបណ្តុះបណ្តាលតាមអនឡាញដោយគ្មានការរំខាន អំឡុងពេលដែលវិទ្យាស្ថានជាតិអប់រំនៅតែបិទទ្វារនៅឡើយដោយសារការរីករាលដាលជំងឺកូវីដ ១៩។ ទន្ទឹមនឹងនេះ គេហទំព័រសាលារៀនជំនាន់ថ្មីនឹងអាចឱ្យគ្រូ និងភាគីផ្សេងៗទៀតអាចដាក់ពាក្យផ្ទាល់ទៅរដ្ឋបាលសាលារៀនជំនាន់ថ្មីដើម្បីស្នើសុំបម្រើការងារ និងអាចឱ្យសិស្សចុះឈ្មោះចូលប្រឡងតាមអេឡិចត្រូនិកបានផងដែរ។ ទាំងសាធារណៈជនទូទៅ និងសមាជិករដ្ឋាភិបាលក៏អាចចូលប្រើប្រាស់ធនធានអប់រំទាំងអស់ ដែលផលិតដោយសាលារៀនជំនាន់ថ្មីបានយ៉ាងលឿនរហ័ស និងមានប្រសិទ្ធភាព រួមមាន៖ របាយការណ៍ស្តីពីសមិទ្ធផលកម្មវិធី ឯកសារគោលនយោបាយ សៀវភៅបច្ចេកទេស ធនាគារសំណួរ ឯកសារប្រវត្តិកម្មវិធី និងធនធានអប់រំដទៃៗទៀត៕

[2] https://www.kas.de/documents/264850/9494366/Cambodia+2040+Culture+and+Society.pdf/2d86a754-1708-ca31-d78f-e70ac7b19aac?version=1.0&t=1593966925445

# ការបោះពុម្ពផ្សាយសៀវភៅថ្មីរបស់អង្គការ ខេប




ខេបពិតជាមានផលិតភាពយ៉ាងខ្លាំងអំឡុងឆ្នាំ២០២០នេះ ពាក់ព័ន្ធនឹងការជួយដល់ក្រសួងអប់រំ យុវជន និងកីឡាក្នុងការបោះពុម្ពសៀវភៅថ្មីៗមានលក្ខណៈប្លែក និងភាពច្នៃប្រឌិតខ្ពស់។ ក្នុងនោះរួមមាន៖ រចនាបថហេដ្ឋារចនាសម្ព័ន្ធបណ្ណាល័យសតវត្សរ៍ទី២១ ឯកសារវាយតម្លៃសិស្ស ឯកសារមគ្គុទ្ទេសក៍សិក្សាជំនាន់ថ្មី និងឯកសារអភិវឌ្ឍន៍គោលនយោបាយ។ ***សៀវភៅបណ្ណាល័យសតវត្សរ៍ទី២១*** ត្រូវបានខេបបង្កើតឡើងតាមសំណើរបស់ក្រសួង ហើយបច្ចុប្បន្ននេះ ត្រូវបានបញ្ចប់និងបោះពុម្ពរួចរាល់ ខណៈដែលការបោះពុម្ពសៀវភៅគោលការណ៍ណែនាំស្ថាបត្យកម្មត្រូវបានប្រើប្រាស់នៅក្នុងកម្មវិធីសាលារៀនជំនាន់ថ្មី។

សៀវភៅស្ថាបត្យកម្មជាភាសាអង់គ្លេសបានបោះពុម្ពចេញជាសៀវភៅរួច សម្រាប់ភាសាខ្មែរនឹងត្រៀមបោះពុម្ពក្នុងឆ្នាំ២០២១ខាងមុខនេះ។ ឯកសារថ្មីនេះមានឈ្មោះថា ***ស្ថាបត្យកម្មសាលារៀនសម្រាប់សតវត្សរ៍ថ្មី*** ហើយសង្ឃឹមថាសៀវភៅនេះនឹងមិនត្រឹមតែគាំទ្រដល់ការបង្កើតបរិស្ថានសិក្សាសាលារៀនជំនាន់ថ្មីប៉ុណ្ណោះទេ ប៉ុន្តែក៏អាចយកទៅប្រើប្រាស់នៅក្នុងគម្រោងអភិវឌ្ឍន៍ផ្សេងៗទៀតដែរ។ សៀវភៅនេះគឺជាការខិតខំប្រឹងប្រែងចង្អុលបង្ហាញក្នុងប្រព័ន្ធអប់រំនៅប្រទេសកម្ពុជា ដើម្បីប្រើប្រាស់រចនាបថស្តង់ដាសាលារៀននៅក្នុងរយៈពេល ៧០ឆ្នាំចុងក្រោយ ហើយក៏ជារចនាបថមិនហួសពីតម្រូវការការអប់រំក្នុងបច្ចុប្បន្ននេះឡើយ។ ការបោះពុម្ពសៀវភៅបានតែចំនួន ២០០ច្បាប់ គឺនៅមានកម្រិតនៅឡើយ ហើយឯកសារទន់ (**Soft Version**) អាចទាញយកបានពីគេហទំព័រសាលារៀនជំនាន់ថ្មី។




នៅក្នុងការបោះពុម្ពសៀវភៅស្ថាបត្យកម្មថ្មីនេះបានផ្តល់នូវគោលការណ៍ណែនាំជាច្រើនសម្រាប់កំណត់ទីតាំងសិក្សាដោយប្រើប្រាស់គោលការណ៍ស្ថាបត្យកម្មសាលារៀនទំនើប និងរួមទាំងករណីសិក្សាជាច្រើននៅក្នុងប្រទេសកម្ពុជា ការកសាងប្លង់ប៉ាន់គំរូ ការសន្មត់តម្លៃសាងសង់ និងអនុសាសន៍សម្រាប់ទិសដៅអនាគតក្នុងការរចនាសាលារៀននៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ឯកសារជាភាសាអង់គ្លេសត្រូវបានបោះពុម្ពផ្សព្វផ្សាយរួចហើយ សម្រាប់ភាសាខ្មែរនឹងត្រូវបោះពុម្ពក្នុងឆ្នាំ២០២១៕

## ខេបសម្ពោធន៍គម្រោងថ្មីគាំទ្រដោយសហគមន៍អឺរ៉ុប

ជាលើកដំបូងហើយក្នុងប្រវត្តិសាស្ត្ររបស់ខេប ដែលបានដាក់ដេញថ្លៃគម្រោងថ្មីដោយជោគជ័យក្នុងនាមជាអង្គការដឹកនាំគម្រោងដែលគាំទ្រហិរញ្ញប្បទានពីសហគមន៍អ៊ឺរ៉ុប។ គម្រោងថ្មីនេះមានឈ្មោះថា ***គម្រោងលើកកម្ពស់ការអប់រំ និងការងារនៅកម្ពុជា (SEEK)*** ដោយបានចាប់ផ្តើមដំណើរការនៅខែមីនា ឆ្នាំ២០២០ (សូមមើលរូបភាព) ហើយនឹងគាំទ្រដល់យុវជនកម្ពុជារាប់ម៉ឺននាក់ក្នុងការរកបានការងារមានប្រយោជន៍។ គម្រោងនេះផ្តោតលើការពង្រឹងទាំងការអប់រំក្នុងប្រព័ន្ធ និងការបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីជួយរដ្ឋាភិបាលបង្កើនការអប់រំមានភាពទាក់ទងសម្រាប់យុវជន។ ខេបមានពហុដៃគូសម្រាប់ប្រតិបត្តិគម្រោងនេះ រួមមាន៖ **អង្គការវីវើល-GVC អង្គការសកម្មភាពពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍សង្គម (BSDA) និងអង្គការក្រុមប្រឹក្សាយុវជនកម្ពុជា (YCC)**៕



# ក្រុមហ៊ុន ធីធីអូ អ៊ីមផត អិចផត ឯ.ក

*“សម្ភារៈជំនួយការសិក្សាដែលមានប្រសិទ្ធភាព និងតម្លៃសមរម្យ ”*



***សកម្មភាពទីផ្សារ:*** *TTO បានផ្សព្វផ្សាយផលិតផលអំឡុងពេលកម្មវិធីពិព័រណ៍សៀវភៅថ្នាក់ជាតិនៅរាជធានីភ្នំពេញ។ សម្ភារជំនួយការរៀន និងបង្រៀនប្រកបដោយគំនិតច្នៃប្រឌិតថ្មីទាក់ទាញសិស្ស និស្សិត កុមារ ជនបរទេស យុវជន និងអ្នកពាក់ព័ន្ធចូលទិញ។*

ព័ត៌មានលម្អិតមាននៅលើគេហទំព័រTTO: **www.tts-kape.org** និងសូមចុច “**Like**” និងចុច “**Share**” បណ្ដាញសង្គម **Facebook** របស់យើង: **www.facebook.com/ttskape**។

## សេចក្ដីសង្ខេប

### អំពីយើង

ធីធីអូជាក្រុមហ៊ុនក្នុងស្រុក ផលិតនិងចែកចាយសម្ភារបង្រៀន និងរៀនទាំងក្នុងនិងក្រៅថ្នាក់។

### ផលិតផល

**សម្ភារបង្រៀនរួមមានៈ**

- ល្បែងសិក្សាគណិតវិទ្យា **២៤ (បឋម)**
- ល្បែងសិក្សាគណិតវិទ្យា **១៣ (មធ្យម)**
- ល្បែងសិក្សាភាសា **៣២**
- ល្បែងសិក្សាវិទ្យាសាស្ត្រ **២**
- ទម្រង់វាយតម្លៃអំណាន **៣ កម្រិត**

### ទទួលស្គាល់

ផលិតផលទទួលស្គាល់ និងបានប្រកាសអនុញ្ញាតបោះពុម្ពផ្សាយដោយក្រសួងអប់រំយុវជននិងកីឡា។






***ការងារសង្គម:*** *TTO បានផ្ដល់សម្ភារសម្រាប់ការពារជំងឺកូវីដ១៩ រួមទាំងសម្ភារជំនួយការរៀននៅផ្ទះក្នុងអំឡុងពេលសាលារៀនកំពុងបិទទ្វារ។*

# ខេបអនុវត្តកម្មវិធីអប់រំច្រើនផ្នែកតាមបច្ចេកទេស



ប៉ុន្មានឆ្នាំកន្លងមកនេះ ខេបទទួលបានជោគជ័យក្នុងការងារបច្ចេកទេសដែលមានលក្ខណៈខុសប្លែកពីគ្នាជាច្រើនស្របតាមផែនការយុទ្ធសាស្ត្ររបស់ខ្លួន។ ដំបូងឡើយ ខេបបានវិនិយោគតែលើពីរផ្នែកប៉ុណ្ណោះ គឺ ***ការអភិវឌ្ឍគ្រូបង្រៀន*** និង ***កម្មវិធីអប់រំបរិយាប័ន្ន***។ អំឡុងពេលយុទ្ធសាស្ត្រទាំងពីរនេះរក្សាបាននូវការវិនិយោគកម្រិតខ្ពស់បំផុតផ្អែកលើជំនាញរបស់ខេប ខេបក៏បានបញ្ចូលជំនាញចំនួន៨ផ្នែកទៀតដែលមានរៀបរាប់ក្នុងតារាងខាងក្រោម។ ភាពស៊ីសង្វាក់គ្នាទៅនឹងផែនការយុទ្ធសាស្ត្រ (២០១៤-២០១៩) ខេបបានបង្កើនឱ្យមានជំនាញបច្ចេកទេសប្លែកៗពីគ្នាក្នុងកម្មវិធីជាច្រើន។ ផែនការយុទ្ធសាស្ត្រថ្មីដែលនឹងត្រូវចេញផ្សាយនៅឆ្នាំ២០២១ នឹងធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្ររបស់ខេបគ្រប់ផ្នែកបច្ចេកទេសទាំងអស់។

***កម្មវិធីឆ្លើយតបការអប់រំក្នុងបរិបទកូវីដ ១៩*** គឺជាជំនាញយុទ្ធសាស្ត្រវិនិយោគថ្មីមួយសម្រាប់ខេប ដែលពិតជាជះឥទ្ធិពលដល់គម្រោងភាគច្រើនបំផុត។ ទោះបីជាយ៉ាងណាក៏ដោយ គម្រោងថ្មីនេះគាំទ្រហិរញ្ញប្បទានដោយអង្គការយូនីសេហ្វ-គាំទ្រដោយភាពជាដៃគូសកលដើម្បីការអប់រំ (UNICEF-GPE3) ផ្តោតការគាំទ្រទាំងស្រុងដល់ក្រសួងអប់រំ យុវជន និងកីឡាតាមរយៈជំនួយបច្ចេកទេសក្នុងការសម្របសម្រួលកម្មវិធីឆ្លើយតបការអប់រំជាមួយនាយកដ្ឋាន និងដៃគូអភិវឌ្ឍន៍ជាច្រើនទៀត។ ទន្ទឹមនឹងនេះដែរ ***ព័ត៌មានវិទ្យា ទំនាក់ទំនង និងបច្ចេកវិទ្យាសម្រាប់ការអប់រំ*** និង ***កម្មវិធីអប់រំបំណិនជីវិត*** ក៏ជាជំនាញបច្ចេកទេសដែលទទួលបានការវិនិយោគក្នុងកម្រិតខ្ពស់ពីពហុគម្រោងផងដែរ។

ខាងក្រោមនេះគឺជាការពន្យល់អំពីយុទ្ធសាស្ត្រតាមផ្នែកបច្ចេកទេស ថាតើផ្នែកបច្ចេកទេសនីមួយៗផ្សារភ្ជាប់ជាមួយគម្រោងបច្ចុប្បន្នរបស់ខេបណាខ្លះ។

## ការរៀបចំមុខងារគម្រោងរបស់ខេបតាមផ្នែកបច្ចេកទេសក្នុងឆ្នាំ២០២០

| គម្រោងខេបក្នុងឆ្នាំ២០២០ | ពាក្យបំព្រួញ | ការអភិវឌ្ឍសាលារៀន ធនធាន | ICT សម្រាប់ការអប់រំ | ការអភិវឌ្ឍគ្រូបង្រៀន | កម្មវិធីអប់រំបរិយាប័ន្ន | កម្មវិធីអំណានថ្នាក់ដំបូង | កម្មវិធីមតេយ្យសិក្សា | រចនាបថហេដ្ឋារចនា សម្ព័ន្ធ | ការអភិវឌ្ឍយុវវ័យ | កម្មវិធីបំណិនជីវិត និង ប្រឹក្សាអាជីព | កម្មវិធីឆ្លើយតបលើវិស័យ អប់រំក្នុងបរិបទកូវីដ១៩ |
|---|---|---|---|---|---|---|---|---|---|---|---|
| ១. គម្រោង សៀវភៅសម្រាប់កម្ពុជា (BfC) | BfC | | | | | | | | ✓ | | |
| ២. គម្រោង អាហារូបករណ៍និស្សិតកម្រិតឧត្តមសិក្សា | CTSP | | | | ✓ | | | | | | ✓ |
| ៣. កម្មវិធីឆ្លើយតប និងស្តារឡើងវិញនូវវិស័យអប់រំក្នុងបរិបទជំងឺកូវីដ ១៩ | CERRP | | ✓ | ✓ | ✓ | ✓ | | | | | ✓ |
| ៤. គម្រោងអប់រំកុមារី | GEI | | | | ✓ | | | | | ✓ | ✓ |
| ៥. គម្រោង វាយតម្លៃ-GPE3 (តេស្ត EGRA) | GPE3-PE | | | | | ✓ | | | | | |
| ៦. គម្រោង កុមារកម្ពុជារីករាយ | HCC | | | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| ៧. គម្រោង សកម្មភាពយុវជនវ័យក្មេងនៅកម្ពុជា | KYLA | | | | ✓ | | | | | ✓ | |
| ៨. គម្រោង អប់រំបំណិនជីវិតសម្រាប់កុមារី | LSLAG | | | | ✓ | | | | | ✓ | |
| ៩. មជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី | NGPRC | ✓ | ✓ | ✓ | | | | | | | ✓ |
| ១០.គម្រោង សាលារៀនជំនាន់ថ្មី (កម្រិតបឋម) | NGS-P | ✓ | ✓ | ✓ | ✓ | ✓ | | ✓ | ✓ | ✓ | ✓ |
| ១១.គម្រោង សាលារៀនជំនាន់ថ្មី (កម្រិតមធ្យម) | NGS-S | ✓ | ✓ | ✓ | ✓ | | | ✓ | ✓ | ✓ | ✓ |
| ១២.គម្រោង សាលារៀនជំនាន់ថ្មី/ស្វាយរៀង | NGS-SR | ✓ | ✓ | ✓ | ✓ | | | ✓ | ✓ | ✓ | ✓ |
| ១៣.គម្រោង ពន្លកចំណេះ (ស្រាវជ្រាវប្រឹក្សាគរុកោសល្យ) | PC | | | ✓ | | | | | | | |
| ១៤.គម្រោង បរិស្ថានសិក្សាប្រកបដោយគុណភាព | QLE | | | ✓ | ✓ | ✓ | | | | | ✓ |
| ១៥.គម្រោង បង្កើនភាពងាយស្រួលចូលសាលារៀនតាមរយៈការគាំទ្រពីសហគមន៍ | REACH III | | | ✓ | ✓ | ✓ | ✓ | | ✓ | ✓ | ✓ |
| ១៦.គម្រោង លើកកម្ពស់ការអប់រំ និងការងារនៅកម្ពុជា | SEEK | | | ✓ | ✓ | | | | | ✓ | ✓ |
| ១៧.គម្រោង លើកកម្ពស់ការឆ្លើយតបនឹងសមភាពយេនឌ័រក្នុងការបង្រៀន និងរៀន | TIGER | | ✓ | | ✓ | | | | | ✓ | |
| ១៨.គម្រោង វិធីសាស្ត្រសរុបដើម្បីពង្រឹងអំណានសម្រាប់កុមារ | TRAC III | | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | | ✓ |
| ១៩.គម្រោង អភិវឌ្ឍន៍វិស័យអប់រំ-មធ្យមសិក្សា ២ | USE-SDP2 | | ✓ | ✓ | | | | ✓ | ✓ | ✓ | |
| ២០.គម្រោង សហគ្រិនវ័យក្មេង | YEP | | | | ✓ | | | | | ✓ | ✓ |
| **សរុបគម្រោងកំពុងដំណើរការក្នុងផ្នែកនីមួយៗ** | | ៤ | ៨ | ១២ | ១៥ | ៧ | ៣ | ៦ | ៨ | ១២ | ១៣ |

# ការអភិវឌ្ឍសាលារៀនធម្មនុញ្ញ

*"បង្កើតសាលារដ្ឋជាមួយនឹងស្តង់ដាសាលារៀនឯកជន"*

## ព័ត៌មានសំខាន់ខ្លីៗអំពីការអភិវឌ្ឍសាលារៀនធម្មនុញ្ញ

| | | |
|---|---|---|
| ចំនួនគម្រោង | ៤ | |
| ដៃគូអភិវឌ្ឍន៍សំខាន់ៗ | ក្រសួងអប់រំ យុវជន និងកីឡា<br>មូលនិធិគ្រួសារត្រកូលហ្វ្រេងស៍ | អង្គការឆាលហ្វាន |
| កាលបរិច្ឆេទវិនិយោគ | ២០១១ | |
| ប្រធានបទសំខាន់ៗក្នុងការវិនិយោគ | • ការវិនិយោគពហុបទ<br>• គណនេយ្យភាពអនុវត្តដោយការទទួលស្គាល់គុណភាពដែលមានកម្រិតខ្ពស់<br>• ការវិនិយោគលើកម្មវិធីស្ទែម និង ICT សម្រាប់ការអប់រំមានកម្រិតខ្ពស់<br>• រចនាបថអប់រំទំនើប<br>• ការប្រឹក្សាគរុកោសល្យមូលដ្ឋាន<br>• ការលើកទឹកចិត្តផ្អែកលើការអនុវត្តជាក់ស្តែង<br>• មូលនិធិសមធម៌សង្គមដើម្បីធានាថា សិស្សក្រីក្រអាចចូលទៅសិក្សានៅសាលារៀនជំនាន់ថ្មីបាន។ | |

## តារាងរង្វាស់ការអនុវត្តសំខាន់ៗនៃកម្មវិធីសាលារៀនជំនាន់ថ្មី (NGS) កម្រិតមធ្យម (២០១៩-២០២០)

| *រង្វាស់ (Metric)* | *NGS* | *ថ្នាក់ជាតិ* |
|---|---|---|
| អត្រាប្រឡងជាប់មធ្យមសិក្សាទុតិយភូមិ៖ | ៩១%[3] | ៦៨% |
| សិស្សមធ្យមសិក្សាទុតិយភូមិប្រឡងជាប់និទ្ទេស A, B ឬ C៖ | ៣៥% | ៨% |
| សិស្សបន្តសិក្សានៅសាកលវិទ្យាល័យ៖ | ៨៨% | ១៣,៧%* |
| សិស្សទទួលបានមេដៃ/ពានរង្វាន់៖ | ៦១២ | មិនមាន |
| សិស្សសិក្សា ICT ចំនួន ៣ម៉ោងក្នុង ១សប្តាហ៍ ឬច្រើនជាងនេះ៖ | ១០០% | ០% |
| អត្រាធ្លាក់៖ | ៤% | បឋមភូមិ:១៦%<br>ទុតិយភូមិ: ១៧% |
| សាលាមធ្យមសិក្សាដែលបានទទួលស្គាល់គុណភាព៖ | ៨៣% | មិនមាន |
| គ្រូសាលាមធ្យមសិក្សាដែលមានសញ្ញាបត្របរិញ្ញាបត្រ ឬកម្រិតខ្ពស់ជាងនេះ៖ | ៨៦% | ៤៣% |
| គ្រូបង្រៀនដែលបំពេញផែនការអាជីព៖ | ៩៨% | មិនមាន |
| គម្រោងរបស់សិស្សដែលបានបំពេញក្នុងមួយឆ្នាំ៖ | គម្រោង ៤៩០ (គម្រោង១ សិស្ស ៦នាក់) | មិនមាន |

** ការចុះឈ្មោះចូលរៀនសរុប (ថ្នាក់ឧត្តមសិក្សា)*



## សេចក្តីសង្ខេប:

ខេបបានចាប់ផ្តើមបង្កើតសាលារៀនធម្មនុញ្ញជាយុទ្ធសាស្ត្រអភិវឌ្ឍន៍មួយចាប់តាំងពីឆ្នាំ២០១១មក ដោយមានគោលបំណងបំបែករដ្ឋដែលបង្កើតឡើងដោយវិធីសាស្ត្រអភិវឌ្ឍន៍របស់ម្ចាស់ជំនួយទ្វេភាគី និងពហុភាគីក្នុងការបែងចែកជាកម្រិតទាបបំផុត។ វិធីសាស្ត្រនេះធ្វើឱ្យមូលដ្ឋានធនធានមនុស្សថមថយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលបណ្តាលឱ្យកំណែទម្រង់អប់រំចុះខ្សោយ។ លទ្ធផលនេះនាំទៅរកដំណើរការចុះឡើងមួយដែលប្រទេសកម្ពុជាមិនអាចអនុវត្តកំណែទម្រង់អប់រំប្រកបដោយមហិច្ឆតាបាន ព្រោះខ្វះធនធានមនុស្សប្រកបដោយគុណភាពខ្ពស់ ហើយបើកំណែទម្រង់អនុវត្តមិនសូវបានល្អ ប្រទេសកម្ពុជានៅតែខ្វះធនធានមនុស្សយ៉ាងខ្លាំង។ ការវិនិយោគសាលារៀនធម្មនុញ្ញត្រូវការវិធីសាស្ត្ររយៈពេលយូរអង្វែងក្នុងការអភិវឌ្ឍ ដើម្បីបង្កើតមូលដ្ឋានធនធានមនុស្សប្រកបដោយគុណភាពខ្ពស់ដែលនឹងធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធអប់រំយ៉ាងឆាប់រហ័សក្នុងប្រទេសកម្ពុជា។ ការបង្កើតសាលារៀនធម្មនុញ្ញតម្រូវឱ្យមានវិធីសាស្ត្រវិនិយោគខ្ពស់នៅក្នុងការជ្រើសរើសសាលារៀន ដែលមានការទទួលខុសត្រូវចំពោះការអនុវត្តយ៉ាងតឹងរ៉ឹង។ ការប្រព្រឹត្តអំពើពុករលួយ ដូចជា ការបើកបង្រៀនគួរត្រូវតែលុបបំបាត់ចោលយ៉ាងម៉ឺងម៉ាត់ និងជំនួសមកវិញនូវវិធីសាស្ត្រវិជ្ជាជីវៈបន្ថែមទៀតចំពោះការអប់រំសម្រាប់សិស្សគ្រប់ស្រទាប់វណ្ណៈទាំងអស់។

## ការអភិវឌ្ឍក្នុងបច្ចុប្បន្នភាព:

ការអភិវឌ្ឍសាលារៀនធម្មនុញ្ញត្រូវបានធ្វើឡើងក្រោមគម្រោងផ្សេងគ្នាមួយចំនួនដែលគាំទ្រនូវអ្វីដែលគេស្គាល់ថា***សាលារៀនជំនាន់ថ្មី***។ សាលារៀនទាំងនេះត្រូវបានកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡាជាសាលារៀនធម្មនុញ្ញនៅកម្ពុជា។ ខេបបានប្រើប្រាស់ហិរញ្ញប្បទានពីក្រសួងអប់រំ យុវជន និងកីឡាដល់ឆ្នាំទី៥ហើយ ក្នុងការគាំទ្រកំណែទម្រង់សាលារៀនជំនាន់ថ្មីនៅក្នុងសាលារៀនចំនួន១០ ក្នុងខេត្តទាំង៥ កាន់តែមានភាពរឹងមាំខ្លាំងឡើង។ បច្ចុប្បន្ននេះ ក្រសួងអប់រំ យុវជន និងកីឡាបានអនុម័តផ្តល់ហិរញ្ញប្បទានចំនួន ១,៨លានដុល្លារក្នុងជុំទី៦(ឆ្នាំទី៦) ដែលរួមបញ្ចូលទាំងហិរញ្ញប្បទានសម្រាប់មជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មីនៅក្នុង វិទ្យា-ស្ថានជាតិអប់រំ ដែលបានក្លាយជាយុទ្ធសាស្ត្របន្ថែមដល់កម្មវិធីសាលារៀនជំនាន់ថ្មីដើម្បីពង្រឹងការជ្រើសរើសធនធានមនុស្សមានគុណភាពខ្ពស់។ ក្នុងពេលថ្មីៗនេះ ក្រសួងអប់រំ យុវជន និងកីឡាបានបង្ហាញអំពីបំណងពង្រីកកម្មវិធីសាលារៀនជំនាន់ថ្មីឱ្យបានចំនួន ១៥សាលាផ្សេងទៀតចាប់ពីឆ្នាំ២០២២ទៅ។



*↑ សិស្សសាលារៀនជំនាន់ថ្មីសិក្សានៅក្នុងអាគារប្រជុំទំនើប។*
*← សាលារៀនជំនាន់ថ្មីមានអគារវិទ្យាសាស្ត្រទំនើប ដែលត្រូវបានគ្រូប្រើប្រាស់យ៉ាងសកម្ម។*

[3] *គួរកត់សម្គាល់ថា សិស្សសាលារៀនជំនាន់ថ្មីទាំងអស់បានចុះឈ្មោះចូលសិក្សាស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រ មានអត្រាប្រឡងមធ្យមសិក្សាទុតិយភូមិជាប់ត្រឹមតែប្រមាណជា ៥០%ប៉ុណ្ណោះ បើប្រៀបធៀបនឹងសិស្សដែលបានចុះឈ្មោះសិក្សាស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រសង្គមគឺមានអត្រាប្រឡងជាប់ប្រមាណជា ៨០%។*

# ព័ត៌មានវិទ្យា ទំនាក់ទំនង និងបច្ចេកវិទ្យាសម្រាប់ការអប់រំ (ICT)

*“បច្ចេកវិទ្យានឹងមិនអាចជំនួសគ្រូដ៏ឆ្នើមៗបានទេ ប៉ុន្តែគ្រូឆ្នើមៗ ក៏មិនអាចអត់បច្ចេកវិទ្យាសម្រាប់ផ្លាស់ប្តូរដែរ”*

**ព័ត៌មានសំខាន់ខ្លីៗអំពី ICT សម្រាប់ការអប់រំ**

| | | |
|---|---|---|
| ចំនួនគម្រោង | ៨ | |
| ដៃគូអភិវឌ្ឍន៍សំខាន់ៗ | ក្រសួងអប់រំ យុវជន និងកីឡា<br>មូលនិធិគ្រួសារត្រកូលហ្រ្វេងស៍<br>មូលនិធិហ្វីនិក្ស៍ ធនាគារអភិវឌ្ឍន៍អាស៊ី | អង្គការយូនីសេហ្វ<br>អង្គការវីវីអូប៊ី<br>អង្គការឆាលហ្វាន |
| កាលបរិច្ឆេទវិនិយោគ | ២០០៨ | |
| ប្រធានបទសំខាន់ៗក្នុងការវិនិយោគ | ផែនការយុទ្ធសាស្ត្រព័ត៌មានវិទ្យា ទំនាក់ទំនង និងបច្ចេកវិទ្យារបស់ខេបដើម្បីលើកម្ពស់ការវិនិយោគ មានដូចខាងក្រោម៖<br>• ការអភិវឌ្ឍសុសវែរអប់រំ និងទម្រង់អេឡិចត្រូនិកដទៃៗទៀត (សូមមើលនៅទំព័រកម្មវិធីអំណានថ្នាក់ដំបូង)<br>• វេទិកាផ្តល់ការប្រឹក្សាតាមប្រព័ន្ធអេឡិចត្រូនិក (ត្រីវិស័យ)<br>• សុសវែរប្រឹក្សាគរុកោសល្យគ្រូ (អុបសើវីក)<br>• ការបំពាក់បច្ចេកវិទ្យា Thin Client នៅបន្ទប់កុំព្យូទ័រ<br>• ការផ្លាស់ប្តូរសេវាកម្មសិក្សាតាមទូរសព្ទដៃនៅបណ្ណាល័យបឋមសិក្សា និងមធ្យមសិក្សា<br>• តេស្តតាមប្រព័ន្ធអេឡិចត្រូនិក/ធនាគារសំណួរ<br>• ការផ្លាស់ប្តូររចនាសម្ព័ន្ធគ្រប់គ្រងសាលាតាមប្រព័ន្ធអេឡិចត្រូនិក<br>• ការផ្លាស់ប្តូរទម្រង់ពង្រីកអំណានភាសាអង់គ្លេស (**X-Reading**)<br>• ការសិក្សាតាមអនឡាញ និងការសិក្សារួមបញ្ចូលគ្នា<br>• ការអភិវឌ្ឍកម្មវិធីសិក្សាសរសេរកូដដោយសហការជាមួយនាយកដ្ឋានព័ត៌មានវិទ្យា | |
| ចំណុចសំខាន់ៗ | **បន្ទប់កុំព្យូទ័រដែលបានតម្លើងតាំងពីឆ្នាំ២០០៩**: មានការតម្លើងបន្ទប់កុំព្យូទ័រចំនួន ១៦១ បន្ទប់នៅសាលាមធ្យមសិក្សា។ | |
| | **បណ្ណាល័យដែលបំពាក់ការសិក្សាតាមទូរសព្ទដៃតាំងពីឆ្នាំ ២០១៥**: បណ្ណាល័យដែលមានសមត្ថភាពបំពាក់ការសិក្សាតាមទូរសព្ទដៃចំនួន ៥២កន្លែង ត្រូវបានបង្កើតឡើងទាំងនៅកម្រិតបឋមសិក្សា និងមធ្យមសិក្សា។ | |
| | **កម្មវិធីបណ្តុះបណ្តាលនិម្មិត ( កម្មវិធីបណ្តុះបណ្តាលពីចម្ងាយ )**៖ កម្មវិធីបណ្តុះបណ្តាលរបស់មជ្ឈមណ្ឌល NGPRC គឺជាកម្មវិធីបណ្តុះបណ្តាលដំបូងគេបង្អស់របស់ប្រទេសកម្ពុជា ដែលត្រូវបានធ្វើការផ្លាស់ប្តូរទៅជាទម្រង់និម្មិតទាំងស្រុង។ | |




↑ *ឧទាហរណ៍គំរូប្រព័ន្ធវិភាគសំណួរតេស្ត ដែលត្រូវបានបង្កើតឡើងសម្រាប់សាលារៀននីមួយៗ។ គំរូខាងលើនេះមានន័យថា៖ (១) ផែនការតេស្ត (២) តេស្តគំរូ (៣) ពិន្ទុក្រុមសមត្ថភាពខ្ពស់ (4) ពិន្ទុក្រុមសមត្ថភាពទាប (៥) លទ្ធផលវិភាគតេស្ត និង (៦) បង្ហាញសំណួរពេញ។ ទិន្នន័យពីសកម្មភាពវិភាគតេស្តពីសាលារៀននីមួយៗនឹងបញ្ចូលទៅក្នុងធនាគារសំណួរ ដែលសាលារៀនទាំងអស់អាចចូលទៅទាញយកពីក្នុងប្រព័ន្ធ ដើម្បីធានាថាការអភិវឌ្ឍន៍តេស្តមានសុពលភាពបំផុត។*

## សេចក្តីសង្ខេប

ខេបបានធ្វើការវិនិយោគផ្នែកព័ត៌មានវិទ្យា ទំនាក់ទំនង និងបច្ចេកវិទ្យាផ្តោតជាសំខាន់ទៅលើការផ្លាស់ប្តូរបន្ទប់កុំព្យូទ័រនៅកម្រិតមធ្យមសិក្សា ដែលជាផ្នែកមួយនៃ*គម្រោងកែលម្អកម្រិតអប់រំមូលដ្ឋាននៅកម្ពុជា* ដែលគាំទ្រហិរញ្ញប្បទានដោយ USAID (២០០៩-១៤)។ កម្មវិធីខេបនៅក្នុងផ្នែកនេះបានពង្រីកច្រើនទៅជាផ្នែកថ្មីៗទាំងកម្រិតបឋមសិក្សា និងមធ្យមសិក្សា។ ម្យ៉ាងវិញទៀត ចំនួនកម្មវិធីលើកកម្ពស់ផ្នែកព័ត៌មានវិទ្យា ទំនាក់ទំនង និងបច្ចេកវិទ្យាសម្រាប់ការអប់រំកាន់តែមានភាពជឿនលឿន ពង្រីកបានការវិនិយោគច្រើនផ្នែកក្រោមប្រធានបទជាច្រើន (សូមមើលព័ត៌មានសំខាន់ខ្លីៗអំពី ICT នៅប្រអប់ខាងឆ្វេង)។

## ការអភិវឌ្ឍក្នុងបច្ចុប្បន្នភាព

**ការសិក្សាតាមអនឡាញ៖** ការរីករាលដាលជំងឺកូវីដ ១៩ បានធ្វើឱ្យខេបជំរុញការវិនិយោគផ្នែកព័ត៌មានវិទ្យា ទំនាក់ទំនង និងបច្ចេកវិទ្យាកាន់តែខ្លាំង។ រយៈពេលមួយឆ្នាំកន្លងមក ជំនួយហិរញ្ញប្បទានក្រសួងអប់រំ យុវជន និងកីឡាសម្រាប់វិនិយោគសាលារៀនជំនាន់ថ្មី ត្រូវបានប្រើប្រាស់ធ្វើការផ្លាស់ប្តូរសាលារៀនទាំងអស់ធ្វើកម្មវិធីសិក្សាតាមអនឡាញ។ គ្រូបង្រៀននៅគ្រប់ប្រព័ន្ធសាលារៀនជំនាន់ថ្មីនៅកម្រិតមធ្យមសិក្សាបានផលិតវីដេអូមេរៀនចំនួន ៤.១៨០ក្លីប និងកម្រិតបឋមសិក្សាផលិតបាន ២៧៦ក្លីប ក្នុងអំឡុងពេលការរីករាលដាលជំងឺកូវីដ ១៩ ។ ម្យ៉ាងវិញទៀតចំពោះការសិក្សាពីចម្ងាយនេះ គ្រូសាលារៀនជំនាន់ថ្មីគ្រប់គ្រងការធ្វើតេស្តតាមអនឡាញបានចំនួន ១១៥.០០០តេស្ត គិតជាមធ្យមក្នុងសិស្សម្នាក់ធ្វើបាន ៣០តេស្ត។ ទន្ទឹមនឹងនេះដែរ ខេបបានធ្វើឱ្យកម្មវិធីបរិញ្ញាបត្រជាន់ខ្ពស់អប់រំនៅមជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី ផ្លាស់ប្តូរទៅជាទម្រង់សិក្សាតាមអនឡាញ ទោះបីជាវិទ្យាស្ថានជាតិអប់រំត្រូវបានបិទទ្វារទាំងស្រុងក៏ដោយ។

**ការធ្វើតេស្តតាមអេឡិចត្រូនិក៖** ធនាគារសំណួរអេឡិចត្រូនិកបានដំណើរការតាមអនឡាញអំឡុងឆ្នាំនេះ ដែលប្រព័ន្ធសាលារៀនជំនាន់ថ្មីបង្កើនសុពលភាពធ្វើតេស្ត។ នេះជាចំណុចសំខាន់មួយដើម្បីជួយសាលារៀនប្រើវិធីសាស្ត្រវិទ្យាសាស្ត្របង្កើតបន្ថែម និងកែតម្រូវតេស្ត។ ទន្ទឹមនឹងនេះដែរ ខេបបានផ្លាស់ប្តូរសាលាបឋមសិក្សាជាច្រើន ដែលខេបបានគាំទ្រឱ្យទៅប្រើប្រាស់ទម្រង់តេស្តអេឡិចត្រូនិកសម្រាប់តេស្តដំណាក់កាល ដែលផ្សារភ្ជាប់ទៅនឹងកម្មវិធីសិក្សាក្នុងប្រព័ន្ធ ដោយប្រើប្រាស់សុសវែរមានឈ្មោះថា ***TEST***។

**រចនាសម្ព័ន្ធគ្រប់គ្រងសាលារៀន៖** កិច្ចសហការជាមួយក្រុមហ៊ុន SALA ខេបអាចធ្វើការសាកល្បងប្រព័ន្ធគ្រប់គ្រងសាលារៀនដោយស្វ័យប្រវត្តិ ដែលពន្លឿនមុខងារនៅមូលដ្ឋាន ដូចជា ការធ្វើរបាយការណ៍អំពីសាលារៀន ការចូលរួម និងទិន្នន័យសាលារៀនដែលមានប្រសិទ្ធភាព។

**កម្មវិធីសុសវែរអប់រំ៖** ខេបបានបន្តគាំទ្រការប្រើប្រាស់សុសវែរអប់រំជាច្រើនប្រភេទនៅក្នុងថ្នាក់រៀន ដែលលើកកម្ពស់ការប្រើប្រាស់ភាសា សមត្ថភាពផ្នែកភាសាអង់គ្លេស និងស្តែម (STEM)។



↑ *គ្រូបង្រៀនដឹកនាំសិស្សធ្វើតេស្តដំណាក់កាលតាមរយៈប្រព័ន្ធអេឡិចត្រូនិកនៅក្នុងបណ្ណាល័យសាលារៀន ដោយប្រើប្រាស់គម្លាតសង្គមក្នុងអំឡុងពេលការរីករាលដាលជំងឺកូវីដ ១៩ (គម្រោងត្រាក់៣/TRAC III)។*

# ការអភិវឌ្ឍន៍គ្រូបង្រៀន

**“គ្រូដែលល្អមិនមែនគ្រាន់តែជាអ្នកប្រាប់ ពន្យល់ និងបង្ហាញនោះទេ តែជាអ្នកជំរុញលើកទឹកចិត្តសិស្ស”**

## ព័ត៌មានសំខាន់ខ្លីៗអំពីការអភិវឌ្ឍគ្រូបង្រៀន

| | | |
|---|---|---|
| ចំនួនគម្រោង | ១២ | |
| ដៃគូអភិវឌ្ឍន៍សំខាន់ៗ | ក្រសួងអប់រំ យុវជន និងកីឡា<br>មូលនិធិ គីន ឆាន់<br>មូលនិធិគ្រួសារត្រកូលប្រូវេងស៍<br>មូលនិធិហ្វីនីក្ស<br>ធនាគារអភិវឌ្ឍអាស៊ី | អង្គការសង្គ្រោះកុមារ (SC)<br>សហគមន៍អឺរ៉ុប—អង្គការវីវើល<br>-GVC អង្គការយូនីសេហ្វ<br>អង្គារ PACT<br>អង្គការឆាលហ្វាន |
| កាលបរិច្ឆេទវិនិយោគ | ១៩៩៩ | |
| ប្រធានបទសំខាន់ៗក្នុងការវិនិយោគ | ♦ ប្រឹក្សាគរុកោសល្យគ្រូ<br>♦ ការលើកកម្ពស់ការប្រើប្រាស់កម្មវិធីប្រឹក្សាគរុកោសល្យគ្រូដែលគេស្គាល់ថា *អុបសើវីក/Observic*<br>♦ ការអភិវឌ្ឍគោលនយោបាយឈានដល់ការបង្កើត*ក្របខណ្ឌគរុកោសល្យថ្មី*ថ្នាក់ជាតិ និង*ក្របខណ្ឌគោលនយោបាយប្រឹក្សាគរុកោសល្យ*<br>♦ ការកសាងសមត្ថភាពគ្រូផ្នែក៖<br>• ការសិក្សាបែបស្ថាបនា<br>• ការសិក្សាបែបសហការ<br>• ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានវិទ្យាសម្រាប់ការអប់រំ<br>• កម្រិតពុទ្ធិប្លូម (Bloom′s Taxonomy)<br>• ការគ្រប់គ្រងថ្នាក់រៀន<br>• ការវាយតម្លៃសិស្សដោយអនុវត្តតាមគោលការណ៍សុពលភាព និងទំនុកចិត្ត<br>♦ ការបង្កើនសមត្ថភាពគ្រូកិច្ចសន្យាដែលកាន់តែដើរតួនាទីយ៉ាងសំខាន់នៅតំបន់ដាច់ស្រយាលដើម្បីដោះស្រាយបញ្ហាកង្វះគ្រូ។<br>♦ ការសិក្សាស្រាវជ្រាវការអប់រំគ្រូ និងប្រឹក្សាគរុកោសល្យគ្រូ។ | |
| ចំណុចសំខាន់ៗ | • ការបង្កើតមជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី (NGPRC) នៅវិទ្យាស្ថានជាតិអប់រំ<br>• ការបញ្ចប់ការសិក្សារបស់គរុនិស្សិតចំនួន ២៥នាក់ ជំនាន់ទី១ បរិញ្ញាអប់រំជាន់ខ្ពស់ ឯកទេសប្រឹក្សាគរុកោសល្យ<br>• ការបង្កើតប្រព័ន្ធប្រឹក្សាគរុកោសល្យមូលដ្ឋាននៅសាលារៀនជំនាន់ថ្មី<br>• បញ្ចប់ការសរសេរសៀវភៅគន្លឹះបណ្តុះបណ្តាល ស្តីពី “ការស្ថាបនា” និង“ ការវាយតម្លៃសិស្ស”។ | |

## សេចក្តីសង្ខេប

ការអភិវឌ្ឍគ្រូបង្រៀនគឺជាកម្មវិធីមួយដែលខេបបានផ្តោតការយកចិត្តទុកដាក់ដ៏សំខាន់តាំងពីពេលចាប់ផ្តើមក្លាយជាអង្គការផ្លូវការនៅក្នុងឆ្នាំ១៩៩៩មក។ ទោះបីជាអស់រយៈពេលច្រើនឆ្នាំកន្លងមកក៏ដោយ ខេបបានប្រើវិធីសាស្ត្រនេះកសាងសមត្ថភាពគ្រូបង្រៀនកាន់តែមានលក្ខណៈដ៏ទំនើប ហើយបានផ្លាស់ប្តូរទៅជាការផ្តល់វគ្គសិក្ខាសាលាយ៉ាងសំខាន់។ ខេបបានងាកទៅរកការបង្កើនបង្កើតប្រព័ន្ធប្រឹក្សាគរុកោសល្យមូលដ្ឋាន និងការប្រើប្រាស់សុសវែរគរុកោសល្យដើម្បីពង្រីកផលជះដល់សិក្ខាសាលាកសាងសមត្ថភាពជាច្រើនទៀត។

## ការអភិវឌ្ឍក្នុងបច្ចុប្បន្នភាព

**ការបង្កើតមជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី (NGPRC) នៅវិទ្យាស្ថានជាតិអប់រំ៖** ការបង្កើត NGPRC តាមសំណើរបស់ក្រសួងអប់រំ យុវជន និងកីឡាបានផ្តល់នូវគោលគំនិតរឹងមាំដល់ខេបតាមរយៈការជួយក្រសួងក្នុងការសិក្សាស្រាវជ្រាវអំពីវិធីសាស្ត្រដែលមានប្រសិទ្ធភាពសម្រាប់អប់រំគ្រូ និងផលិតធនធានមនុស្ស (ឧ.គ្រូប្រឹក្សាគរុកោសល្យ) ដែលអាចផ្តល់នូវវិធីសាស្ត្រថ្មីៗដ៏មានប្រសិទ្ធភាពក្នុងការអភិវឌ្ឍគ្រូបង្រៀន។ បច្ចុប្បនេះ មជ្ឈមណ្ឌលបានបិទវគ្គបណ្តុះបណ្តាលជំនាន់ទី១ បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសប្រឹក្សាគរុកោសល្យ។

**ការបង្កើតប្រព័ន្ធប្រឹក្សាគរុកោសល្យមូលដ្ឋាន៖** គរុនិស្សិតចំនួន ២៥នាក់ ដែលទើបបញ្ចប់ការសិក្សាពី NGPRC ក្នុងឆ្នាំ ២០២០ ត្រូវបានប្រកាសបង្កើតប្រព័ន្ធប្រឹក្សាគរុកោសល្យនៅគ្រប់សាលារៀនជំនាន់ថ្មីទាំងអស់។ នេះជាសញ្ញាណដ៏សំខាន់មួយសម្រាប់ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីបង្កើតគ្រូប្រឹក្សាគរុកោសល្យអនុវត្តតាមឯកសារក្របខ័ណ្ឌគោលនយោបាយដែលខេបបានអភិវឌ្ឍន៍។

**ការបញ្ចប់ការសរសេរសៀវភៅគន្លឹះបណ្តុះបណ្តាល “ការស្ថាបនា” និង “ការវាយតម្លៃសិស្ស”៖** ខេបបានបញ្ចប់ការសរសេរសៀវភៅគន្លឹះបណ្តុះបណ្តាលថ្មីៗជាច្រើន ដែលជាជំនាញគន្លឹះជួយលើកកម្ពស់សកម្មភាពកសាងសមត្ថភាពគ្រប់គម្រោងទាំងអស់។

**បង្កើតក្របខ័ណ្ឌគរុកោសល្យថ្មីសម្រាប់ប្រទេសកម្ពុជា៖** ខេបបានធ្វើការងារយ៉ាងជិតស្និទ្ធជាមួយរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ក្នុងការប្រើប្រាស់បទពិសោធន៍កម្មវិធីសាលារៀនជំនាន់ថ្មីធ្វើជាផែនទី និងជាមាគ៌ាណែនាំអំពីការផ្លាស់ប្តូរយុទ្ធសាស្ត្ររៀបចំគរុកោសល្យនៃការបង្រៀននៅប្រទេសកម្ពុជា។

**ការបណ្តុះបណ្តាលគ្រូកិច្ចសន្យា៖** ដោយសារក្រសួងអប់រំ យុវជន និងកីឡាពឹងផ្អែកកាន់តែច្រើនលើគ្រូកិច្ចសន្យា ដើម្បីដោះស្រាយបញ្ហាកង្វះខាតគ្រូបង្រៀន ការកសាងសមត្ថភាពគ្រូកិច្ចសន្យាបានក្លាយជាការងារអាទិភាពខ្ពស់។ បច្ចុប្បន្ននេះ គម្រោងខេបមួយចំនួន ដូចជា HCC កំពុងបង្កើនការវិនិយោគក្នុងការបណ្តុះបណ្តាលគ្រូកិច្ចសន្យា និងសម្របសម្រួលឱ្យពួកគាត់ទៅជាគ្រូពេញសិទ្ធិ។



↑ ***ផលិតធនធានអប់រំសម្រាប់ការអប់រំពីចម្ងាយ៖*** *ការបណ្តុះបណ្តាលនិម្មិត (ការបណ្តុះបណ្តាលពីចម្ងាយ)នៅមជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី (NGPRC) ជួយគ្រូអភិវឌ្ឍវីដេអូអប់រំ។*



***ការបណ្តុះបណ្តាលដោយអនុវត្តផ្ទាល់៖*** *គ្រូបង្រៀនក្នុងគម្រោង HCC ប្រើប្រាស់ល្បែងសិក្សាសិស្សមួយកញ្ចប់ ដើម្បីឈ្វេងយល់ឱ្យកាន់តែច្បាស់នូវរបៀបប្រើប្រាស់ល្បែងសិក្សា។* →

# កម្មវិធីអប់រំបរិយាប័ន្ន

**"ភាពចម្រុះ និងការអប់រំបរិយាប័ន្នផ្តល់តម្លៃដល់មនុស្សគ្រប់រូប មិនថាយើងមានភាពខុសគ្នាយ៉ាងណាក៏ដោយ"**

## ព័ត៌មានសំខាន់ខ្លីៗអំពីកម្មវិធីអប់រំបរិយាប័ន្ន

| | | |
|---|---|---|
| ចំនួនគម្រោង | ១៥ | |
| ដៃគូអភិវឌ្ឍន៍សំខាន់ៗ | អង្គការមូលនិធិអាស៊ី អង្គការ Lotus Outreach, មូលនិធិ គីន ឆាន់, អង្គការមូលនិធិអ្នកទ្រី, មូលនិធិ GAP និងអង្គការ PACT-USAID | ក្រសួងអប់រំ យុវជន និងកីឡា - អង្គការឆាលហ្វាន, អង្គការសង្គ្រោះកុមារ (SC), អង្គការវីរើល-GVC, សហគមន៍អឺរ៉ុប, អង្គការវីវីអូប៊ី |
| កាលបរិច្ឆេទវិនិយោគ | ១៩៩៩ | |
| ប្រធានបទសំខាន់ៗក្នុងការវិនិយោគ | • អន្តរាគមន៍ជាច្រើន (សូមមើលតារាងខាងក្រោម) មានគោលដៅផ្តោតលើកុមារ និងយុវជនផ្អែកលើកម្រិតអប់រំពួកគាត់<br>• អន្តរាគមន៍បានផ្តោតលើកម្រិតអប់រំជាច្រើន | |
| ចំណុចសំខាន់ៗ | • និស្សិតស្រីគម្រោង CTSP ចំនួន ៣០នាក់បានទទួលបរិញ្ញាបត្រពីសាកលវិទ្យាល័យវេស្ទើន ហើយបច្ចុប្បន្ននេះ ពួកគាត់មានការងារធ្វើគ្រប់ៗគ្នា។<br>• ខេបបានផ្តល់អាហារូបករណ៍ដល់កុមារ និងយុវជនងាយរងគ្រោះចំនួន ២.១៧៦ នាក់នៅឆ្នាំ២០២០។ | |

## តារាងស្តីពីអន្តរាគមន៍កម្មវិធីអប់រំបរិយាប័ន្ន

| គម្រោង | អាហារូបករណ៍/ការស្នាក់ | ការឧបត្ថម្ភថ្លៃសិក្សា | ការបណ្តុះបណ្តាលយេនឌ័រ និងការប្រឹក្សា | ការសិក្សាបំប៉នបន្ថែម | ការបង្រៀនខុសប្លែកពីគេ | អាគារសិក្សាបណ្តោះអាសន្ន | ការចូលរួមពីសហគមន៍ | ការអោយសម្ភារសិក្សា |
|---|---|---|---|---|---|---|---|---|
| ១. អាហារូបករណ៍និស្សិតកម្រិតឧត្តមសិក្សា | ✓ | ✓ | ✓ | | | | | ✓ |
| ២. ឆ្លើយតប និងស្តារឡើងវិញនូវវិស័យអប់រំក្នុងបរិបទជំងឺកូវីដ ១៩ | | | | ✓ | | | | ✓ |
| ៣. អប់រំកុមារី | ✓ | | ✓ | ✓ | | | ✓ | ✓ |
| ៤. កុមារកម្ពុជារីករាយ | | | ✓ | ✓ | | ✓ | ✓ | ✓ |
| ៥. សកម្មភាពយុវជនវ័យក្មេងនៅកម្ពុជា | ✓ | | | | | | ✓ | ✓ |
| ៦. អប់រំបំណិនជីវិតសម្រាប់កុមារី | | | ✓ | | | | | |
| ៧. កម្មវិធីសាលារៀនជំនាន់ថ្មី (កម្រិតបឋម) | | ✓ | | ✓ | ✓ | | ✓ | |
| ៨. កម្មវិធីសាលារៀនជំនាន់ថ្មី (កម្រិតមធ្យម) | | ✓ | | ✓ | ✓ | | ✓ | |
| ៩. កម្មវិធីសាលារៀនជំនាន់ថ្មី/ស្វាយរៀង | | ✓ | | ✓ | ✓ | | ✓ | |
| ១០. បរិស្ថានសិក្សាប្រកបដោយគុណភាព | ✓ | | | ✓ | | | ✓ | |
| ១១. បង្កើនភាពងាយស្រួលចូលសាលារៀនតាមរយៈការគាំទ្រពីសហគមន៍ (REACH III) | ✓ | | | ✓ | | | ✓ | ✓ |
| ១២. លើកកម្ពស់ការអប់រំ និងការងារនៅកម្ពុជា | ✓ | | ✓ | ✓ | | | ✓ | ✓ |
| ១៣. លើកកម្ពស់ការឆ្លើយតបនឹងសមភាពយេនឌ័រក្នុងការបង្រៀន និងរៀន | | | ✓ | | | | ✓ | ✓ |
| ១៤. វិធីសាស្ត្រសរុបដើម្បីពង្រឹងអំណានសម្រាប់កុមារ | | | | ✓ | ✓ | | ✓ | ✓ |
| ១៥. សហគ្រិនវ័យក្មេង | | | ✓ | | | | | ✓ |

## សេចក្តីសង្ខេប

ការប្រឹងប្រែងធ្វើឱ្យការអប់រំកាន់តែមានលទ្ធភាពសម្រាប់កុមារងាយរងគ្រោះ និងយុវជនគឺជាគោលដៅមួយយូរអង្វែងបំផុតនៃគោលដៅដទៃទៀត ចាប់តាំងពីពេលខេបបានបង្កើតឡើង។ មកដល់បច្ចុប្បន្ននេះ ខេបបានអភិវឌ្ឍនូវអន្តរាគមន៍យ៉ាងទូលំទូលាយ ដើម្បីបង្កើនលទ្ធភាពទទួលបានការអប់រំ ជាពិសេសនៅតាមតំបន់ជនបទភាគច្រើនក្នុងប្រទេសកម្ពុជា។ អន្តរាគមន៍ទាំងនេះ រួមមាន៖ អាហារូបករណ៍ ប្រាក់ឧបត្ថម្ភថ្លៃសិក្សា ការបណ្តុះបណ្តាលយេនឌ័រ ការសិក្សាបំប៉នបន្ថែមសម្រាប់កុមាររៀនយឺត ការបង្រៀនខុសប្លែកពីគេតាមតម្រូវការកុមារម្នាក់ៗ អគារសិក្សាបណ្តោះអាសន្នដើម្បីបង្កលទ្ធភាពអប់រំបន្ទាន់ដល់តំបន់ដាច់ស្រយាល ការចូលរួមពីសហគមន៍ ដូចជា ផែនទីសាលារៀន និងយុទ្ធនាការប្រមូលសិស្សចូលរៀន និងការសម្របសម្រួល។ បច្ចុប្បន្ននេះ ខេបមានគម្រោងចំនួន១៥ ដែលមានយុទ្ធសាស្ត្រអប់រំបរិយាប័ន្នចាប់ពីកម្រិតបឋម (HCC, REACH, NGS) ដល់ឧត្តមសិក្សា (ឧ.CTSP)។

## ការអភិវឌ្ឍក្នុងបច្ចុប្បន្នភាព

ខេបបានបន្ថែមគម្រោងថ្មីចំនួនពីរក្រោមប្រធានបទការអប់រំបរិយាប័ន្ននៅក្នុងឆ្នាំ២០២០ ដែលរួមមាន៖ ***គម្រោងលើកកម្ពស់ការអប់រំ និងការងារនៅកម្ពុជា (SEEK)*** គាំទ្រហិរញ្ញប្បទានដោយសហគមន៍អឺរ៉ុប និង***កម្មវិធីឆ្លើយតប និងស្តារឡើងវិញនូវវិស័យអប់រំក្នុងបរិបទជំងឺកូវីដ ១៩ (CERRP )***គាំទ្រហិរញ្ញប្បទានដោយអង្គការយូនីសេហ្វ។ SEEK ផ្តល់ការគាំទ្រអាហារូបករណ៍ដល់កុមារងាយរងគ្រោះទាំងថ្នាក់បឋមសិក្សា និងមធ្យមសិក្សា ក៏ដូចជាការសិក្សាបំប៉នបន្ថែមដល់កុមារបឋមសម្រាប់ឡើងថ្នាក់ទី៧។CERRP ផ្តល់នូវតួនាទីដ៏សំខាន់ដល់ខេបក្នុងការធ្វើការងារជាមួយក្រសួងអប់រំ យុវជន និងកីឡា ដើម្បីរៀបចំ "**ការសិក្សាបន្ត**" តាមរយៈការអប់រំពីចម្ងាយនូវកម្មវិធីឌីជីថល ក៏ដូចជា "**ការសិក្សាបំប៉នបន្ថែម**" ដល់កុមារនៅតំបន់ដាច់ស្រយាល។ ទន្ទឹមនេះដែរ ក្នុងពេលបច្ចុប្បន្នក្មេងស្រីចំនួន ៣០នាក់ ដែលទទួលបានអាហារូបករណ៍ពីគម្រោង CTSP ទទួលសញ្ញាបត្របរិញ្ញាបត្រក្នុងឆ្នាំ២០២០ និងមានការងារធ្វើគ្រប់ៗគ្នា។ ម្យ៉ាងវិញទៀត ខេបបានបន្តផ្តល់អាហារូបករណ៍ដល់សិស្សមធ្យមសិក្សារាប់រយនាក់តាមរយៈគម្រោង SEEK។



↑ និស្សិតស្រីគម្រោង CTSP ចំនួន ៣០នាក់ផ្សេងទៀតទទួលបានសញ្ញាបត្របរិញ្ញាបត្ររបស់ពួកគាត់។



← សកម្មភាពសិក្សាបំប៉នបន្ថែមតាមភូមិរបស់គម្រោង HCC ជួយកុមារបានចូលសិក្សានៅសាលា។

សកម្មភាពអាហារូបករណ៍របស់គម្រោងរីក/REACH បានគាំទ្រដល់កុមារក្រីក្រឱ្យបានចូលសាលារៀន។ →



# អំណានថ្នាក់ដំបូង

## "នៅពេលអ្នករៀនអាន អ្នកនឹងមានសេរីភាពរហូត"

| ព័ត៌មានសំខាន់ខ្លីៗអំពីកម្មវិធីអំណានថ្នាក់ដំបូង | | |
|---|---|---|
| ចំនួនគម្រោង | ៧ | |
| ដៃគូអភិវឌ្ឍន៍សំខាន់ៗ | ក្រសួងអប់រំ យុវជន និងកីឡា-GPE3, មូលនិធិ គីន ឆាន់, មូលនិធិហ្វ៊ីនីកស៍ | អង្គការវីវើល-GVC, អង្គការយូនីសេហ្វ, អង្គការសង្គ្រោះកុមារ (SC) |
| កាលបរិច្ឆេទវិនិយោគ | ២០១២ | |
| ប្រធានបទសំខាន់ៗក្នុងការវិនិយោគ | • ការអភិវឌ្ឍស្តង់ដាអំណាន<br>• ការវាយតំលៃជាប្រចាំ (ផ្តល់ដំណឹងជាស្តង់ដា)<br>• ការធ្វើតេស្តអ៊ីហ្គ្រា (EGRA)<br>• ប្រព័ន្ធឆ្លើយតបរហ័ស (RRS) ដើម្បីដោះស្រាយសេចក្តីត្រូវការរបស់សិស្សរៀនយឺត<br>• ប្រអប់ល្បែងសិក្សាអក្ខរកម្មសម្រាប់ផ្តល់ជាសម្ភារពង្រឹងជំនាញដាក់លេខកូដពាក្យ<br>• គ្រូបង្វឹកអក្ខរកម្មមូលដ្ឋានធ្វើចលករប្រព័ន្ធឆ្លើយតបរហ័ស<br>• ការវិនិយោគបណ្ណាល័យសតវត្សរ៍ទី២១មានកម្រិតខ្ពស់<br>• ការអភិវឌ្ឍសុសវែរអំណាន និងសំណេរ | |
| ចំណុចសំខាន់ៗ | • ការផ្សព្វផ្សាយវិធីសាស្រ្តរបស់គម្រោងត្រាក់នៅតាមសាលារៀនចំនួន ១៤៧។<br>• លទ្ធផលពិន្ទុ EGRA នៅសាលារៀនគម្រោងត្រាក់ដែលគាំទ្រដោយគម្រោងទ្វេភាគីបង្ហាញថាមានកម្រិតខ្ពស់។ | |

## សេចក្តីសង្ខេបៈ

ខេបបានចាប់ផ្តើមខិតខំវិនិយោគកម្មវិធីអំណានក្នុងឆ្នាំ២០១២ តាមរយៈការបង្កើតគម្រោងវិធីសាស្រ្តសរុបដើម្បីពង្រឹងអំណានសម្រាប់កុមារ(TRAC I)។ បច្ចុប្បន្ន គម្រោងនេះបានផ្តល់នូវវិធីសាស្រ្តមូលដ្ឋានគ្រឹះផ្នែកអំណានដែលខេបកំពុងប្រើប្រាស់នៅក្នុងគម្រោងចំនួន៧។ គម្រោងត្រាក់មកដល់បច្ចុប្បន្ននេះបានប្រតិបត្តិក្នុងជុំទី៣ ដែលយើងហៅថា ត្រាក់៣/TRAC III។

មិនដូចកម្មវិធីគាំទ្រដោយទ្វេភាគីច្រើនបំផុតនោះទេ ខេបបានចៀសវាងវិធីសាស្រ្តវិនិយោគផ្តោតលើការកែសម្រួលកម្មវិធីសិក្សា តែជ្រើសរើសយកប្រព័ន្ធជំនួសវិញដើម្បីលើកកម្ពស់គណនេយ្យភាពក្នុងការផ្តល់កម្មវិធីសិក្សា។ គណនេយ្យភាពនេះតម្រូវឱ្យមានការប្រើប្រាស់ស្តង់ដាអំណាន ដើម្បីផ្តល់នូវការវាយតម្លៃជាប្រចាំ ប្រព័ន្ធឆ្លើយតបយ៉ាងឆាប់រហ័សដើម្បីដោះស្រាយបញ្ហាកុមាររៀនយឺត ការខិតខំវិនិយោគបណ្ណាល័យ កម្មវិធីសុសវែរអំណាន និងគ្រូអក្ខរកម្មមូលដ្ឋានដែលធ្វើឱ្យប្រព័ន្ធទាំងមូលមានដំណើរការ។

## ការអភិវឌ្ឍក្នុងបច្ចុប្បន្នភាពៈ

កម្មវិធីអំណានរបស់ខេបបានចុះបញ្ជីប្រើប្រាស់ជោគជ័យក្នុងការបង្កើនពិន្ទុ EGRA នៅតាមសាលារៀនដែលខេបគាំទ្រ ជាពិសេសការប្រៀបធៀបទៅនឹងកម្មវិធីថ្នាក់ជាតិដែលគាំទ្រដោយទ្វេភាគី ដែលភាគច្រើនមិនបានបង្ហាញអំពីសមត្ថភាពអំណានមានភាពប្រសើរឡើងទេ (សូមមើលតារាងខាងក្រោម)។

| គម្រោងដែលកំពុងប្រើប្រាស់វិធីសាស្រ្តរបស់គម្រោងត្រាក់ |
|---|
| ១. ត្រាក់៣/TRAC III (២០១៨-២២)<br>• ចំនួន ១៨ សាលា<br>• ក្នុងខេត្តកំពង់ចាម និងត្បូងឃ្មុំ |
| ២. គម្រោងងាយស្រួលរៀន (E2L-ស្វាយរៀង) (បានបិទបញ្ចប់)<br>• ចំនួន ២៨ សាលា |
| ៣. គម្រោងងាយស្រួលរៀន (E2L-ខេត្តក្រចេះ)[4]<br>• ចំនួន ៣០ សាលា |
| ៤. គម្រោង (REACH)<br>• ចំនួន ២៦ សាលា<br>• ខេត្តស្វាយរៀង កំពង់ឆ្នាំង និងពោធិ៍សាត់ |
| ៥. សាលារៀនជំនាន់ថ្មី<br>• ចំនួន ៤ សាលា<br>• ខេត្តកំពង់ចាម ស្វាយរៀង និងកំពង់ស្ពឺ |
| ៦. គម្រោងកុមារកម្ពុជារីករាយ (HCC)<br>• ចំនួន ៤១ សាលា<br>• ខេត្តសៀមរាប កំពង់ចាម ក្រចេះ រតនៈគិរី និងត្បូងឃ្មុំ |
| សរុបៈ ១៤៧ សាលា |

| ផ្នែកតេស្តអ៊ីហ្គ្រា/EGRA (ថ្នាក់ទី១) | វិធីសាស្រ្តត្រាក់ | | កម្មវិធីថ្នាក់ជាតិដែលគាំទ្រហិរញ្ញប្បទានដោយទ្វេភាគី | |
|---|---|---|---|---|
| | មធ្យម | ពិន្ទុសូន្យ | មធ្យម | ពិន្ទុសូន្យ |
| ឈ្មោះតួអក្សរ (ក្នុង១នាទី) | ២៦.៥ | ២% | ១២.៦ | ១២% |
| ស្គាល់ពាក្យ (ក្នុង១នាទី) | ១០.០ | ៣៦% | ៣.៣ | ៦៦% |

*កុមារនៅក្នុងសាលាដែលគាំទ្រដោយគម្រោង HCC ថ្នាក់ទី២ បានធ្វើតេស្ត EGRA(រូបខាងឆ្វេង)។*

*គ្រូបង្វឹកអក្ខរកម្មម្នាក់បានធ្វើការជាមួយគ្រូបង្រៀនក្នុងអំឡុងពេលប្រជុំប្រចាំពីរខែម្តង (រូបខាងស្តាំ)។*





**ការធ្វើបរិបទអំណាន សំណេរ និងធ្វើតេស្តតាមសុសវែរ អាចរកបាននៅក្នុងបណ្ណាល័យគម្រោងត្រាក់៖** បច្ចុប្បន្ននេះ កម្មវិធីអំណាន សំណេរ និងតេស្តផ្សេងៗដែលអភិវឌ្ឍន៍ឡើងដោយខេប និងដៃគូ បានតំឡើងនៅក្នុងថេបប្លេតនៅតាមបណ្ណាល័យដែលគាំទ្រដោយខេប។ រូបសញ្ញា(Logo)កម្មវិធីសុសវែរទាំងនេះបង្ហាញនៅខាងលើពីឆ្វេងទៅស្តាំ រួមមាន៖ កម្មវិធី***អានខ្មែរ*** (កម្មវិធីអំណានថ្នាក់ទី១) ***សរសេរខ្មែរ*** (កម្មវិធីសំណេរថ្នាក់ទី១ និងទី២) ***សៀវភៅឆ្លាត*** (កម្មវិធីអំណានថ្នាក់ទី២ និងទី៣) ***តោះអាន*** (បញ្ជីរឿងជាអេឡិចត្រូនិកថ្នាក់ទី២ ទី៣ ទី៤ ទី៥ និងទី៦) និង***តេស្ត*** (កម្មវិធីតេស្តដែលប្រើប្រាស់ការគ្រប់គ្រងការធ្វើតេស្តដំណាក់កាល)។

[4] *គាំទ្រហិរញ្ញប្បទាន និងប្រតិបត្តិដោយអង្គការឆាលហ្វានផ្ទាល់។*

# កម្មវិធីមត្តេយ្យសិក្សា

## "បង្កើនគំនិតមួយសម្រាប់កុមារមួយនាក់ក្នុងពេលតែមួយ"

### ព័ត៌មានសំខាន់ខ្លីៗអំពីកម្មវិធីមត្តេយ្យសិក្សា

| | |
|---|---|
| ចំនួនគម្រោង | ៣ |
| ដៃគូអភិវឌ្ឍន៍សំខាន់ៗ | មូលនិធិ គីន ឆាន់ (HCC)<br>មូលនិធិហ្វីនីកស៍ (ត្រាក់៣/TRAC III)<br>អង្គការវីវើល-GVC (រីក៣/REACH III) |
| កាលបរិច្ឆេទវិនិយោគ | ២០១៥ |
| ប្រធានបទសំខាន់ៗក្នុងការវិនិយោគ | • ការពង្រីកបន្ថែមកម្មវិធីសាលារៀនជំនាន់ថ្មីផ្នែកកម្មវិធីមត្តេយ្យសិក្សា<br>• ការវិនិយោគកម្មវិធីមត្តេយ្យសិក្សា ដើម្បីលើកកម្ពស់លទ្ធផលកម្មវិធីអំណាន<br>• រចនាបថថ្នាក់រៀនមត្តេយ្យសិក្សាថ្មីលើកកម្ពស់ការសិក្សា<br>• ព័ត៌មានវិទ្យា ទំនាក់ទំនង និងបច្ចេកវិទ្យា (ICT) សម្រាប់ការអប់រំនៅមត្តេយ្យសិក្សា |
| ចំណុចសំខាន់ៗ | • ការអភិវឌ្ឍសៀវភៅមត្តេយ្យសិក្សាជំនាន់ថ្មី<br>• ការសាកល្បងរចនាបថថ្មីសម្រាប់ថ្នាក់មត្តេយ្យសិក្សា។ |




*↑ នាពេលបច្ចុប្បន្ននេះ ខេបបានបង្កើតសៀវភៅណែនាំថ្មីមួយ ដែលនឹងផ្តល់ជាមូលដ្ឋានគ្រឹះសម្រាប់បណ្តុះបណ្តាលគ្រូមត្តេយ្យ ដើម្បីរៀបចំបរិស្ថានសិក្សារូបវន្តនៅក្នុងថ្នាក់រៀនប្រកបដោយប្រសិទ្ធភាពសម្រាប់កុមារថ្នាក់មត្តេយ្យ។ គោលការណ៍ណែនាំទាំងនេះបានសង្កត់ធ្ងន់ទៅលើការប្រើប្រាស់បច្ចេកវិទ្យាក្នុងការអប់រំកុមារតូច ហើយថែមទាំងស្នើយោបល់ធ្វើរចនាបថរូបវន្តថ្មីៗ ដើម្បីបង្កើតបរិស្ថានសិក្សានៅមត្តេយ្យសិក្សាទំនើប។ សៀវភៅណែនាំត្រូវបានដាក់បង្ហាញជូនក្រសួងអប់រំ យុវជន និងកីឡាត្រួតពិនិត្យ និងអនុម័ត ដើម្បីពង្រីកកម្មវិធីសាលារៀនជំនាន់ថ្មីទៅមត្តេយ្យសិក្សា។*

## សេចក្តីសង្ខេប

ខេបបានឈានចូលពាក់ព័ន្ធនឹងជំនាញអភិវឌ្ឍន៍មត្តេយ្យសិក្សា។ ខេបបានចាប់ផ្តើមវិនិយោគនៅក្នុងជំនាញនេះតាមរយៈគម្រោងរីក២/REACH II (២០១៦-១៨) នៅពេលខេបបានធ្វើការវិនិយោគបង្កើត និងកែលម្អមត្តេយ្យសិក្សានៅតាមសាលាបឋមសិក្សាចំនួន៥០ ដែលបច្ចុប្បន្ននេះបានគាំទ្រដោយគម្រោង REACH III។ មានការវិនិយោគបន្ថែមច្រើនទៀតលើកម្មវិធីមត្តេយ្យសិក្សាពីមូលនិធិ **គីន ឆាន់** ដើម្បីបង្កើតសាលាមត្តេយ្យសិក្សាសហគមន៍មួយនៅឃុំហាន់ជ័យ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ ខេបនិងអង្គការដៃគូ BSDA បានអភិវឌ្ឍន៍រចនាបថហេដ្ឋារចនាសម្ព័ន្ធថ្មីសម្រាប់សាលាមត្តេយ្យនេះ គឺពិតជាមានលក្ខណៈខុសប្លែកពីគេ។ ខេបចាត់ទុកការវិនិយោគលើការអប់រំមត្តេយ្យសិក្សាមានភាពពាក់ព័ន្ធខ្លាំងទៅនឹងការខិតខំប្រឹងប្រែងដើម្បីកែលម្អអំណានថ្នាក់ដំបូង និងគណិតវិទ្យា ដោយផ្តល់នូវជំនាញអក្ខរកម្ម និងលេខនព្វន្តជាមូលដ្ឋានដ៏រឹងមាំមុនពេលចុះឈ្មោះចូលរៀននៅថ្នាក់ទី១។

## ការអភិវឌ្ឍក្នុងបច្ចុប្បន្នភាព

នៅឆ្នាំ២០២០ មូលនិធិហ្វីនីកស៍បានគាំទ្រខេបដើម្បីធ្វើការវិនិយោគបន្ថែមលើការអប់រំមត្តេយ្យ ដោយមានគោលដៅអភិវឌ្ឍទៅជាអ្វីដែលគេហៅថា ***សាលាមត្តេយ្យសិក្សាជំនាន់ថ្មី (NGPS)***។ ការគាំទ្រនេះបានជួយខេបបង្កើតវិធីសាស្ត្រប្រកបដោយភាពច្នៃប្រឌិតលើកម្មវិធីអប់រំមត្តេយ្យ ដែលរួមបញ្ចូលនូវបច្ចេកទេសចុងក្រោយក្នុងការអប់រំកុមារតូច និងជាពិសេសការប្រើប្រាស់ព័ត៌មានវិទ្យា ទំនាក់ទំនង និងបច្ចេកវិទ្យាជាមួយកុមារតូចៗ។ វិធីសាស្ត្រនេះត្រូវបានចងក្រងជាសៀវភៅណែនាំមានលក្ខណៈច្នៃប្រឌិត ដែលនឹងជួយក្រសួងយកវិធីសាស្ត្រថ្មីនេះទៅអនុវត្តនៅសាលាមត្តេយ្យសិក្សាស្ថិតក្នុងទីតាំងថ្មីៗ។ ខេបក៏ជឿជាក់ផងដែរថា ការគាំទ្រដល់ការអប់រំមត្តេយ្យសិក្សានៅតាមសាលារៀនគោលដៅគម្រោងត្រាក់៣/TRACIII នឹងជួយពង្រឹងលទ្ធផលអំណានបន្ថែមទៀត។



***← សាលាមត្តេយ្យសហគមន៍ថ្មីក្នុងខេត្តកំពង់ចាម៖*** *សិស្សសាលាមត្តេយ្យវ័យក្មេងម្នាក់នៅក្នុងសាលាមត្តេយ្យសហគមន៍ដែលសាងសង់ដោយខេប និងគាំទ្រហិរញ្ញប្បទានពីមូលនិធិ គីន ឆាន់ ឈរពន្យល់អំពីអក្សរដែលនាងកំពុងសិក្សា។*

***រចនាបថសាលាមត្តេយ្យសិក្សាថ្មី៖*** *ជាកន្លែងបង្កើនការសិក្សាដែលលើកកម្ពស់ការសិក្សាដោយឯករាជ្យ ហើយបច្ចុប្បន្ននេះកំពុងទទួលបានការគាំទ្រហិរញ្ញប្បទានពីមូលនិធិហ្វីនីកស៍។ ↓*



# របនាបថហេដ្ឋារចនាសម្ព័ន្ធ

## “ធ្វើឱ្យទម្រង់ការអប់រំស្របតាមតម្រូវការ និងដើរតួនាទីថ្មីៗ”

| ព័ត៌មានសំខាន់ខ្លីៗអំពីរចនាបថហេដ្ឋារចនាសម្ព័ន្ធ | |
|---|---|
| ចំនួនគម្រោង | ៦ |
| ដៃគូអភិវឌ្ឍន៍សំខាន់ៗ | ក្រសួងអប់រំ យុវជន និងកីឡា - មូលនិធិគ្រួសារត្រកូលហ្វ្រេងស៍, អង្គការឆាលហ្វាន (NGS), មូលនិធិ គីនឆាន់ (HCC), មូលនិធិហ្វ៊ីនីកស៍(TRAC III), អង្គការវីវើល-GVC (REACH III), ធនាគារអភិវឌ្ឍអាស៊ី |
| កាលបរិច្ឆេទវិនិយោគ | ២០១៥ |
| ប្រធានបទសំខាន់ៗក្នុងការវិនិយោគ | • លើកកម្ពស់ការរៀបចំថ្នាក់រៀនដែលអាចជំរុញដល់គរុកោសល្យថ្មី។<br>• ណែនាំអំពីការប្រើប្រាស់សម្ភារទំនើបៗ ដូចជា កញ្ចក់ Formica ក្រូមេ និងបរិក្ខារអប់រំធ្វើពីក្រណាត់។<br>• រចនាគ្រឿងសង្ហារឹមច្រើនមុខងារដើម្បីបន្ស៊ីគ្នានឹងកន្លែងសិក្សាព័ទ្ធជុំវិញមានលក្ខណៈរួបរួន្ត។<br>• លើកកម្ពស់សោភ័ណភាពបន្ថែមទៀតឱ្យកាន់តែជាកន្លែងសិក្សាមានការទាក់ទាញ។ |
| ចំណុចសំខាន់ៗ | • ការបោះពុម្ពផ្សាយសៀវភៅស្ថាបត្យកម្មសាលារៀនសតវត្សរ៍ទី២១<br>• អភិវឌ្ឍន៍រចនាបថថ្មីសម្រាប់មត្តេយ្យសិក្សាជំនាន់ថ្មី<br>• បញ្ចប់ការវិនិយោគដ៏ធំក្នុងការរចនាអគារសិក្សា ដែលបានកែលម្អនៅសាលាបឋមសិក្សាដាច់ស្រយាលចំនួន ៩១ ដោយប្រើប្រាស់បច្ចេកទេសជួសជុលទំនើប<br>• បញ្ចប់ការកសាងបណ្ណាល័យសតវត្សរ៍ទី២១ចំនួន ៦ថ្មីទៀតនៅកម្រិតបឋម។ |

## សេចក្តីសង្ខេប

ការចូលរួមក្នុងការងាររចនាបថហេដ្ឋារចនាសម្ព័ន្ធ ខេបបានចាប់ផ្តើមវិនិយោគជាអគាររួបរ័ន្ត ដើម្បីទទួលបានអគារ និងថ្នាក់រៀនដែលសាងសង់មានបរិមាណខ្ពស់។ ជាក់ស្តែង ខេបចៀសវាងការវិនិយោគលើស្ថាបត្យកម្មចាស់ៗពីអតីតកាលដែលគ្មានភាពទាក់ទាញ ហើយផ្តោតលើរចនាបថច្នៃប្រឌិតថ្មីដែលលើកកម្ពស់ជំនាញសិក្សានៅក្នុងសតវត្សរ៍ទី២១ (ឧ. ការងារក្រុម ការសិក្សាបែបនិម្មិត (ការសិក្សាពីចម្ងាយ)) មានសាភ័ណភាពទាក់ទាញ និងប្រសិទ្ធភាពប្រើប្រាស់ទីកន្លែង។ ការគាំទ្រហិរញ្ញប្បទានពីក្រសួងអប់រំ យុវជននិង កីឡាក្នុងកម្មវិធីសាលារៀនជំនាន់ថ្មី ជាពិសេសបានគាំទ្ររចនាបថច្នៃប្រឌិតថ្មី ទាំងផ្នែកហេដ្ឋារចនាសម្ព័ន្ធ និងការដំឡើងគ្រឿងសង្ហារឹម។ ការវិនិយោគនេះបានផ្លាស់ប្តូរបរិយាកាសនៅសាលារៀនជាច្រើនដែលខេបធ្វើការជាមួយ ដើម្បីឱ្យកាន់តែទំនើប និងគាំទ្រដល់គរុកោសល្យថ្មីៗ ដូចជា៖ ការសិក្សាប្រើគោលគំនិត ការងារគម្រោង និងវិធីសាស្ត្រដទៃៗទៀត។ រចនាបថថ្មីមិនត្រឹមតែផ្តោតលើថ្នាក់រៀនតែប៉ុណ្ណោះទេ ប៉ុន្តែក៏ផ្តោតលើអគារសិក្សាដទៃៗទៀតជាច្រើនដែរ រួមមាន៖ បណ្ណាល័យ បន្ទប់ពិសោធន៍វិទ្យាសាស្ត្រ បន្ទប់កុំព្យូទ័រ បន្ទប់ប្រជុំ...។ល។

## ការអភិវឌ្ឍក្នុងបច្ចុប្បន្នភាព

ក្នុងឆ្នាំ២០២០ ខេបបានបោះពុម្ពឯកសារសង្ខេបស្តីពីវិធីសាស្ត្ររចនាបថស្ថាបត្យកម្មថ្មីនៅតាមសាលារដ្ឋ។ គោលបំណងបោះពុម្ពផ្សាយនេះគឺធ្វើការសម្របសម្រួលយ៉ាងសកម្មជាមួយម្ចាស់ជំនួយឱ្យងាកចេញពីរចនាបថចាស់ៗគ្មានភាពទាក់ទាញ ដែលបានប្រើប្រាស់ក្នុងរយៈពេល ៧០ឆ្នាំកន្លងមក ហើយមានការផ្លាស់ប្តូរតិចតួចនៅពេលនោះ។ ទន្ទឹមនឹងនេះ ខេបមានលទ្ធភាពបង្កើនចំនួនគំរូស្ថាបត្យកម្មបង្ហាញពីរចនាបថថ្មីៗនៅក្នុងគម្រោងតាមបណ្តាខេត្តជាច្រើន។ តាំងពីឆ្នាំ២០១៥មក ខេបមានលទ្ធភាពជួសជុល និងរចនាបថថ្មីឡើងវិញនូវអគារសិក្សាចំនួន៤៩២បន្ទប់ ទាំងកម្រិតបឋមសិក្សា និងមធ្យមសិក្សា (សូមមើលតារាងខាងក្រោមនេះ)។

## សេចក្តីសង្ខេបអំពីការវិនិយោគរបស់ខេបផ្នែករចនាបថអាគារសិក្សាច្នៃប្រឌិតថ្មី ឆ្នាំ២០១៥-២០២០

| បរិក្ខា | NGS | REACH | E2L | TRAC | HCC | សរុប |
|---|---|---|---|---|---|---|
| ថ្នាក់រៀនទំនើប | ១៣៦ | | | | ១៧០ | ៣០៦ |
| បន្ទប់ពិសោធន៍ | ៤៩ | | | | | ៤៩ |
| បន្ទប់កុំព្យូទ័រ | ១៦ | | | | | ១៦ |
| បណ្ណាល័យទំនើប | ៧ | ១២ | ១៦ | ១៨ | ៣៥ | ៨៨ |
| សាលប្រជុំ | ៤ | | | | | ៤ |
| បន្ទប់ប្រជុំ | ១៧ | | | | | ១៧ |
| អាហារដ្ឋាន | ២ | | | | | ២ |
| បន្ទប់សង្គ្រោះបឋម | ៥ | | | | | ៥ |
| មណ្ឌលយុវជន | ៥ | | | | | ៥ |
| សរុប | ២៤១ | ១២ | ១៦ | ១៨ | ២០៥ | ៤៩២ |





***↑ រចនាបថបន្ទប់ពិសោធន៍វិទ្យាសាស្ត្រទំនើប៖*** *រូបភាពខាងលើបង្ហាញអំពីរចនាបថបន្ទប់ពិសោធន៍វិទ្យាសាស្ត្រទំនើប ដែលប្រើពណ៌ចម្រុះមួយឬពីរ និងការរៀបចំរចនាបថដែលជួយសម្រួលដល់ការសិក្សាជំនាញក្នុងសតវត្សរ៍ទី២១ ដូចជា៖ ការងារក្រុម ការងារពិសោធន៍ និងការធ្វើបទបង្ហាញ។*

***← រចនាបថថ្នាក់រៀនទំនើប៖*** *ប្លង់ថ្នាក់រៀនបានបង្ហាញអំពីរបៀបផ្លាស់ប្តូរសាមញ្ញមួយចំនួននៅក្នុងរចនាបថថ្នាក់រៀន អាចធ្វើឱ្យបរិយាកាសសិក្សាទទួលបានភាពរីកចម្រើនយ៉ាងធំធេង។ រូបសណ្ឋានតុសិស្សថ្មីបង្កើនចំនួនបម្រែបម្រួលនៅក្នុងចំណោមក្រុមសិស្ស ខណៈពេលដែលកន្លែងលំហនៅកណ្តាលថ្នាក់រៀនបង្កើនសមត្ថភាពគ្រូធ្វើការផ្លាស់ប្តូររវាងក្រុមសិស្សនិងសិស្សបាន។*

# ការអភិវឌ្ឍបណ្ណាល័យ

## "បណ្ណាល័យសាលារៀន៖ ជាសោរសម្រាប់អតីតកាល និងជាទ្វារសម្រាប់អនាគត"

| ព័ត៌មានសំខាន់ខ្លីៗអំពីការវិនិយោគបណ្ណាល័យ | |
|---|---|
| ចំនួនគម្រោង | ៨ |
| ដៃគូអភិវឌ្ឍន៍សំខាន់ៗ | ក្រសួងអប់រំ យុវជន និងកីឡា - មូលនិធិគ្រួសារត្រកូលហ្រ្វេងស៍ អង្គការឆាលហ្វាន មូលនិធិ គីន អាន់ (HCC) មូលនិធិហ៊្វីនីកស៍ (TRAC III) អង្គការវីរើល-GVC (REACH III) អង្គការមូលនិធិអាស៊ី និងធនាគារអភិវឌ្ឍអាស៊ី |
| កាលបរិច្ឆេទវិនិយោគ | ២០១៥ |
| ប្រធានបទសំខាន់ៗក្នុងការវិនិយោគ | • អភិវឌ្ឍគោលនយោបាយលើការរចនាបថបណ្ណាល័យ និងការកំណត់រចនាសម្ព័ន្ធបណ្ណាល័យ<br>• សហការល្អជាមួយអង្គការមូលនិធិអាស៊ី ដើម្បីលើកកម្ពស់ការបរិច្ចាគសៀវភៅជាភាសាអង់គ្លេសដល់បណ្ណាល័យសាលារៀន (BfC)<br>• រចនាបថបណ្ណាល័យទំនើប មានសេវាកម្មសិក្សាតាមទូរសព្ទ (TRAC & HCC)<br>• ការរៀបចំបណ្ណាល័យសម្រាប់គាំទ្រដល់អំណានថ្នាក់ដំបូង<br>• ជួសជុលបណ្ណាល័យ<br>• ផ្សព្វផ្សាយអំពីបណ្ណាល័យដល់សហគមន៍ |
| ចំណុចសំខាន់ៗ | • ការបោះពុម្ពសៀវភៅស្តង់ដាបណ្ណាល័យសតវត្សរ៍ទី២១ ដែលលើកកម្ពស់ទំនើបកម្មបណ្ណាល័យសាលារៀន<br>• ជួសជុលបណ្ណាល័យនៅសាលារៀនដាច់ស្រយាលចំនួន ១៦បណ្ណាល័យបានសព្វគ្រប់ (HCC)<br>• បណ្ណាល័យសតវត្សរ៍ទី២១ មួយបន្ថែមទៀតបង្រួមជាមួយបណ្ណាល័យទាំង ១២ ដែលបង្កើតឡើងដោយគម្រោងត្រាក់/TRAC ដំបូងគេ។<br>• សៀវភៅជាភាសាអង់គ្លេសចំនួន ៨.០២៨ក្បាលត្រូវបានបរិច្ចាគក្នុងឆ្នាំនេះដោយគម្រោង BfC និងផ្តល់ប្រយោជន៍ដល់កុមារចំនួន ៧៦.០០០នាក់។ |

### សេចក្តីសង្ខេប:

ចាប់ផ្តើមក្នុងឆ្នាំ២០១៥ ខេបបានកែប្រែវិធីអភិវឌ្ឍន៍បណ្ណាល័យដោយបង្កើតជារចនាបថថ្មីដែលធ្វើឱ្យបណ្ណាល័យសាលារៀនផ្លាស់ប្តូរ និងដំណើរការ។ រចនាបថថ្មីនេះព្យាយាមលើកកម្ពស់វិធីសិក្សាថ្មី ជាតម្រូវការនៅក្នុងសតវត្សរ៍ទី២១ ដូចជា៖ ការសិក្សាស្រាវជ្រាវតាមអនឡាញ ការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក និងការប្រើប្រាស់សៀវភៅអេឡិចត្រូនិក។ ទោះបីជាយ៉ាងណាក៏ដោយ ខេបបានបញ្ចុះបញ្ចូលម្ចាស់ជំនួយជាច្រើនឱ្យធ្វើការវិនិយោគទាំងក្នុងរចនាបថបណ្ណាល័យសតវត្សរ៍ទី២១ ក៏ដូចជាបណ្ណាល័យធម្មតាដែលមានប្លង់ទាក់ទាញ សូម្បីតែគ្មានបំពាក់គ្រឿងបរិក្ខាភ្លើងអគ្គិសនីសម្រាប់សិក្សាក៏ដោយ។ មកដល់បច្ចុប្បន្ននេះ ខេបបានបង្កើតបណ្ណាល័យសតវត្សរ៍ទី២១ ចំនួន៥៥កន្លែង និងចំនួន៧៤ ទៀតប្រើប្រាស់រចនាបថថ្មី (សូមមើលតារាងខាងក្រោម)។ ខេបក៏បានជួយផ្តល់ទាំងសៀវភៅសិក្សាជាភាសាអង់គ្លេស និងភាសាខ្មែរតាមរយៈគម្រោងសៀវភៅសម្រាប់កម្ពុជា (BfC) ដែលគាំទ្រហិរញ្ញប្បទានពីអង្គការមូល និធិអាស៊ី និងក្រសួងអប់រំយុវជននិង កីឡា។




### ការអភិវឌ្ឍក្នុងបច្ចុប្បន្នភាព:

ខេបបានអភិវឌ្ឍន៍សៀវភៅបណ្ណាល័យផ្លូវការចប់សព្វគ្រប់សម្រាប់ជួយដល់ក្រសួងអប់រំ យុវជន និងកីឡា ដើម្បី ចម្លងបណ្ណាល័យសតវត្សរ៍ទី២១ ទៅប្រើប្រាស់នៅទីតាំងផ្សេងៗទៀត។ សៀវភៅនេះនឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្សព្វផ្សាយអំពីរចនាបថបណ្ណាល័យថ្មីៗនៅក្នុងគម្រោងអភិវឌ្ឍន៍វិស័យអប់រំ-មធ្យមសិក្សា២ ដែលក្រសួងអប់រំ យុវជន និងកីឡាបានស្នើសុំឱ្យខេបជាអ្នកជួយផ្តល់ការគាំទ្រផ្នែកបច្ចេកទេស។ សាលាមធ្យមសិក្សចំនួនជាង ១៣០សាលានឹងទទួលបានប្រយោជន៍ពីការគាំទ្រនេះ។

| គម្រោង | បណ្ណាល័យសតវត្សរ៍ទី២១ | បណ្ណាល័យធម្មតា | សរុប |
|---|---|---|---|
| គម្រោង (ត្រាក់៣/TRACIII) | ១៨ | ០ | ១៨ |
| គម្រោងរីក៣/REACH III | ១២ | ២៨ | ៤០ |
| គម្រោងកុមារកម្ពុជារីករាយ (HCC) | ១ | ៣៤ | ៣៥ |
| គម្រោងសាលារៀនជំនាន់ថ្មី (NGS) | ៨ | ០ | ៨ |
| គម្រោងងាយស្រួលរៀន (បានបញ្ចប់) (E2L) | ១៦ | ១២ | ២៨ |
| សរុប | ៥៥ | ៧៤ | ១២៩ |

*ប្លង់ដ៏ល្អសម្រាប់បណ្ណាល័យសតវត្សរ៍ទី ២១ មានលក្ខណៈធំទូលាយដូចមានបង្ហាញខាងក្រោមនេះ។ រចនាបថសម្រាប់បណ្ណាល័យនេះមានចន្លោះបន្ទប់រៀនពីរ។ បណ្ណាល័យប្រើប្រាស់ពណ៌ចម្រុះទាន់សម័យ (ពណ៌ឈើ)។ ម្យ៉ាងវិញទៀត បរិវេណក្នុងបណ្ណាល័យមានមុខងារផ្សេងៗគ្នា (ឧ. កន្លែងសិក្សាស្រាវជ្រាវ ទូរដាក់សៀវភៅរាងមូលសម្រាប់សិស្ស សិក្សាបែបបុគ្គល កន្លែងមើលទូរទស្សន៍មានជញ្ជាំងរូបភាព...ជាដើម។ល។) លេចឡើងលាយលំគ្នា ប៉ុន្តែមានសោភ័ណភាពល្អលើកម្រាលឥដ្ឋនៅកណ្តាលបណ្ណាល័យ ជួយបង្កើតជាដែនកំណត់មួយផ្នែកទៀតរបស់បណ្ណាល័យដែលនៅសេសសល់។*



# កម្មវិធីអប់រំបំណិនជីវិត និងប្រឹក្សាអាជីព

**“បំណិនជីវិតទទួលបានអត្ថប្រយោជន៍ពីការអប់រំសកម្មគ្រូបង្រៀនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់និងកម្មវិធីសិក្សាឌីណាមិក ”**

## ព័ត៌មានសំខាន់ៗអំពីកម្មវិធីអប់រំបំណិនជីវិត

| | | |
|---|---|---|
| ចំនួនគម្រោង | ១២ | |
| ដៃគូអភិវឌ្ឍន៍សំខាន់ៗ | ក្រសួងអប់រំ យុវជន និងកីឡា - អង្គការឆាលហ្វាន មូលនិធិគិន ឆាន់ អង្គការអុកទ្រី មូលនិធិ GAP ធនាគារអភិវឌ្ឍអាស៊ី | អង្គការវីវើល-GVC អង្គការ Lotus Outreach អង្គការ PACT-USAID សហគមន៍អឺរ៉ុប |
| កាលបរិច្ឆេទវិនិយោគ | ២០០៨ | |
| ប្រធានបទសំខាន់ៗក្នុងការវិនិយោគ | • ការអភិវឌ្ឍគោលនយោបាយស្តីពីការអប់រំបំណិនជីវិត<br>• កម្មវិធីសិក្សាបំណិនជីវិត និងការអភិវឌ្ឍសៀវភៅគោល រួមមាន៖ ផែនការមេរៀន ផ្ទាំងរូបភាព សន្លឹកកិច្ចកា និងឧបករណ៍វាយតម្លៃ<br>• សហគ្រិនភាព និងជំនាញភាពជាអ្នកដឹកនាំ<br>• បណ្តុះបណ្តាលគ្រូបង្រៀនកម្មវិធីបំណិនជីវិត<br>• ផ្លាស់ប្តូរការប្រឹក្សាអាជីពនៅក្នុងសាលារៀនជំនាន់ថ្មី<br>• អភិវឌ្ឍន៍សុសវែរប្រឹក្សាអាជីពតាមប្រព័ន្ធអេឡិចត្រូនិច (ហៅថា ត្រីវិស័យ) ដើម្បីពង្រឹងសេវាប្រឹក្សាអាជីពនៅតាមសាលារៀន | |
| ចំណុចសំខាន់ៗ | • ក្រសួងអប់រំ យុវជន និងកីឡាបានស្នើឱ្យខេបផ្តល់ជំនួយបច្ចេកទេសក្នុងការអភិវឌ្ឍកម្មវិធីបំណិនជីវិត និងសេវាប្រឹក្សាអាជីពនៅក្នុងសាលារៀនចំនួន ១៣៧ ដែលគាំទ្រហិរញ្ញប្បទានដោយធនាគារអភិវឌ្ឍន៍អាស៊ី។<br>• ខេបទទួលបានគម្រោងធំមួយឈ្មោះថា SEEK ដើម្បីជួយពង្រឹងសេវាកម្មប្រឹក្សាអាជីពនៅក្នុងសាលាមធ្យមសិក្សាគោលដៅចំនួន ២០។ | |

## សេចក្តីសង្ខេប

ខេបបានចាប់ផ្តើមវិនិយោគយ៉ាងច្រើនលើកម្មវិធីអប់រំបំណិនជីវិតនៅឆ្នាំ ២០០៨ តាមរយៈការប្រតិបត្តិ ***គម្រោងសាលារៀនដើម្បីជីវិត*** បន្ទាប់មកតាមរយៈការប្រតិបត្តិ ***គម្រោងកែលម្អការអប់រំមូលដ្ឋាននៅកម្ពុជា***។ គម្រោងទាំងនេះផលិតសៀវភៅបំណិនជីវិតបានចំនួន ៣០ក្បាល មាន៣ជំនាញ គឺ៖ (i) ជំនាញពាក់ព័ន្ធសង្គម (ឧ.ការបង្ការការប្រើប្រាស់គ្រឿងញៀន ការចំណាកស្រុកដោយសុវត្ថិភាពជាដើម...។ល។) (ii) បំណិនជីវិតសេដ្ឋកិច្ច (ឧ. ពិភពការងារ) និង (iii) ជំនាញវិជ្ជាជីវៈ (ឧ. ការដាំបន្លែ ការចិញ្ចឹមត្រី ការជួសជុលកង់ជាដើម...។ល។) សៀវភៅបំណិនជីវិតទាំងនេះបង្កើតបានជាមូលដ្ឋានគ្រឹះសកម្មភាពបំណិនជីវិតច្រើនបំផុតដែលបានប្រើប្រាស់នៅក្នុងគម្រោងដទៃទៀត។ នៅក្នុងបច្ចុប្បន្ន សៀវភៅទាំងនេះកំពុងត្រូវបានមូលនិធិ GAP ផ្តល់ជាសៀវភៅបំណិនជីវិតបន្ថែម ដោយផ្តោតលើការឈ្វេងយល់ដោយខ្លួនឯងអំពីយេនឌ័រ។

ទន្ទឹមនឹងនេះដែរ ខេបបានអភិវឌ្ឍន៍គម្រោងពង្រឹងការផ្តល់សេវាប្រឹក្សាអាជីពនៅមធ្យមសិក្សា ដោយប្រើសៀវភៅបំណិនជីវិតសេដ្ឋកិច្ចមួយចំនួនដែលបានអភិវឌ្ឍន៍ដោយគម្រោង IBEC (ឧ. ពិភពការងារ)។ កិច្ចខិតខំប្រឹងប្រែងទាំងអស់នេះរួមមានការបណ្តុះបណ្តាលគ្រូ ដែលធ្វើការងារពេញម៉ោងជាអ្នកប្រឹក្សាដោយប្រើប្រាស់សុសវែរប្រឹក្សាអាជីពតាមប្រព័ន្ធអេឡិចត្រូនិក និងផ្តល់វគ្គសិក្ខាសាលាស្តីពីការងារដល់សិស្សមធ្យមសិក្សា។

## ការអភិវឌ្ឍក្នុងបច្ចុប្បន្នភាព

ចំនួនគម្រោងគាំទ្រកម្មវិធីអប់រំបំណិនជីវិត និងការផ្តល់ប្រឹក្សាអាជីពបានកើនឡើងដល់ ១២គម្រោង រួមទាំងគម្រោងធំៗដែលគាំទ្រដោយសហគមន៍អឺរ៉ុប (SEEK) និងធនាគារអភិវឌ្ឍន៍អាស៊ី(USE-SDP2)។ គម្រោងថ្មីមួយទៀតឈ្មោះថា គម្រោងសហគ្រិនវ័យក្មេង (គាំទ្រហិរញ្ញប្បទានពីអង្គការ PACT-USAID) ក៏ទើបចាប់ផ្តើមសាកល្បងដើម្បីលើកកម្ពស់ភាពជាសហគ្រិន និងជំនាញភាពជាអ្នកដឹកនាំក្នុងចំណោមយុវជន។ លើសពីនេះទៀត គម្រោង LSLAG ក៏បានពន្លឿនកិច្ចខិតខំប្រឹងប្រែងធ្វើឱ្យប្រសើរឡើងនូវកម្មវិធីសិក្សា ភែស(PACE) នៅក្នុងគម្រោងរបស់ខេបទាំងអស់ផងដែរ។








↑ *សិក្ខាសាលាស្តីពីការជ្រើសរើសអាជីពនៅសាលារៀនជំនាន់ថ្មី។*

← *ក្រុមសិស្សបានដឹកនាំការប្រជុំនៅមជ្ឈមណ្ឌលយុវជន ដើម្បីពិភាក្សាគ្នាអំពីការកែលម្អសាលារៀនរបស់ពួកគាត់។*



↑ សិស្សរៀនពីរបៀបដាំបន្លែលើទឹកដែលជាផ្នែកមួយនៃកម្មវិធីបំណិនជីវិតរបស់ខេប។



↑ សិស្សមធ្យមសិក្សាបានជួបជាមួយអ្នកប្រឹក្សាអាជីពក្នុងវគ្គផ្តល់ប្រឹក្សាអាជីពផ្ទាល់ខ្លួន។

# កម្មវិធីឆ្លើយតប និងស្តារឡើងវិញនូវវិស័យអប់រំក្នុងបរិបទជំងឺកូវីដ ១៩

| ព័ត៌មានសំខាន់ខ្លីៗអំពីកម្មវិធីឆ្លើយតប និងស្តារឡើងវិញក្នុងបរិបទជំងឺកូវីដ ១៩ | | |
|---|---|---|
| ចំនួនគម្រោង | ១៣ | |
| ដៃគូអភិវឌ្ឍន៍សំខាន់ៗ | ក្រសួងអប់រំ យុវជន និងកីឡា - អង្គការឆាលហ្វាន មូលនិធិ គីន ឆាន់ ហ៊្វីនីកស៍ និងអង្គការវីវើល-GVC | សហគមន៍អឺរ៉ុប អង្គការយូនីសេហ្វ-GPE3 |
| កាលបរិច្ឆេទវិនិយោគ | ២០២០ | |
| ប្រធានបទសំខាន់ៗក្នុងការវិនិយោគ | • កញ្ចប់សម្ភារសម្រាប់ការពារជំងឺកូវីដ ១៩ (ការអភិវឌ្ឍ និងចែកចាយ)<br>• គាំទ្របច្ចេកទេសដល់ក្រសួងអប់រំ យុវជន និងកីឡាដើម្បីឆ្លើយតប និងស្តារឡើងវិញនូវវិស័យអប់រំក្នុងបរិបទជំងឺកូវីដ ១៩<br>• សហការជិតស្និទ្ធជាមួយមជ្ឈមណ្ឌលអប់រំពីចម្ងាយ និងឌីជីថល (CDDE)<br>• ការសម្របសម្រួលការសិក្សាបន្ត<br>• បណ្តាញសិក្សាអប់រំពីចម្ងាយ និងឌីជីថល<br>• ការសម្របសម្រួលថ្នាក់ជាតិស្តីពីកម្មវិធីឆ្លើយតប និងស្តារឡើងវិញនូវការសិក្សាបំប៉នក្នុងបរិបទកូវីដ ១៩ ។ | |



*គ្រូបង្រៀននៅសាលាគោលដៅគម្រោង SEEK ធ្វើការងាររួមគ្នាដើម្បីស្វែងរកគន្លឹះសំខាន់ៗរៀបចំវិធីសាស្ត្របង្រៀនអំឡុងពេលការរីករាលដាលជំងឺកូវីដ១៩។*

## សេចក្តីសង្ខេប

កម្មវិធីរបស់អង្គការ ខេប ជាច្រើននៅតាមសាលារៀនបានព្យាយាមដោះស្រាយបញ្ហាប្រឈមនានា ដែលកើតឡើងដោយសារតែការរីករាលដាលជំងឺកូវីដ ១៩ ហើយខេបធ្វើការជាមួយក្រសួងអប់រំ យុវជន និងកីឡា ក្នុងការផ្សព្វផ្សាយសន្លឹកកិច្ចការស្វ័យសិក្សា ដែលបង្កើតដោយនាយកដ្ឋាននានារបស់ក្រសួង និងគាំទ្រដល់ការសិក្សាបន្ត។ ខេបក៏បានប្រើប្រាស់ហិរញ្ញប្បទានម្ចាស់ជំនួយបង្កើត ***កញ្ចប់ឧបករណ៍ការពារជំងឺកូវីដ១៩*** រួមមានៈ បរិក្ខារអនាម័យ ដូចជា ម៉ាស់ អាល់កុល និងល្បែងសិក្សាដែលឪពុកម្តាយអាចប្រើប្រាស់បានដើម្បីគាំទ្រដល់ការសិក្សានៅផ្ទះ។ខេបបានធ្វើការតស៊ូមតិឱ្យក្បាលបណ្ណាល័យបើកដំណើរការ (ទោះបីជាសាលារៀនបិទក៏ដោយ) ដូច្នេះ ឪពុកម្តាយសិស្សអាចខ្ចីសៀវភៅ និងល្បែងសិក្សាឱ្យកូនៗពួកគាត់បានប្រើប្រាស់ក្នុងការសិក្សានៅផ្ទះបាន។

ចំពោះការសិក្សាតាមអនឡាញវិញ អង្គការ ខេប បានកំពុងធ្វើការយ៉ាងជិតស្និទ្ធជាមួយ ***មជ្ឈមណ្ឌលអប់រំពីចម្ងាយ និងឌីជីថល***នៃវិទ្យាល័យព្រះស៊ីសុវត្ថិ ធ្វើឱ្យសកម្មភាពសិក្សានៅសាលារៀនជំនាន់ថ្មីដំណើរការទៅមុខតាមអនឡាញ។ ក្នុងន័យនេះ អង្គការ ខេប បានជួយសាលារៀនជាច្រើនក្នុងការឈ្មួសឈ្មួលសកម្មភាពសិក្សាជាទម្រង់អនឡាញ ដោយផ្តោតខ្លាំងទៅលើការផលិតវីដេអូមេរៀន។ វីដេអូប្រមាណ ៤.១៨០ ក្លីបត្រូវបានផលិតដោយសាលារៀនជំនាន់ថ្មីសម្រាប់ចែកចាយទៅមជ្ឈមណ្ឌល CDDE ក៏ដូចជាសិស្សសាលារៀនជំនាន់ថ្មី (សូមមើលតារាងខាងក្រោម)។

អង្គការ ខេប ត្រូវបានក្រសួងអប់រំ យុវជន និងកីឡា និងអង្គការយូនីសេហ្វជ្រើសរើសឱ្យជួយធ្វើការងារបច្ចេកទេសគាំទ្រដល់នាយកដ្ឋានបឋមសិក្សា និងមធ្យមសិក្សាចំណេះដឹងទូទៅរបស់ក្រសួង ក្នុងការបង្កើតសន្លឹកកិច្ចការការសិក្សាបន្ត និងកម្មវិធីបង្រៀនបំប៉នបន្ថែមដែលជាផ្នែកមួយរបស់កម្មវិធី GPE ឈ្មោះថា ***កម្មវិធីឆ្លើយតប និងស្តារឡើងវិញនូវវិស័យអប់រំក្នុងបរិបទជំងឺកូវីដ ១៩***។ គម្រោងនេះបានចាប់ផ្តើមនៅខែធ្នូ ឆ្នាំ ២០២០ ហើយនឹងបន្តរយៈពេលមួយឆ្នាំពេញ។ ខេបមានតួនាទីផ្តោតលើការជួយសម្របសម្រួលជាមួយម្ចាស់ជំនួយព្រមទាំងការគាំទ្របច្ចេកទេសដល់នាយកដ្ឋាននីមួយៗរបស់ក្រសួងអប់រំយុវជននិងកីឡា។

## វឌ្ឍនភាពក្នុងការលើកកម្ពស់ការសិក្សាតាមអនឡាញនៅក្នុងសាលារៀនជំនាន់ថ្មីតាមមុខវិជ្ជា និងកម្មវិធីសាលារៀន (២០២០)

| សាលារៀន | ចំនួនវីដេអូ | | | | | | | | | | | | ចំនួនគ្រូបង្រៀន | ចំនួនគ្រូបង្រៀនចូលរួម | ចំនួនគ្រូបង្រៀនចូលរួមជា % | វីដេអូត្រូវកែលម្អបន្ទាប់ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| មុខវិជ្ជាៈ | K | M | P | C | B | En | H | G | Mo | ES | IT | ដទៃ | សរុប | | | |
| *កម្រិតមធ្យមសិក្សា* | | | | | | | | | | | | | | | | |
| វិទ្យាល័យ ព្រះស៊ីសុវត្ថិ(គ្រូ)* | ១៤៨ | ២៩៨ | ២៣២ | ១៥៤ | ១៣៤ | ៣៧ | ៨៤ | ២០ | ១៩ | ១៤ | ២៧ | ២២ | ១.១៨៩ | ៦១ | ៦១ | ១០០% | ៣២ |
| វិទ្យាល័យ ព្រះស៊ីសុវត្ថិ(អេយក)** | ១៣៦ | ១៩៣ | ៩៦ | ១១៩ | ១១៧ | 0 | ៧៦ | 0 | 0 | 0 | 0 | 0 | ៧៣៧ | | | | |
| វិទ្យាល័យព្រែកលៀប | ៦៨ | ១២០ | ៧១ | ៧៣ | ៦៥ | ៦៨ | ៦៤ | ៧១ | ៦៨ | ៣២ | ៨៤ | 0 | ៧៨៤ | ៥០ | ៤៨ | ៩៦% | ១៦ |
| វិ. ហ៊ុន សែន កំពង់ចាម | ៨៦ | ៨៦ | ៤០ | ៣៣ | ៤៤ | ៨០ | ៣៥ | ២៨ | ៤៧ | ២៩ | ២០ | ២៣ | ៥៥១ | ២២ | ២២ | ១០០% | ២៥ |
| វិទ្យាល័យពាមជីកង | ៤១ | ២៩ | ៣៤ | ៣០ | ៣០ | ២៨ | ៤២ | ៣២ | ៣១ | ១២ | ៤០ | 0 | ៣៤៩ | ២៨ | ២៧ | ៩៦% | ១៣ |
| វិទ្យាល័យព្រែកអញ្ចាញ | ៥២ | ៦០ | ៥៤ | ៥៧ | ៥៥ | ៤៧ | ៤៩ | ៤៩ | ៦៣ | ២៤ | ៦០ | 0 | ៥៧០ | ៤៩ | ៤៦ | ៩៤% | ១២ |
| វិទ្យាល័យគោកព្រីង*** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| **សរុប** | **៥៣១** | **៧៨៦** | **៥២៧** | **៤៦៦** | **៤៤៥** | **២៦០** | **៣៥០** | **២០០** | **២២៨** | **១១១** | **២៣១** | **៤.១៣៥** | **៤.១៨០** | **២១០** | **២០៤** | **៩៧#** | **២០** |
| *កម្រិតបឋមសិក្សា* | ថ្នាក់ទី១ | ថ្នាក់ទី២ | ថ្នាក់ទី៣ | ថ្នាក់ទី៤ | ថ្នាក់ទី៥ | ថ្នាក់ទី៦ | | | | | | | | | | | |
| សាលាបឋមសិក្សាអនុវត្ត | ២៦ | ៤៦ | ៦០ | ១១ | ៤០ | ១០ | | | | | | | ១៩៣ | ១៣ | ១៣ | ១០០% | ១៥ |
| សាលាបឋមអគ្គមហេសី | ៦០ | ១០ | ១៣ | - | - | - | | | | | | | ៨៣ | ២១ | ២១ | ១០០% | ៤ |
| **សរុប** | **៨៦** | **៥៦** | **៧៣** | **១១** | **៤០** | **១០** | | | | | | | **២៧៦** | **៣៤** | **៣៤** | **១០០%** | **៨** |

** វិ.ស៊ីសុវត្ថិ : វីដេអូសម្រាប់គ្រូ; ** វិ.ស៊ីសុវត្ថិ: អភិវឌ្ឍន៍វីដេអូសម្រាប់ក្រសួងអប់រំ; *** ដោយសារសេវាអ៊ីនធឺណែតមិនអាចទុកចិត្តបាន ឬទាញយកសន្លឹកកិច្ចការរបស់ក្រសួងបាន ។*

# ប្រវត្តិកម្មវិធី

## គម្រោង សាលារៀនជំនាន់ថ្មី (NGS)

| | |
|---|---|
| ម្ចាស់ជំនួយ | ក្រសួងអប់រំ យុវជន និងកីឡា<br>មូលនិធិគ្រួសារត្រកូលហ្វ្រែងស៍ |
| អ្នកទទួលផលផ្ទាល់ | ៥.៧២២ |
| ថវិកាទទួលបានក្នុងឆ្នាំ២០២០ | ១.៦៦៤.០០០ ដុល្លារ |
| ថវិកាសម្រាប់អ្នកទទួលផល | ២៩២ ដុល្លារ |
| ខេត្តគ្របដណ្ដប់ | ៤ (កំពង់ចាម ភ្នំពេញ កណ្ដាល កំពង់ស្ពឺ) |
| ចំនួនស្រុកគ្របដណ្ដប់ | ៦ ស្រុក |
| បឋមសិក្សាគោលដៅ | ៣ |
| មធ្យមសិក្សាគោលដៅ | ៥ សាលា |
| កាលបរិច្ឆេទចាប់ផ្ដើមគម្រោង | ខែតុលា ឆ្នាំ២០១៥ |
| កាលបរិច្ឆេទបញ្ចប់គម្រោង | មិនកំណត់ |

**<u>សេចក្ដីសង្ខេប</u>៖** កម្មវិធីសាលារៀនជំនាន់ថ្មីបានដំណើរដល់ឆ្នាំទី៥ ក្រោមជំនួយហិរញ្ញប្បទានពីក្រសួងអប់រំ យុវជន និងកីឡា និងប្រតិបត្តិដោយអង្គការ ខេប។ ទោះបីមានឧបសគ្គហិរញ្ញប្បទានក្នុងរដ្ឋាភិបាលក៏ដោយ ក្រសួងបានយល់ព្រមពង្រីកហិរញ្ញប្បទានសម្រាប់ឆ្នាំសារពើពន្ធ ២០២១ ដែរ។ ចំនួនសាលារៀនជំនាន់ថ្មីដែលបានគាំទ្រទាំង១០ នៅមានស្ថេរភាពពីឆ្នាំមុន (សាលា ៨ គាំទ្រដោយក្រសួងអប់រំ យុវជន និងកីឡា និង ២ គាំទ្រដោយអង្គការឆាលហ្វាន)។ សាលារៀនគាំទ្រមួយចំនួនបានពង្រីកចំនួនកម្រិតថ្នាក់ពីការវិនិយោគរបស់សាលារៀនជំនាន់ថ្មីទៅក្នុងសាលារៀនទាំងមូល។ ការវិនិយោគនេះរួមមាននៅសាលា៖ ព្រែកលៀប ព្រែកអញ្ចាញ ពាមជីកង សាលាបឋមសិក្សាអគ្គមហេសី និងសាលាបឋមសិក្សាអង្គរបាន។ តម្រូវការបញ្ចូលសាលារៀនទាំងនេះទៅជាសាលារៀនជំនាន់ថ្មីបានកើនឡើងលើសពីការកំណត់បង្ហាញថាជាសាលារៀនស្តង់ដាគុណភាពខ្ពស់ និងមានការគាំទ្រពីសាធារណៈជន។ ការវាស់ស្ទង់ការអនុវត្តន៍សាលារៀនជំនាន់ថ្មីបង្ហាញឱ្យឃើញពីសមិទ្ធផលដ៏ធំធេង។

## គម្រោង សាលារៀនជំនាន់ថ្មី (NGS) - ស្វាយរៀង

| | |
|---|---|
| ម្ចាស់ជំនួយ | អង្គការឆាលហ្វាន កម្ពុជា |
| អ្នកទទួលផលផ្ទាល់ | សិស្សសរុប ៧៥២នាក់ |
| ថវិកាទទួលបានក្នុងឆ្នាំ២០២០ | ១៣៩.០៦០ ដុល្លារ |
| ថវិកាសម្រាប់អ្នកទទួលផលក្នុង១នាក់ | ១៨៥ ដុល្លារ |
| ខេត្តគ្របដណ្ដប់ | ស្វាយរៀង |
| ចំនួនស្រុកគ្របដណ្ដប់ | ស្វាយជ្រំ |
| មធ្យមសិក្សាគោលដៅ | ១ |
| បឋមសិក្សាគោលដៅ | ១ |
| កាលបរិច្ឆេទចាប់ផ្ដើមគម្រោង | កក្កដា ២០១៨ |
| កាលបរិច្ឆេទបញ្ចប់គម្រោង | សីហា ២០២១ |

**<u>សេចក្ដីសង្ខេប</u>៖** កម្មវិធីសាលារៀនជំនាន់ថ្មីក្នុងខេត្តស្វាយរៀងដូចគ្នាទៅនឹងកម្មវិធីសាលារៀនជំនាន់ថ្មីថ្នាក់ជាតិ ដែលគាំទ្រហិរញ្ញប្បទានផ្ទាល់ដោយក្រសួងអប់រំ យុវជន និងកីឡា និងប្រតិបត្តិដោយអង្គការ ខេប។ លក្ខណៈកម្មវិធីសំខាន់ៗក្នុងខេត្តស្វាយរៀង រួមមាន៖ ការបង្កើតសាលារដ្ឋស្វយ័តដែលសម្រេចបាននូវស្តង់ដាអប់រំខ្ពស់តាមលក្ខខណ្ឌវិនិយោគ។ ស្តង់ដាទាំងនេះស្ថិតក្រោមដំណើរការទទួលស្គាល់គុណភាព និងសុពលភាពកំណត់នៅក្នុងក្របខ័ណ្ឌគោលនយោបាយ។ ដូច្នេះ អភិបាលកិច្ច គណនេយ្យភាព និងកម្រិតវិជ្ជាជីវៈខ្ពស់គឺជាធាតុស្នូលកម្មវិធី។ ការសាកល្បងកម្មវិធីសាលារៀនជំនាន់ថ្មីក្នុងខេត្តស្វាយរៀងមានភាពខុសប្លែកពីកម្មវិធីថ្នាក់ជាតិ ដោយជ្រើសរើសសាលារៀននៅទីជនបទ ដើម្បីធ្វើតេស្តពីភាពផ្ទុយគ្នានឹងសាលានៅទីក្រុង។ ការទទួលស្គាល់ជាផ្លូវការដោយក្រុមប្រឹក្សាភិបាលសាលារៀនជំនាន់ថ្មីថ្នាក់ជាតិឆ្នាំនេះបង្ហាញថា មានទំនុកចិត្តចំពោះសាលាគំរូនេះ អាចចម្លងទៅអនុវត្តនៅទីជនបទជាច្រើនបាន។ ម្យ៉ាងវិញទៀត ការសាកល្បងនេះរកឃើញថា វាត្រូវការពេលច្រើនជាង ៣ ឆ្នាំដើម្បីវិនិយោគឱ្យដល់ស្តង់ដា (ដូចមានចែងនៅក្នុងគោលនយោបាយ) ហើយគួររក្សាជាគំនិតសម្រាប់ចម្លងនាពេលអនាគត។

## មជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី

| | |
|---|---|
| ម្ចាស់អំណោយ | ក្រសួងអប់រំ យុវជន និងកីឡា |
| ចំនួនអ្នកទទួលផលផ្ទាល់ | គរុនិស្សិតចំនួន ២៥នាក់ |
| ថវិកាទទួលឆ្នាំ២០២០ | ១៦៣.៥៨២ ដុល្លារអាមេរិក |
| តម្លៃជាមធ្យមសិស្សម្នាក់ | មិនមាន |
| ចំនួនខេត្តគ្របដណ្ដប់ | រាជធានីភ្នំពេញ |
| ចំនួនស្រុកគ្របដណ្ដប់ | ១ |
| សាលាគោលដៅ | គ្រឹះស្ថានឧត្តមសិក្សា |
| កាលបរិច្ឆេទចាប់ផ្ដើមគម្រោង | ១៦ កញ្ញា ២០២០ |
| កាលបរិច្ឆេទបញ្ចប់គម្រោង | មិនកំណត់ |




*ឯកឧត្តមបណ្ឌិតសភាចារ្យ ច័ន្ទ រ័ត្ន ប្រធានមជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី បានអញ្ជើញឯកឧត្តមបណ្ឌិតសភាចារ្យ សុខ ទូច ប្រធានរាជបណ្ឌិត្យសភាកម្ពុជាចូលថ្លែងបិទសន្និសីទអន្តរជាតិលើកទី១ ស្តីពី "**ការអប់រំប្រឹក្សាគរុកោសល្យ**" ដែលបានរៀបចំដោយមជ្ឈមណ្ឌល។*

**<u>គោលបំណង</u>៖** ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតមជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី ដើម្បីជួយដល់ការពង្រីកសាលារៀនជំនាន់ថ្មីជាសាលារដ្ឋស្វយ័តដែលទទួលបានការវិនិយោគខ្ពស់ពីរដ្ឋាភិបាល និងទាមទារគ្រូបង្រៀនមានស្តង់ដាខ្ពស់ធ្វើការនៅទីនេះ។

**<u>ចក្ខុវិស័យ</u>៖** ចក្ខុវិស័យមជ្ឈមណ្ឌលគឺដើម្បីផ្លាស់ប្តូរចរិតលក្ខណៈសាលានៅប្រទេសកម្ពុជាឱ្យមានចលនាយន្តការពីគ្រូឧទ្ទេសមានបទពិសោធន៍ ដែលអាចជួយបណ្តុះទាំងវិជ្ជាជីវៈ និងសីលធម៌ ធ្វើឱ្យសាលារៀនរបស់ពួកគាត់មានភាពរីករាយ និងជាកន្លែងទាក់ទាញការសិក្សា។

**<u>បេសកកម្ម</u>៖** មជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មីធ្វើការស្រាវជ្រាវ ដែលនឹងផ្តល់ព័ត៌មានកាន់តែប្រសើរដល់ការបណ្តុះបណ្តាលគ្រូ មានសមត្ថភាពរឹតតែរឹងមាំ ស្វែងយល់របៀបបង្រៀនបន្តដល់គ្រូផ្សេងៗទៀតតាមវិធីមានប្រសិទ្ធភាព និងគ្មានការគំរាមកំហែង។

# ប្រវត្តិកម្មវិធី

## គម្រោង សៀវភៅសម្រាប់កម្ពុជា (BFC)

| | |
|---|---|
| ម្ចាស់ជំនួយ | អង្គការមូលនិធិអាស៊ី និង ក្រសួងអប់រំ យុវជន និងកីឡា |
| អ្នកទទួលផលផ្ទាល់ | ៦៩.២២៦ (ស្រី ៣៦.២១៦) |
| ថវិកាបដិភាគទទួលបានឆ្នាំ២០២០ | ២០១.៣៧០,៣៨ ដុល្លារ |
| ថវិកាសម្រាប់អ្នកទទួលផល | ២.៩០ ដុល្លារក្នុង១នាក់ |
| ខេត្តគ្របដណ្តប់ | ១២ |
| ចំនួនស្រុកគ្របដណ្តប់ | ៤២ |
| វិទ្យាស្ថានរដ្ឋាភិបាល និងសាកលវិទ្យាល័យគោលដៅ | ៣ |
| អង្គការមិនមែនរដ្ឋាភិបាលគោលដៅ | ២ |
| អនុវិទ្យាល័យគោលដៅ | ៧០ |
| បឋមសិក្សាគោលដៅ | ១២ |
| សាលាបណ្តាញ និងសាលាធនធាន | ២ |
| វិទ្យាស្ថានដទៃទៀត | ១ |
| កាលបរិច្ឆេទចាប់ផ្តើមគម្រោង | ០១ មេសា ២០១៤ |
| កាលបរិច្ឆេទបញ្ចប់គម្រោង | ៣១ ធ្នូ ២០២២ |

**គោលបំណង:** អនុស្សារណៈយោគយល់ថ្មីរបស់កម្មវិធីជាមួយក្រសួងអប់រំ យុវជន និងកីឡា និងអង្គការមូលនិធិអាស៊ីបានផ្តល់អាទិភាពដល់ការបរិច្ចាគសៀវភៅដល់សាលាមធ្យមសិក្សាដោយផ្តោតលើខេត្តថ្មីចំនួន ៥ជារៀងរាល់ឆ្នាំ ដោយមានគោលបំណងគ្របដណ្តប់ទាំង ២៥ខេត្តក្រុង ក្នុងរយៈពេល៥ឆ្នាំ។ គម្រោងព្យាយាមលើកកម្ពស់ការអានភាសាអង់គ្លេស នៅកម្រិតអនុវិទ្យាល័យ និងវិទ្យាល័យ។ នៅឆ្នាំសិក្សាបន្ទាប់ BfC នឹងជ្រើសរើសយកសាលាដែលលេចធ្លោមួយក្នុងចំណោមសាលារៀនចំនួន ២០០ ដើម្បីឱ្យដំណើរការបណ្ណាល័យសាធារណៈ។

## គម្រោងបរិស្ថានសិក្សាប្រកបដោយគុណភាព (QLE Ex.)

| | |
|---|---|
| ម្ចាស់ជំនួយ | ន័រវ៉ាដ/អង្គការសង្គ្រោះកុមារ |
| អ្នកទទួលផលផ្ទាល់ | សិស្ស ៨.៨៨១ នាក់ |
| ថវិកាបានទទួលឆ្នាំ២០២០ | ៣៨.០១៧ ដុល្លារ |
| ថវិកាសម្រាប់អ្នកទទួលផល | ៤.២៨១ ដុល្លារក្នុង១នាក់ |
| ខេត្តគ្របដណ្តប់ | ២ (កំពង់ចាម និងត្បូងឃ្មុំ) |
| ស្រុកគ្របដណ្តប់ | ៩ |
| បឋមសិក្សាគោលដៅ | ១៧ |
| កាលបរិច្ឆេទចាប់ផ្តើមគម្រោង | ០១ មករា ២០១៦ |
| កាលបរិច្ឆេទបញ្ចប់គម្រោង | ៣១ ធ្នូ ២០២០ |

**គោលបំណង:** សាលាបឋមសិក្សានៅកម្ពុជាមានការកែលម្អ និងផ្តល់លទ្ធផលសិក្សាប្រសើរជាងមុន។




*គម្រោង BfC បានរៀបចំផ្តល់ការបណ្តុះបណ្តាលដល់លោកនាយក និងបណ្ណារក្សគោលដៅអំពីវិធីសាស្ត្រគ្រប់គ្រងបណ្ណាល័យ និងការចុះលេខកូដសៀវភៅ។*

## គម្រោង កុមារកម្ពុជារីករាយ (HCC)

| | |
|---|---|
| ម្ចាស់អំណោយ | មូលនិធិ គីនឆាន ស្ទីហ្វទុង |
| ចំនួនអ្នកទទួលផលផ្ទាល់ | ៨.៥៩៩ (ស្រី ៤.២០៣នាក់) |
| មត្តេយ្យ | ១០៣ (ស្រី ៥៨នាក់) |
| កម្រិតបឋម | ៨.៤៩៨ (ស្រី ៤.១៩០នាក់) |
| ថវិកាទទួលឆ្នាំ២០២០ | ៦៦៣.៦៥៤ ដុល្លារ |
| តម្លៃជាមធ្យមសិស្សម្នាក់ | ៧៦ ដុល្លារ |
| ចំនួនខេត្តគ្របដណ្តប់ | ៥ (សៀមរាប កំពង់ចាម រតនគិរី ក្រចេះ ត្បូងឃ្មុំ) |
| ចំនួនស្រុកគ្របដណ្តប់ | ១៣ (វ៉ារិន ក្រឡាញ់ កំពង់សៀម មេមត់ ពញាក្រែក តំបែរ ស្ទួល ចិត្របូរី សំបូរ អូរយ៉ាដាវ បរកែវ លំផាត់ អូររាំង) |
| សាលាគោលដៅ៖ | បឋម ចំនួន ៤១ សាលាជំរុំទី១ ចំនួន ១២ សាលាជំរុំទី២ ចំនួន ១៣ សាលាជំរុំទី២ ចំនួន ១៦ សាលាមត្តេយ្យចំនួន ១ |
| កាលបរិច្ឆេទចាប់ផ្តើមគម្រោង | ០១ សីហា ២០១៨ |
| កាលបរិច្ឆេទបញ្ចប់គម្រោង | មិនកំណត់ |

**គោលបំណងទី១៖** ពង្រឹងលទ្ធភាពទទួលបានសេវាអប់រំឱ្យមានភាពប្រសើរឡើងនៅតំបន់គោលដៅ (ពិសេសសម្រាប់កុមារី និងកុមារងាយរងគ្រោះ)។

**គោលបំណងទី២៖** ពង្រឹងប្រសិទ្ធភាពបង្រៀន និងរៀន (គុណភាពអប់រំ) ឱ្យមានភាពប្រសើរឡើងតាមរយៈការអភិវឌ្ឍ និងការអនុវត្តកម្មវិធីសាលាកុមារមេត្រីក្នុង និងក្រៅថ្នាក់រៀនតាមរបៀបដែលពាក់ព័ន្ធនឹងតម្រូវការរបស់កុមារ ជាពិសេសកុមារងាយរងគ្រោះ និងកុមារី។

**គោលបំណងទី៣៖** ពង្រឹងសកម្មភាពអំណានថ្នាក់ដំបូងរបស់កុមារឱ្យបានប្រសើរឡើង ពិសេសសម្រាប់កុមាររៀនថ្នាក់ទី១, ២ និងទី៣។

**គោលបំណងទី៤៖** កែលម្អសមត្ថភាពគ្រប់គ្រងដៃគូនៅមូលដ្ឋាន ដើម្បីបង្កើនលទ្ធភាពទទួលបានសេវាអប់រំ និងគុណភាពបង្រៀននិងរៀន ក៏ដូចជាការផ្សព្វផ្សាយនៅតាមសហគមន៍។

# ប្រវត្តិកម្មវិធី

## គម្រោងបង្កើនភាពងាយស្រួលចូលសាលារៀន តាមរយៈការគាំទ្រពីសហគមន៍ (REACH III/រីក៣)

| | |
|---|---|
| ម្ចាស់ជំនួយ | អង្គការ វីវើល |
| អ្នកទទួលផលផ្ទាល់ | ១៧.៩៤១ នាក់ |
| ថវិកាបានទទួល ឆ្នាំ២០២០ | ៣២៤.៥៥៥,២៨ ដុល្លារ |
| ថវិកាសម្រាប់អ្នកទទួលផល | ១៨,០៩ ដុល្លារក្នុង១នាក់ |
| ខេត្តគ្របដណ្តប់ | ៤ ខេត្ត |
| ស្រុកគ្របដណ្តប់ | ៨ ស្រុក |
| បឋមសិក្សាគោលដៅ | ៣៨ សាលា |
| កាលបរិច្ឆេទចាប់ផ្តើមគម្រោង | ០១ មករា ២០១៩ |
| កាលបរិច្ឆេទបញ្ចប់គម្រោង | ៣០ ធ្នូ ២០២០ |

**គោលបំណង:** គម្រោងរីកដំណាក់កាលទី៣គឺការបង្កើតសកម្មភាពការការពារកុមារ និងផលជះនៃការសិក្សារបស់កុមារលើផ្នែកជាច្រើន រួមមាន៖ ការពង្រឹងអក្ខរកម្ម លេខនព្វន្ត និងបំណិនជីវិត តាមរយៈយុទ្ធសាស្រ្តចម្រុះដែលលើកកម្ពស់ការអភិវឌ្ឍ អភិបាលកិច្ច និងបរិស្ថានសិក្សាដែលមានគុណភាពខ្ពស់ទាំងនៅក្នុងសាលារៀន និងនៅតាមផ្ទះក្នុងខេត្តគោលដៅទាំងបួន។

គម្រោងរីកគឺជាគម្រោងធំមួយផ្សេងទៀតរបស់អង្គការ ខេប ដែលប្រើវិធីសាស្រ្តអភិវឌ្ឍន៍ចម្រុះដើម្បីបង្កើតទិដ្ឋភាពសិក្សារៀនសូត្រផ្សេងៗច្រើនដល់សិស្សានុសិស្ស ដូចជា៖ បង្កើតភាពងាយស្រួលចូលសាលារៀន បរិស្ថានអប់រំ ការចូលរួមរបស់សហគមន៍ ការការពារកុមារ។ល។ ដែលឈរលើគោលនយោបាយកម្មវិធីសាលាកុមារមេត្រី។

## គម្រោងអប់រំបំណិនជីវិតសម្រាប់កុមារី (LSLAG)

| | |
|---|---|
| ម្ចាស់ជំនួយ | ក្រុមហ៊ុន Gap Inc |
| អ្នកទទួលផលផ្ទាល់ | ក្មេងស្រី ៦.០០០នាក់ |
| ថវិកាទទួលបានឆ្នាំ២០២០ | ៨.៥០០០ ដុល្លារ |
| ថវិកាសម្រាប់អ្នកទទួលផល | ១៤.១៧ ដុល្លារក្នុង១នាក់ |
| ខេត្តគោលដៅ | ២ (កំពង់ចាម និងត្បូងឃ្មុំ) |
| ស្រុកគោលដៅ | ១១ ស្រុក |
| អនុ/វិទ្យាល័យគោលដៅ | ២៣ សាលា |
| កាលបរិច្ឆេទចាប់ផ្តើមគម្រោង | ០១ ធ្នូ ២០១៨ |
| កាលបរិច្ឆេទបញ្ចប់គម្រោង | ៣១ មីនា ២០២១ |

**គោលបំណង:** គម្រោង LSLAG គឺធ្វើឱ្យដំណើរការការផ្លាស់ប្តូរប្រកបដោយសុខភាពល្អ និងវិជ្ជមានទៅជាមនុស្សពេញវ័យ ខណៈពេលដែលការទទួលស្គាល់ និងដោះស្រាយភាពងាយរងគ្រោះ និងវិសមភាពយេនឌ័រ។

**គោលបំណងសំខាន់ៗ រួមមាន៖**

- ដើម្បីកសាងបំណិន និងប្រសិទ្ធភាពរបស់កុមារីឱ្យមានទំនុកចិត្ត សមត្ថភាពធ្វើការសម្រេចចិត្ត និងចេះធ្វើផែនការសម្រាប់អនាគតរបស់ខ្លួន។
- បង្កើតប្រសិទ្ធភាពសម្រាប់កុមារី ដើម្បីឱ្យពួកគាត់អាចឆ្លងកាត់ការផ្លាស់ប្តូររាងកាយ ផ្លូវចិត្ត និងសង្គមក្នុងអំឡុងពេលវ័យជំទង់ដែលមានផលប៉ះពាល់សំខាន់ៗចំពោះលទ្ធផលនៅពេលពេញវ័យ។

## គម្រោងវិធីសាស្រ្តសរុបដើម្បីពង្រឹងអំណានសម្រាប់កុមារ (ត្រាក់៣/TRAC III)

| | |
|---|---|
| ម្ចាស់ជំនួយ | មូលនិធិ ហ្វូនិកស៍ |
| អ្នកទទួលផលផ្ទាល់ | ៣.៩៦២ នាក់ (ស្រី ១.៨៣៦នាក់) |
| ថវិកាបានទទួលឆ្នាំ២០២០ | ១៩៩.៩៧១,៩៨ ដុល្លារ |
| ថវិកាសម្រាប់អ្នកទទួលផល | ២៦ ដុល្លារក្នុង១នាក់ |
| ខេត្តគ្របដណ្តប់ | ២ ខេត្ត (កំពង់ចាម និងត្បូងឃ្មុំ) |
| ស្រុកគ្របដណ្តប់ | ៨ |
| បឋមសិក្សាគោលដៅ | ១៨ |
| កាលបរិច្ឆេទចាប់ផ្តើមគម្រោង | ០១ កក្កដា ២០១៧ |
| កាលបរិច្ឆេទបញ្ចប់គម្រោង | ៣០ មិថុនា ២០២២ (ពង្រីក) |



*គម្រោង TRAC III ផ្តល់វគ្គបណ្តុះបណ្តាលដល់គ្រូស្តីពីវិធីសាស្រ្តបង្រៀន និងការប្រើប្រាស់ល្បែងសិក្សា។*

**គោលបំណង:** គម្រោង TRACIII មានបំណងបង្កើនកម្រិតអានរបស់កុមារដែលចាំបាច់នឹងទទួលបាននូវជំនាញអានតាមរយៈវិធីសាស្រ្តមួយ ដែលសំដៅលើ បរិស្ថានរៀនសូត្ររបស់កុមារ បរិស្ថានថ្នាក់រៀនទាំងស្រុង និងមានការវាយតម្លៃទៀងទាត់ព្រមទាំងមានការចូលរួមបង្ហាត់បង្រៀនពីឪពុកម្តាយនៅផ្ទះ។

# ប្រវត្តិកម្មវិធី

## គម្រោងលើកកម្ពស់ការឆ្លើយតបនឹងសមភាពយេនឌ័រក្នុងការបង្រៀន និងរៀន (TIGER)

| | |
|---|---|
| ម្ចាស់ជំនួយ | សហគមន៍អឺរ៉ុប អង្គការវីវីអូប៊ី(VVOB) |
| អ្នកទទួលផលផ្ទាល់ | ៤.៨០០ក្មេងស្រី នឹង ៤.៨០០ក្មេង ប្រុស ចំនួន៤០ សាលាបឋមសិក្សា និងអនុវិទ្យាល័យ |
| ថវិកាបានទទួលក្នុងឆ្នាំ២០២០ | ២៧.២០៦,២៧ ដុល្លារ |
| ថវិកាសម្រាប់អ្នកទទួលផល | ២,៨៣ ដុល្លារក្នុង១នាក់ |
| ខេត្តគ្របដណ្តប់ | ខេត្តបាត់ដំបង |
| ស្រុកគ្របដណ្តប់ | ក្រុងបាត់ដំបង |
| មធ្យមសិក្សាគោលដៅ | ១៦ សាលា |
| បឋមសិក្សាគោលដៅ | ២៤ សាលា |
| កាលបរិច្ឆេទចាប់ផ្តើមគម្រោង | ០១ តុលា ២០១៧ |
| កាលបរិច្ឆេទបញ្ចប់គម្រោង | ៣០ កញ្ញា ២០២០ |

### គោលបំណង

- **វត្ថុបំណងរួម:** ធានាថាសិស្សបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិត្រូវបានការពារពីអំពើហិង្សាផ្នែកយេនឌ័រនៅក្នុងសាលារៀន និងជំរុញលទ្ធភាពឱ្យកុមារបានចូលរួមដោយសមធម៌ក្នុងគ្រប់សកម្មភាពនៃជីវិតសាលារៀន និងនៅផ្ទះ។
- **វត្ថុបំណងជាក់លាក់:** ផ្លាស់ប្តូរវិទ្យាស្ថានគរុកោសល្យ និងសាលាចំនួន៤០ ក្នុងខេត្តបាត់ដំបងឱ្យក្លាយជាមណ្ឌលគំរូដែលឆ្លើយតបយ៉ាងប្រសើរលើបញ្ហាយេនឌ័រ។
- **ទំហំគម្រោង:** សិស្សស្រី ៤.៨០០នាក់ និងសិស្សប្រុស ៤.៨០០នាក់នៅបឋម និងអនុវិទ្យាល័យទាំង ៤០សាលានឹងទទួលផលក្នុងអំឡុងពេលអនុវត្តគម្រោង។

## គម្រោងលើកកម្ពស់ការអប់រំ និងការងារនៅកម្ពុជា (SEEK)

| | |
|---|---|
| ម្ចាស់ជំនួយ | សហគមន៍អឺរ៉ុប |
| អ្នកទទួលផលផ្ទាល់ | ២៥.៧០៨នាក់ |
| ថវិកាបានទទួលក្នុងឆ្នាំ២០២០ | ៣១៧.៧៩៣ ដុល្លារ |
| ថវិកាសម្រាប់អ្នកទទួលផល | ១២.៤ ដុល្លារ |
| ខេត្តគ្របដណ្តប់ | ៣ (កំពង់ចាម ត្បូងឃ្មុំ និងកំពង់ឆ្នាំង) |
| ស្រុកគ្របដណ្តប់ | ១២ |
| មធ្យមសិក្សាគោលដៅ | ១៥ |
| បឋមសិក្សាគោលដៅ | ៥០ |
| កាលបរិច្ឆេទចាប់ផ្តើមគម្រោង | ០១ មករា ២០២០ |
| កាលបរិច្ឆេទបញ្ចប់គម្រោង | ៣១ ធ្នូ ២០២២ |

### គោលបំណង:

- កុមារ និងយុវជនទទួលបានការអប់រំប្រកបដោយបរិយាប័ន្នដែលជាមធ្យោបាយមួយក្នុងការលើកកម្ពស់លទ្ធភាពការងាររបស់ពួកគេ ជាពិសេសក្មេងស្រីដែលមកពីសហគមន៍ជនជាតិខ្មែរឥស្លាម។
- សង្គមស៊ីវិល ចូលរួម និងមានសិទ្ធិអំណាចក្នុងការស្វែងរកដំណោះស្រាយនៅក្នុងសហគមន៍ដល់យុវជនងាយរងគ្រោះទៅលើផ្នែកសេដ្ឋកិច្ច និងសង្គមដើម្បីទទួលបានការបណ្តុះបណ្តាលវិជ្ជាជីវៈ តម្រង់ទិសអាជីព និងឱកាសការងារ។
- បង្កើនបណ្តាញយុវជន និងសមត្ថភាពតស៊ូមតិ។

## កម្មវិធីអប់រំបញ្ចូលគ្នា (IEP)

| | គម្រោងអាហារូបករណ៍និស្សិតកម្រិតឧត្តមសិក្ស CTSP | គម្រោងសកម្មភាពយុវជនវ័យក្មេងនៅកម្ពុជា (KYLA) | គម្រោងអប់រំកុមារី (GEI) |
|---|---|---|---|
| ម្ចាស់ជំនួយ | អង្គការមូលនិធិអាស៊ី | អង្គការអ៊ុកទ្រី | អង្គការ Lotus Outreach International |
| អ្នកទទួលផលផ្ទាល់ | និស្សិតចំនួន ៣០នាក់ | សិស្សចំនួន ២២៩នាក់ | សិស្សចំនួន ១០០នាក់ |
| ថវិកាទទួលបានក្នុងឆ្នាំ២០២០ | ៥១.៧៦១,៧៧ ដុល្លារ | ៣៩.៩៩៥,៩៧ ដុល្លារ | ២៩.០៩២,០៥ ដុល្លារ |
| ថវិកាសម្រាប់អ្នកទទួលផល | ១.៧២៥,៤០ ដុល្លារ | ១៧៤,៦៥ ដុល្លារ | ២៩១ ដុល្លារក្នុង១នាក់ |
| ខេត្តគ្របដណ្តប់ | កំពង់ចាម ត្បូងឃ្មុំ ក្រចេះ និងព្រៃវែង | កំពង់ចាម ត្បូងឃ្មុំ | កំពង់ចាម ត្បូងឃ្មុំ |
| ស្រុកគ្របដណ្តប់ | ១១ | ៦ | ២ |
| មធ្យមសិក្សាគោលដៅ | គ្មាន | ៦ | ៥ |
| សាលាបណ្តុះបណ្តាលវិជ្ជាជីវៈគោលដៅ | សាកលវិទ្យាល័យ វេស្ទើន ខេត្តកំពង់ចាម | គ្មាន | គ្មាន |
| កាលបរិច្ឆេទចាប់ផ្តើមគម្រោង | ០១ តុលា ២០១៦ | ០១ កុម្ភៈ ២០១៩ | ០១ តុលា ២០១៩ |
| កាលបរិច្ឆេទបញ្ចប់គម្រោង | ៣០ កញ្ញា ២០២០ | ៣១ ធ្នូ ២០១៩ | ៣០ សីហា ២០២២ |

អង្គការ ខេប បានបង្រួមបញ្ចូលគម្រោងតូចៗ និងមធ្យមមួយចំនួនដោយផ្តោតលើការអប់រំបរិយាប័ន្នស្ថិតក្រោមឆ័ត្រតែមួយ ដែលហៅថា **កម្មវិធីអប់រំបរិយាប័ន្ន (IEP)** ដោយមានគោលដៅចម្បងគឺបង្កើនការទទួលបានការអប់រំ ជាពិសេសសម្រាប់ក្មេងស្រីជនជាតិខ្មែរឥស្លាម និងកុមារ/យុវជនដែលងាយរងគ្រោះ។ កម្មវិធី IEP ជួយដល់កុមារ និងយុវជនជាច្រើនចាប់ពីកម្រិតអនុវិទ្យាល័យដល់កម្រិតឧត្តមសិក្សា វិជ្ជាជីវៈ និងកម្រិតបណ្តុះបណ្តាលជំនាញ។ កម្មវិធី IEP មានគម្រោងចំនួន៣ ផ្សេងគ្នា រួមមាន៖ **កម្មវិធីអាហារូបករណ៍និស្សិតកម្រិតឧត្តមសិក្សា** ( **CTSP)** **គម្រោងសកម្មភាពយុវជនវ័យក្មេងនៅកម្ពុជា** ( **KYLA)** និង**គម្រោងអប់រំកុមារី (GEI)**។

# សេចក្ដីសង្ខេបផ្នែកហិរញ្ញវត្ថុ

## សាច់ប្រាក់ និងការចំណាយ

| សេចក្ដីពណ៌នា | ចំនួនទឹកប្រាក់ជាដុល្លារអាមេរិក |
|---|---|
| ចំណូលថវិកាសរុបក្នុងគម្រោងប្រចាំឆ្នាំ២០២០ | ៣.៨៨១.២២៥,២៦ |
| សមតុល្យចុងគ្រាពីឆ្នាំ២០១៩ | ៩១៣.៥៩០,៨៦ |
| ចំណូលការប្រាក់ | ៤៤៦,៣៣ |
| ទ្រព្យដែលអាចប្រើប្រាស់ក្នុងឆ្នាំ២០២០ | ៤.២៩៥.២៦២,៤៥ |
| សរុបថវិកាចំណាយប្រចាំឆ្នាំ២០២០ | ៤.០០១.៤២៧,៦៩ |
| អត្រាប្រើប្រាស់ថវិកា | ៩៣% |

## និន្នាការទទួលថវិកា




## តើថវិកាជំនួយត្រូវយកទៅប្រើប្រាស់ដូចម្ដេច ?




## លំហូរចំណូលឆ្នាំ២០២០

| ម្ចាស់ជំនួយ | ចំនួនទឹកប្រាក់ជាដុល្លារអាមេរិក |
|---|---|
| ក្រសួងអប់រំ យុវជន និងកីឡា | ១.៨២១.៦២៧,៥៨ |
| ហាមុត (មូលនិធិគីនឆាន់ ស្ទីហ្វទុង) | ៨២៧.០០៣,៨៩ |
| អង្គការវីវីល | ២៩០.០០០,០០ |
| សហគមន៍អឺរ៉ុប | ២៨៦.០១៣,០៨ |
| មូលនិធិហ្វីនីកស៍ | ១៩៩.៩៥៧,០០ |
| អង្គការយូនីសេហ្វ | ១៨៧.០១២,៨៦ |
| អង្គការឆាលហ្វានកម្ពុជា | ១២០.២៣៦,៥៦ |
| អង្គការអុកទ្រី | ៣៩.៨៩៥,៩៧ |
| អង្គការសង្គ្រោះកុមារ/SC | ៣៨.០០៥,៥៥ |
| អង្គការមូលនិធីអាស៊ី | ៣៣.២៤៧,១៨ |
| អង្គការវីអ៊ូប៊ី | ២៥.៣៧៦,៥៩ |
| អង្គការ PACT | ៧.០០០,០០ |
| អង្គការ Lotus Outreach | ៥.៨៤៤,០០ |
| ក្រុមហ៊ុន GAP Inc | ៥,០០ |
| ប្រាក់ចំណូលថ្មីទទួលបានក្នុងឆ្នាំ២០២០ | ៣.៨៨១.២២៥,២៦ |

## សេចក្ដីថ្លែងអំណរគុណ!

ជូសមុខឱ្យកុមារ គ្រូបង្រៀន ឳពុកម្ដាយ និងក្រុមអ្នកទទួលផលទាំងនោះមកពីកម្មវិធីរបស់យើង អង្គការ ខេប សូមថ្លែងអំណរគុណដល់ម្ចាស់ជំនួយទាំងអស់សម្រាប់ការផ្ដត់ផ្គង់របស់ពួកគេក្នុងឆ្នាំនេះ និងឆ្នាំមុនៗកន្លងមក។ ការផ្ដត់ផ្គង់ហិរញ្ញវត្ថុបានធ្វើឱ្យអង្គការ ខេប ផ្ដល់នូវសេវាកម្មជូនអ្នកទទួលផលប្រកបដោយអត្ថន័យគ្រប់គ្រាន់។

សូមអរគុណ!

# រចនាសម្ព័ន្ធអង្គការ ខេប ក្នុងឆ្នាំ២០២០




| | |
|---|---|
| AEOs | មន្ត្រីប្រមូលកុមារ និងទំនាក់ទំនងមាតាបិតា |
| AGPO | មន្ត្រីកម្មវិធីប្រមូលសិស្សរៀន និងអភិបាលកិច្ច |
| AS | អ្នកជំនួយការ |
| BfC | គម្រោងសៀវភៅសម្រាប់កម្ពុជា |
| CCO | មន្ត្រីប្រឹក្សាអាជីព |
| DPO | មន្ត្រីកម្មវិធីថ្នាក់ស្រុក |
| DTOs | មន្ត្រីបច្ចេកទេសថ្នាក់ស្រុក |
| EOs | មន្ត្រីអប់រំ |
| FAO | មន្ត្រីហិរញ្ញវត្ថុ និងរដ្ឋបាល |
| FO | មន្ត្រីហិរញ្ញវត្ថុ |
| GES | មន្ត្រីគុណភាពអប់រំទូទៅ |
| HCC | គម្រោងកុមារកម្ពុជារីករាយ |
| ICT in ES | មន្ត្រីជំនាញព័ត៌មានវិទ្យាសម្រាប់ការអប់រំ |
| ICTPO | មន្ត្រីកម្មវិធីបច្ចេកវិទ្យាព័ត៌មានសម្រាប់ការអប់រំ |
| IEP | កម្មវិធីអប់រំបញ្ចូលគ្នា |
| ITO | មន្ត្រីបច្ចេកវិទ្យាព័ត៌មានវិទ្យា |
| KLS | គ្រូបង្រៀនភាសាខ្មែរ |
| M&E | ការតាមដាន និងវាយតម្លៃ |
| M&EO | មន្ត្រីកម្មវិធីផ្នែកតាមដាន និងវាយតម្លៃ &MIS) |
| M&ES/RT | មន្ត្រីជំនាញតាមដាន និងវាយតម្លៃ/គ្រូបណ្ដុះបណ្ដាលអំណាន |
| NAS | ទីប្រឹក្សាគម្រោង NGS (ទំនាក់ទំនងព័ត៌មានវិទ្យាសម្រាប់ការអប់រំ) |
| NGS | គម្រោង សាលារៀនជំនាន់ថ្មី |
| NIO | មន្ត្រីអប់រំ ICT NGS |
| NOM | ប្រធានប្រតិបត្តិការគម្រោង សាលារៀនជំនាន់ថ្មី |
| QGOs | មន្ត្រីកម្មវិធីផ្នែកគុណភាព និងអភិបាលកិច្ច |
| PA | អ្នកជំនួយការកម្មវិធី |
| PC | មន្ត្រីសម្របសម្រួលថ្នាក់ខេត្ត |
| PED/DCD | នាយកដ្ឋានបឋមសិក្សា/នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា |
| PO | មន្ត្រីកម្មវិធី |
| QLE Exp. | គម្រោង បរិស្ថានសិក្សាប្រកបដោយគុណភាព (ពង្រីក) |
| REACH III | គម្រោង បង្កើនភាពងាយស្រួលចូលសាលារៀនតាមរយៈការគាំទ្រពីសហគមន៍ III |
| RERRP | កម្មវិធីឆ្លើយតប និងស្តារឡើងវិញនូវវិស័យអប់រំនៅកម្ពុជា ក្នុងបរិបទជំងឺកូវីដ ១៩ គាំទ្រដោយភាពជាដៃគូសកលដើម្បីការអប់រំ |
| RT | គ្រូបណ្ដុះបណ្ដាលអំណាន |
| RTL | ប្រធានដឹកនាំក្រុមស្រាវជ្រាវ |
| SCO | មន្ត្រីទំនាក់ទំនងជាន់ខ្ពស់ |
| SA | អ្នកសម្របសម្រួលសាលា (2) |
| SAC | មន្ត្រីប្រឹក្សាសាលារៀន |
| SCOs | មន្ត្រីសហគមន៍ជាន់ខ្ពស់ (CIAI) |
| SEA | ជំនួយការអប់រំវិទ្យាសាស្ត្រ |
| SEEK | គម្រោងលើកកម្ពស់ការអប់រំ និងការងារនៅកម្ពុជា |
| SETL | ប្រធានក្រុមអប់រំវិទ្យាសាស្ត្រ |
| SGM | អ្នកប្រឹក្សាអភិបាលកិច្ចសាលារៀន (2) |
| SITO | មន្ត្រីបច្ចេកវិទ្យាព័ត៌មានវិទ្យាជាន់ខ្ពស់ |
| TIGER | គម្រោងលើកកម្ពស់ការឆ្លើយតបនឹងសមភាពយេនឌ័រក្នុងការបង្រៀន និងរៀន |
| TL | ប្រធានក្រុម |
| TO | មន្ត្រីបណ្ដុះបណ្ដាល |
| TRAC III | វិធីសាស្ត្រសរុបដើម្បីពង្រឹងអំណានសម្រាប់កុមារ |

**ផ្នែកដឹកនាំ**

ព្រួញមុខពីរ = ទំនាក់ទំនងជាមួយទីប្រឹក្សា អ្នកសម្របសម្រួលអំណាន និងប្រ.សស.ផ្នែកបច្ចេកវិទ្យាអប់រំ។

ប្រអប់ដាច់ៗ = ស្វ័យយ័តភាព។ គណៈកម្មការគ្រប់គ្រងមូលនិធិសុខភាពមានស្វ័យយ័តភាពពេញលេញ។

**POs**** កម្មវិធីអប់រំបញ្ចូលគ្នា/**IEP** មាន៖ គម្រោង **KYLA** គម្រោងអប់រំកុមារី **GEI** និងគម្រោងអាហារូបករណ៍និស្សិតកម្រិតឧត្តមសិក្សា **CTSP**។ "**POs**" បង្ហាញអំពីមន្ត្រីទាំងអស់នៅក្នុងកម្មវិធី **IEP**។

*សូមបញ្ជាក់ថា លំដាប់ថ្នាក់ក្នុងរចនាសម្ព័ន្ធខាងក្រោមផ្នែកដឹកនាំ ប្រធានផ្នែកនីមួយៗមិនត្រូវបានបញ្ចូលទៅក្នុងផ្នែកហិរញ្ញវត្ថុ និងធនធានមនុស្ស/រដ្ឋបាល ដែលបានកំណត់ហើយនៅក្នុងបញ្ជីឈ្មោះ។